សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et Des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

ស្រាវជ្រាវពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

រៀបរៀងដោយៈ
និស្សិតឈ្មោះ **ម៉ៅ ទិដ្ឋិកា**

សាស្ត្រាចារ្យណែនាំ
លោក **ហ៊ីង គឹមឡេង**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ
ជំនាន់ទី២២

ឆ្នាំចូលសិក្សា ២០១៨
ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំជានិស្សិតឈ្មោះ **ម៉ៅ ទិច្ឆិកា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ថ្នាក់ L4A2 ជំនាន់ទី២២ ឆ្នាំសិក្សា២០១៨-២០២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

នាងខ្ញុំ សូមសម្តែងនូវការគោរពដឹងគុណ និងគោរពថ្លែងអំណរគុណដ៏ជ្រាលជ្រៅជូនចំពោះ៖ លោកឪពុកឈ្មោះ **ភី នៅ** និងអ្នកម្តាយឈ្មោះ **ម៉ៅ សាម៉ុន** ជាអ្នកមានគុណដ៏ធំធេងដែលបានផ្តល់កំណើត និងបានចិញ្ចឹមបីបាច់ថ្នាក់ថ្នមថែរក្សានាងខ្ញុំតាំងពីចាប់កំណើត រហូតមកដល់នាងខ្ញុំធំធាត់ដឹងក្តី ប្រកបដោយព្រហ្មវិហារធម៌ អប់រំទូន្មាន ប្រៀនប្រដៅ ឱ្យនាងខ្ញុំក្លាយជាកូនស្រីដែលរឹងមាំ ព្រមទាំងទទួលបានការសិក្សារហូតដល់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ ក៏ព្រោះតែមានការជួយជ្រោមជ្រែង និងការឧបត្ថម្ភរបស់អ្នកមានគុណអស់ពីកម្លាំងកាយ និងកម្លាំងចិត្ត ។

ឯកឧត្តម **លុយ ចន្ទណ្ណា** ជាសាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រីសាស្ត្រាចារ្យ ព្រមទាំងបុគ្គលិក ទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

លោកសាស្ត្រាចារ្យ **ហ៊ីង គីមឡេង** ដែលលោក បានបង្ហាត់បង្រៀន ផ្ទេរចំណេះដឹង ផ្តល់ដំបូន្មាន ក៏ដូចជាការពន្យល់ ណែនាំតម្រង់ទិស និងបានជួយផ្តល់ជាគំនិតល្អៗ កែតម្រូវកំហុសឆ្គង ចំណុចខ្វះខាតរបស់នាងខ្ញុំតាំងពីចំណុចចាប់ផ្តើម រហូតដល់ទីបញ្ចប់ ដែលធ្វើឱ្យការសរសេរសារណារបស់នាងខ្ញុំ សម្រេចបានជោគជ័យ និងសម្រេចបានជាស្ថាពរ ដែលជាសមិទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរបស់នាងខ្ញុំគួរជាទីមោទនភាព។

លោក **មុត សម្បត្តិ** បងប្រុសដ៏គម្រូ ជាទីគោរព ដែលបានលើកទឹកចិត្តប្អូន គាំទ្រប្អូន ផ្តល់ជាបទពិសោធន៍ គំនិតយោបល់ល្អៗ និងបង្ហាត់បង្រៀន ទូន្មានប្រៀនប្រដៅ ឱ្យនាងខ្ញុំមានភាពក្លាហាន និងក្លាយជាមនុស្សស្រីរឹងមាំជាងមុន ដែលជាកម្លាំងចិត្តជម្រុញឱ្យនាងខ្ញុំកាន់តែមានទឹកចិត្តក្នុងការសម្រេចនូវសារណានេះដោយមិនរាថយ និងប្រកបដោយជំនឿចិត្ត។

ជាទីបញ្ចប់ នាងខ្ញុំ សូមការអនុញ្ញាតដើម្បីបានគោរពបន្ទន់កាយ លើកហត្ថាទាំងទ្វេប្រណម្យបួងសួង និងលំអោនកាយវាចាចិត្តថ្លែងអំណរគុណ និងសម្តែងនូវសេចក្តីដឹងគុណដល់អ្នកមានគុណ លោកសាស្ត្រាចារ្យ លោកស្រីសាស្ត្រាចារ្យ លោកគ្រូអ្នកគ្រូ សូមឱ្យជួបប្រទះតែសេចក្តីសុខ សុខដុមរមនា មានសុខភាពពេញបរិបូរណ៍ ព្រមទាំងប្រកបការងារអ្វីៗបានជោគជ័យប្រកបដោយឧត្តមភាព កិត្យានុភាព និងភាពថ្កុំថ្កើងជានិរន្តរ៍ និងសូមឧទ្ទិសកុសលផលបុណ្យជូនចំពោះវិញ្ញាណក្ខន្ធ លោកឪពុកឈ្មោះ ភី នៅ ព្រមទាំងបុព្វការីជនទាំងអស់ សូមលោកទៅកាន់សុគតិភព និងទៅដល់ទីឋានដែលល្អ ដ៏បរមសុខរៀងអើយ។

# អារម្ភកថា

សារណាមួយក្បាលនេះ គឺជាសមិទ្ធផលមួយដែលកើតឡើងពីការខិតខំប្រឹងប្រែង ការតស៊ូព្យាយាមក្នុងការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេលបួនឆ្នាំកន្លងមកនេះ ដើម្បីបន្សល់ទុកជាស្នាដៃមួយ សម្រាប់ជាគុណប្រយោជន៍ ទៅដល់និស្សិតជំនាន់ក្រោយៗងាយស្រួល ក្នុងការសិក្សាស្រាវជ្រាវបន្ត។ ការសិក្សាអស់រយៈពេលបួនឆ្នាំកន្លងមកនេះ គ្រប់មុខវិជ្ជាដែលនាងខ្ញុំបានសិក្សា គឺសុទ្ធតែមានសារៈសំខាន់សម្រាប់អនុវត្តនាពេលបច្ចុប្បន្ននេះ ហើយសម្រាប់នាងខ្ញុំផ្ទាល់ក៏បានសិក្សាស្រាវជ្រាវទាក់ទងនឹងបញ្ហាច្បាប់នៅក្នុងប្រទេសកម្ពុជាយើងជាច្រើន ដែលប្រជាពលរដ្ឋខ្មែរយើងបានជួបប្រទះនាពេលបច្ចុប្បន្ននេះ។ ឆ្លងកាត់ការស្រាវជ្រាវកន្លងមក នាងខ្ញុំសង្កេតឃើញថាប្រជាពលរដ្ឋខ្មែរយើងនៅមានភាពពុំច្បាស់លាស់ ស្រពិចស្រពិលនៃនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ លើសពីនេះទៅទៀតបញ្ហាដែលចោទឡើងដែលគួរឱ្យបារម្ភ ហើយយើងគួរតែផ្តោតសំខាន់ទៅទៀតនោះគឺពាក់ព័ន្ធនឹង ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ដែលពលរដ្ឋខ្មែរយើងគួរតែយល់ដឹងបន្ថែមទៀត។

ក្នុងនាមនាងខ្ញុំជាយុវជនជំនាន់ក្រោយ នាងខ្ញុំចង់បន្សល់ទុកស្នាដៃ ក៏ដូចជាចង់ចូលរួមក្នុងការចែករំលែកតាមរយៈការស្រាវជ្រាវសារណានេះក្រោមប្រធានបទ "**ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស**" មកធ្វើជាកម្មវត្ថុក្នុងការស្រាវជ្រាវដើម្បីបញ្ចប់ឆ្នាំសិក្សានេះ ហើយនាងខ្ញុំជឿជាក់យ៉ាងមុតមាំថា សារណាមួយនេះពិតជាអាចជួយដល់ពលរដ្ឋខ្មែរ ឬជាតិសាសន៍ដទៃទៀត កាន់តែមានការយល់ដឹងបន្ថែមទៀតពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ និងជាពិសេស ការរៀបអាពាហ៍ពិពាហ៍ជាមួយជាតិសាសន៍ដទៃ។ ជាក់ស្តែងនៅក្នុងអំឡុងពេលស្រាវជ្រាវ នាងខ្ញុំបានទទួលនូវបទពិសោធន៍ ក៏ដូចជាគន្លឹះថ្មីៗជាច្រើន ដែលនាងខ្ញុំពុំធ្លាប់ជួប និងដឹងពីមុនមក ដូច្នេះហើយទើបនាងខ្ញុំជឿជាក់ថា សារណាស្រាវជ្រាវមួយនេះពិតជាអាចផ្តល់នូវអត្ថប្រយោជន៍ គំនិតថ្មីៗ ដល់អ្នកអាន អ្នកស្រាវជ្រាវទាំងអស់ ក្នុងការសិក្សាស្វែងយល់បន្ថែម និងអាចបំពេញនូវចន្លោះខ្វះខាតដែលទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស។

ជាទីបញ្ចប់ នាងខ្ញុំ នៅតែមានការជឿជាក់ថា ការស្រាវជ្រាវសរសេរសារណាមួយនេះ នៅតែមានចំណុចខ្វះខាត កំហុសឆ្គង ទាំងពាក្យពេចន៍ អត្ថន័យ កើតឡើងដោយអចេតនា ត្រង់ចំណុចណាមួយ ជាក់ជាពុំខានឡើយ។ ហេតុនេះសូម លោក លោកស្រី សាស្ត្រាចារ្យ អ្នកសិក្សាស្រាវជ្រាវទាំងអស់ មេត្តា ខន្តី អភ័យទោសរាល់កំហុសខុសឆ្គងដែលកើតមានឡើង នាងខ្ញុំរង់ចាំស្វាគមន៍ជានិច្ចចំពោះការចូលរួមវាយតម្លៃ និងការរិះគន់ក្នុងន័យស្ថាបនាចំពោះខ្លឹមសារប្រធានបទមួយនេះ ដើម្បីធ្វើអោយសារណាមួយនេះមានអត្ថន័យ ខ្លឹមសារ ត្រឹមត្រូវគ្រប់គ្រាន់ សម្រាប់ឱ្យអ្នកសិក្សាគ្រប់រូប ក៏ដូចជាប្អូនៗជំនាន់ក្រោយយកទៅសិក្សាស្វែងយល់បន្ថែម។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**វិធានជាមូលដ្ឋានក្នុងការបង្កើតអាពាហ៍ពិពាហ៍**

**១.១ គោលការណ៍គ្រឹះនៃការបង្កើតអាពាហ៍ពិពាហ៍** ........ ៤

១.១.១ ការស្ម័គ្រចិត្ត ........ ៤

១.១.២ ភេទផ្ទុយគ្នា ........ ៥

១.១.៣ អាយុរបស់ភាគី ........ ៥

១.១.៤ ការហាមឃាត់មិនឱ្យមានការរៀបអាពាហ៍ពិពាហ៍ ........ ៦

១.១.៤.១ ការហាមឃាត់មិនឱ្យមានទ្វេពន្ធភាព ........ ៧

១.១.៤.២ អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មី ........ ៧

១.១.៤.៣ ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិត ........ ៨

១.១.៤.៤ ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធ ........ ៩

១.១.៤.៥ ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍តាមរយៈភ្នាក់ងាររើសគូស្រករ ........ ១០

**១.២ ទណ្ឌកម្មនៃការមិនគោរពលក្ខខណ្ឌនៃការរៀបអាពាហ៍ពិពាហ៍** ........ ១១

១.២.១ មោឃភាពនៃអាពាហ៍ពិពាហ៍ ........ ១១

១.២.២ ការលុបចោលអាពាហ៍ពិពាហ៍ ........ ១១

១.២.២.១ ការលុបចោលអាពាហ៍ពិពាហ៍ដែលមិនត្រឹមត្រូវតាមច្បាប់ ........ ១១

១.២.២.២ ការលុបចោលអាពាហ៍ពិពាហ៍ធ្វើក្នុងអំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ ពិពាហ៍ថ្មីទៀត ........ ១២

១.២.២.៣ ការលុបចោលអាពាហ៍ពិពាហ៍ដោយការឆបោក ឬការគម្រាម ........ ១៣

**ជំពូកទី២**

**បែបបទនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស**

**២.១ នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស** ........ ១៤

២.១.១ ការបំពេញបែបបទ ........ ១៤
២.១.១.១ នីតិវិធីបំពេញបែបបទនៅក្រសួងការបរទេស ........ ១៤
២.១.១.២ នីតិវិធីបំពេញបែបបទនៅក្រសួងមហាផ្ទៃ ........ ១៥
២.១.១.៣ នីតិវិធីបំពេញបែបបទនៅចំពោះមន្ត្រីអត្រានុកូលដ្ឋាន ........ ១៦
២.១.២ ការបង់កម្រៃសេវារដ្ឋបាល ........ ១៩
២.១.២.១ នៅក្រសួងការបរទេស ........ ១៩
២.១.២.២ នៅក្រសួងមហាផ្ទៃ ........ ២០
២.១.២.៣ នៅរដ្ឋបាលឃុំ សង្កាត់ ........ ២០
**២.២ អានុភាពនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស** ........ ២០
២.២.១ ចំពោះទំនាក់ទំនងបុគ្គល ........ ២០
២.២.១.១ ការបង្កើតបានជាទំនាក់ទំនងញាតិពន្ធ ........ ២០
២.២.១.២ ការបង្កើតស្ទុំកូនពេញលេញ ........ ២១
២.២.១.៣ នាមត្រកូលរបស់សហព័ទ្ធ ........ ២១
២.២.១.៤ ការទទួលបាននីតិភាព ........ ២២
២.២.១.៥ ការទទួលបានសញ្ជាតិ ........ ២២
២.២.១.៦ សិទ្ធិទទួលបានសន្តតិកម្ម ........ ២៣
២.២.២ កាតព្វកិច្ចកំណត់ដោយក្រមរដ្ឋប្បវេណី ........ ២៤
២.២.២.១ ករណីកិច្ចរួមរស់នឹងគ្នា សហការ និង សង្គ្រោះគ្នាទៅវិញទៅមក ........ ២៤
២.២.២.២ សេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ និង សិទ្ធិចូលរួមក្នុងសកម្មភាពសង្គម ........ ២៤
២.២.២.៣ ការទទួលខុសត្រូវដោយសាមគ្គីភាព ........ ២៥
**២.៣ ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ** ........ ២៥
២.៣.១ ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា ........ ២៥
២.៣.១.១ នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ........ ២៦
២.៣.១.២ អានុភាពនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ........ ២៨
២.៣.២ ប្រព័ន្ធទ្រព្យសម្បត្តិតាមច្បាប់កំណត់ ........ ២៨

២.៣.២.១ ទ្រព្យសម្បត្តិដោយឡែក ........ ២៩
២.៣.២.២ ទ្រព្យសម្បត្តិរួម ........ ៣០
**២.៤ ការគ្រប់គ្រង និង ការប្រើប្រាស់ទ្រព្យសម្បត្តិ** ........ ៣១
**២.៥ ការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ** ........ ៣២
**សេចក្តីសន្និដ្ឋាន** ........ ៣៣
**អនុសាសន៍** ........ ៣៤
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃនេះ ឃើញថាអត្រាកំណើននៃជនបរទេសដែលចូលមកដើម្បីស្នាក់នៅមានចំនួនច្រើនគួរឱ្យកត់សម្គាល់។ នៅក្នុងចំណោមជនបរទេសទាំងនោះ មានជនមួយចំនួនបានចូលមក ដើម្បីធ្វើសកម្មភាពជាអាទិ៍ ដូចជា ការចូលមកវិនិយោគ ទេសចរណ៍ និងការចូលមកប្រកបការងារផ្សេងៗ ដែលមានចម្រុះជាតិសាសន៍មកពីជុំវិញពិភពលោក។ ការណ៍នេះបានទាញជាផលប្រយោជន៍ដល់សេដ្ឋកិច្ចជាតិ និងចំណូលរបស់ពលរដ្ឋខ្មែរផងដែរ។

ទន្ទឹមនឹងនេះ ក៏សង្កេតឃើញមានជនបរទេសមួយចំនួន បានបង្កើតនូវទំនាក់ទំនងជាមួយនឹងពលរដ្ឋខ្មែរ រហូតមានចំណងអាពាហ៍ពិពាហ៍នឹងគ្នា។ ប្រជាជនទូទៅ ពុំទាន់បានយល់ច្បាស់លាស់អំពីនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសនៅឡើយនោះទេ។ នៅពេលដែលនិយាយដល់ការរៀបអាពាហ៍ពិពាហ៍ ប្រជាជនខ្មែរភាគច្រើន តែងតែនឹកឃើញដល់ការប្រារព្ធពិធីតាមបែបប្រពៃណីទំនៀមទម្លាប់ខ្មែរ រវាងបុរស និងនារី ដែលស្ម័គ្រចិត្តរួមរស់ជាមួយគ្នាជាប្តីប្រពន្ធ ជាជាងនឹកឃើញដល់ការចុះសំបុត្រអាពាហ៍ពិពាហ៍ដែលត្រូវគោរពទៅតាមនីតិវិធីច្បាប់។ រីឯជនបរទេសវិញ ពិសេសគឺជាជនបរទេសដែលនៅបណ្តាប្រទេសលោកខាងលិច គឺមិនសូវចាត់ទុកការរៀបអាពាហ៍ពិពាហ៍តាមច្បាប់ គឺមានភាពសំខាន់ឡើយ ដោយហេតុថាពួកគេចូលចិត្តរស់នៅជាមួយគ្នាតាមបែបអនីតិសង្វាស ព្រោះវាមានភាពងាយស្រួលមិនចាំបាច់គោរពនូវនីតិវិធីផ្សេងៗនាំឱ្យមានភាពស្មុគស្មាញ។ ហេតុនេះ ស្តែងឱ្យឃើញថា ការរៀបអាពាហ៍ពិពាហ៍តាមច្បាប់ គឺនៅតែជាបញ្ហាចោទនៅឡើយ ព្រោះនៅមានប្រជាជនមួយចំនួននៅមិនទាន់មានការយល់ដឹងអំពីផលអវិជ្ជមានដែលកើតឡើងតាមរយៈការរៀបអាពាហ៍ពិពាហ៍ ដែលមិនចុះបញ្ជីអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមនីតិវិធីច្បាប់នៅឡើយ។ ដោយយោងតាមច្បាប់ស្តីពីឯកពន្ធភាព ចែងថា អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឱឡារិកមួយ ធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ដែលប្តេជ្ញាថារួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួន។ អាពាហ៍ពិពាហ៍ត្រូវបានចាត់ទុកថា ជាអាពាហ៍ពិពាហ៍ ដែលស្របទៅតាមច្បាប់លុះត្រាតែអាពាហ៍ពិពាហ៍មួយនោះគោរពទៅតាមលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់។ លក្ខខណ្ឌគ្រឹះ គឺជាលក្ខខណ្ឌដាច់ខាតដែលតម្រូវដោយច្បាប់ក្នុងការរៀបអាពាហ៍ពិពាហ៍ដែលរួមមាន លក្ខខណ្ឌភេទ លក្ខខណ្ឌអាយុដែលអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍ និងលក្ខខណ្ឌទាក់ទងនឹងសមត្ថភាពរបស់គូភាគី (សមត្ថភាពខាងឆន្ទៈ ដោយស្ម័គ្រចិត្ត គ្មានការបង្ខិតបង្ខំ ឬបោកប្រាស់នោះទេ ហាមដាច់ខាតតាមរយៈភ្នាក់ងាររើសគូស្រករឈ្មួញកណ្តាល ឬការបោកបញ្ឆោត ក្នុងគោលបំណងកេងប្រវ័ញ្ចពលកម្ម ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ជាអាទិ៍) និងលក្ខខណ្ឌទាក់ទងនឹងទំនាក់ទំនងញាតិរវាងគូភាគី (ច្បាប់ហាមឃាត់មិនឱ្យមានការរៀប

អាពាហ៍ពិពាហ៍រវាងញាតិលោហិតក្នុង ៦ថ្នាក់ និងញាតិពន្ធក្នុង ៣ថ្នាក់ជាដើម)។ រីឯលក្ខខណ្ឌទម្រង់ គឺទាក់ទងនឹងនីតិវិធីច្បាប់ រួមមានការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការបំពេញបែបបទនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ការបំពេញបែបបទនៅក្រសួងមហាផ្ទៃ និងការបំពេញបែបបទនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានជាដើម។ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជាពុំមានភាពខុសគ្នាខ្លាំងពីការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរនោះទេ គឺគ្រាន់តែមាននីតិវិធីខុសគ្នាបន្តិចបន្តួចតែប៉ុណ្ណោះ។

អាស្រ័យហេតុនេះ ទើបធ្វើឱ្យនាងខ្ញុំលើកយកប្រធានបទទាក់ទងទៅនឹង "**ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស**" មកធ្វើការពន្យល់បកស្រាយ។ ដោយសារប្រធានបទនេះ មានលក្ខណៈពិសេសក្នុងការជួយកាត់បន្ថយរាល់កំហុសឆ្គង និងបញ្ហានានាដែលកើតមាននៅក្នុងការអនុវត្តជាក់ស្តែងនាពេលបច្ចុប្បន្ន ព្រមទាំងស្វែងយល់កាន់តែច្បាស់អំពីនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

តើច្បាប់នៃព្រះរាជាណាចក្រកម្ពុជា បានកំណត់លក្ខខណ្ឌអ្វីខ្លះ អំពីការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស? ដើម្បីឱ្យការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសត្រឹមត្រូវតាមច្បាប់ តើត្រូវមាននីតិវិធីយ៉ាងដូចម្តេចខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ គឺផ្តោតសំខាន់ទៅលើគោលការណ៍គ្រឹះ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសដែលបានអនុវត្តនៅក្នុងប្រទេសកម្ពុជា ព្រមទាំងដើម្បីចងក្រងជាឯកសារថ្មីមួយ សម្រាប់ជាជំនួយដល់និស្សិត និងអ្នកអានទាំងអស់ ដែលមានបំណងចង់សិក្សាស្វែងយល់អំពីការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសនៅក្នុងប្រទេសកម្ពុជា។

ពិសេសជាងនេះទៅទៀត គឺដើម្បីជាការចែករំលែកចំណេះដឹងទាំងនេះ ទៅដល់ប្រជាពលរដ្ឋទាំងអស់ឱ្យបានយល់ដឹងកាន់តែច្បាស់អំពីបញ្ហាប្រឈម និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសនៅក្នុងប្រទេសកម្ពុជាផងដែរ។

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវប្រធានបទនេះ គឺបង្ហាញអំពីគោលការណ៍នៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស នៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះ ដោយប្រធានបទទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរនិងជនបរទេសនេះ ត្រូវបានសរសេរចងក្រងឡើងដោយយោងទៅតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ច្បាប់ស្តីពីឯកពន្ធភាព ឆ្នាំ២០០៦ ព្រមទាំង

អនុក្រឹត្យស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ព្រមទាំងអនុក្រឹត្យស្តីពីអគ្រានុកូលដ្ឋានជាដើម។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ចំពោះការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ ពិតជាមានសារៈសំខាន់ណាស់ ដើម្បីជាចំណេះដឹងសម្រាប់និស្សិត សិស្សានុសិស្ស និងប្រជាពលរដ្ឋទាំងអស់ឱ្យបានយល់កាន់តែច្បាស់ទាក់ទងទៅនឹងការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស។ ម្យ៉ាងទៀត ដោយសារប្រជាពលរដ្ឋខ្មែរមួយចំនួននៅមានការយល់ដឹងតិចតួចអំពីការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ហើយពួកគាត់ពុំទាន់បានយល់ដឹងអំពីច្បាប់ដែលចែងអំពីសិទ្ធិនិងករណីកិច្ច ព្រមទាំងការហាមឃាត់មួយចំនួនទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសនេះ ជាហេតុធ្វើឱ្យអាពាហ៍ពិពាហ៍របស់ពួកគាត់ ពុំទាន់មានភាពត្រឹមត្រូវ ស្របទៅតាមគោលការណ៍ដែលច្បាប់ទទួលស្គាល់នៅឡើយ។ សារៈសំខាន់នៃប្រធានបទនេះ គឺដើម្បីបើកបង្ហាញអំពីលក្ខខណ្ឌមួយចំនួនទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ព្រមទាំងនីតិវិធីដើម្បីឱ្យការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ត្រឹមត្រូវ ស្របទៅតាមគោលការណ៍ច្បាប់ផងដែរ។

ពិសេសជាងនេះទៅទៀត គឺដើម្បីទុកជាឯកសារតម្កល់នៅបណ្ណាល័យ សម្រាប់ឱ្យនិស្សិត អ្នកសិក្សាស្រាវជ្រាវទាំងអស់ បានសិក្សាស្វែងយល់បន្ថែមឱ្យបានជាប្រយោជន៍ ដើម្បីទទួលបាននូវចំណេះដឹងថ្មីៗ ព្រមទាំងចូលរួមចំណែកក្នុងការអភិវឌ្ឍប្រព័ន្ធច្បាប់នៅព្រះរាជាណាចក្រកម្ពុជាឱ្យកាន់តែល្អប្រសើរឡើង។

## ៦. វិធីសាស្ត្រនៃស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពីការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស គឺនាងខ្ញុំបានធ្វើការស្រាវជ្រាវ ស្វែងរកឯកសារដែលពាក់ព័ន្ធនានា នៅក្នុងបណ្ណាល័យនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច តាមរយៈប្រព័ន្ធអ៊ីនធើណែត ឯកសារមេរៀនដែលនាងខ្ញុំទទួលបានពីលោកគ្រូ អ្នកគ្រូដែលបានបង្រៀនផ្នែកនីតិសាស្ត្ររយៈពេល៤ឆ្នាំ ជាពិសេសច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលមានចែងជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងមានការជួយពន្យល់ណែនាំបន្ថែមពីលោកសាស្ត្រាចារ្យ **ហ៊ីង គឹមឡេង** ផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងការស្រាវជ្រាវប្រធានបទនេះ នាងខ្ញុំបានបែងចែកជា ២ ជំពូកធំៗ គឺ

ជំពូកទី១ បង្ហាញអំពី វិធានជាមូលដ្ឋានក្នុងការបង្កើតអាពាហ៍ពិពាហ៍។

ជំពូកទី២ បែបបទនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស។

ចំពោះខ្លឹមសារលម្អិតទាំងស្រុងនៃប្រធានបទនេះ នាងខ្ញុំនឹងធ្វើការពន្យល់បកស្រាយដូចខាងក្រោម៖

# ជំពូកទី១
# វិធានជាមូលដ្ឋានក្នុងការ
# បង្កើតអាពាហ៍ពិពាហ៍

# ជំពូកទី១

# វិធានជាមូលដ្ឋានក្នុងការបង្កើតអាពាហ៍ពិពាហ៍

## ១.១ គោលការណ៍គ្រឹះនៃការបង្កើតអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឧឡារិកមួយធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ ដែលប្ដេជ្ញាថារួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួន[1] ។ អាពាហ៍ពិពាហ៍ មានភាពសំខាន់ណាស់នៅក្នុងជីវិតរបស់មនុស្សម្នាក់ៗ។ អាពាហ៍ពិពាហ៍ អាចមានអានុភាពពេញលក្ខណៈតាមច្បាប់បាន លុះត្រាតែអាពាហ៍ពិពាហ៍នោះ ធ្វើឡើងស្របតាមក្បួនខ្នាត និងមិនត្រូវមានការបង្ខិតបង្ខំទៅលើភាគីណាម្ខាងនោះទេ ហេតុនេះហើយទើបច្បាប់បានបញ្ញត្តិ និងកំណត់យ៉ាងច្បាស់លាស់ពោលគឺត្រូវតែគោរពយ៉ាងខ្ជាប់ខ្ជួនទៅតាមគោលការណ៍ច្បាប់ ដូចដែលមានចែងនៅក្នុងបទដ្ឋានគតិយុត្ត។

### ១.១.១ ការស្ម័គ្រចិត្ត

ចំពោះការរៀបអាពាហ៍ពិពាហ៍មួយដែលអាចប្រព្រឹត្តទៅបាន លុះត្រាតែមានការយល់ព្រមដោយស្ម័គ្រចិត្តពីគូភាគីទាំងសងខាងជាមុនសិន។ បើយោងទៅតាម រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា មាត្រា៤៥ បានចែងថា អាពាហ៍ពិពាហ៍ ត្រូវធ្វើតាមល័ក្ខខ័ណ្ឌ ដែលមានចែងនៅក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្តប្ដីមួយប្រពន្ធមួយ[2]។ មួយវិញទៀតបើផ្អែកទៅតាម មាត្រា២ នៃអនុក្រឹត្យស្ដីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស គឺ ត្រូវផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត និងឆន្ទៈផ្ទាល់របស់សាមីខ្លួន និងត្រូវអនុវត្តតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនានា នៃព្រះរាជាណាចក្រកម្ពុជា[3]។ ដូចគ្នានេះដែរ ដោយយោងទៅតាម កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងពិធីសារបន្ថែម ត្រង់មាត្រា២៣ ចំណុចទី៣ បានចែងថា គ្មានអាពាហ៍ពិពាហ៍ណាអាចធ្វើឡើងដោយគ្មានការយល់ព្រមដោយសេរី និងពេញលេញពីអនាគតប្ដី ប្រពន្ធឡើយ[4]។ តាមរយៈការបកស្រាយខាងលើ សបញ្ជាក់ឱ្យឃើញថា នៅក្នុងទំនាក់ទំនងអាពាហ៍ពិពាហ៍ គឺពុំអាចមានការបង្ខិតបង្ខំទៅលើភាគីណាមួយឱ្យរៀបអាពាហ៍ពិពាហ៍ ដោយមិនបានកើតចេញពីមនោសញ្ចេតនាស្នេហារវាងចិត្តនិងចិត្ត ឬអាចហៅម្យ៉ាងទៀតបានថា ជាឆន្ទៈរបស់បុគ្គលក្នុងការព្រមព្រៀង ថានឹងយល់ព្រមរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានោះទេ ក្នុងករណីបើមានការបង្ខិតបង្ខំណាមួយកើតឡើង សកម្មភាពនោះគឺវាផ្ទុយទៅនឹងច្បាប់ជាតិ និងច្បាប់អន្តរជាតិទាំងស្រុងតែម្ដង។

[1] មាត្រា៣ នៃច្បាប់ស្ដីពីឯកពន្ធភាព

[2] មាត្រា៤៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

[3] មាត្រា២ នៃអនុក្រឹត្យស្ដីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ឆ្នាំ២០០៨

[4] មាត្រា២៣ ចំណុចទី៣ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងពិធីសារបន្ថែម ឆ្នាំ២០០៩

### ១.១.២ ភេទផ្ទុយគ្នា

យើងអាចក្រឡេកទៅមើលការរៀបអាពាហ៍ពិពាហ៍តាំងពីបុរាណកាលមកដល់បច្ចុប្បន្នបើតាមប្រពៃណីទំនៀមទម្លាប់ដ៏ផូរផង់របស់ប្រទេសខ្មែរយើង ចំពោះការរៀបអាពាហ៍ពិពាហ៍មួយអាចប្រព្រឹត្តទៅបាន លុះណាតែភាគីទាំងសងខាង មានម្នាក់ជាបុរស និងម្នាក់ទៀតជានារី តែប៉ុណ្ណោះ ទើបការរៀបអាពាហ៍ពិពាហ៍មួយនេះត្រឹមត្រូវតាមក្បួនខ្នាត និងច្បាប់ធម្មជាតិ ក្នុងករណីដែលបុគ្គលដែលរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ហើយមានភេទដូចគ្នានោះ វាផ្ទុយនឹងក្រឹត្យក្រមរបស់ធម្មជាតិ គឺមិនអាចបង្កើតកូនបន្តជាពូជពង្សវង្សត្រកូលបាននោះទេ។ ជាក់ស្តែងនៅក្នុងមាត្រា៤៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលជាច្បាប់កំពូលនៃប្រទេសយើងបានចែងយ៉ាងជាក់លាក់ថា អាពាហ៍ពិពាហ៍ ត្រូវធ្វើតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្ត ប្តីមួយប្រពន្ធមួយ[5]។ ដូចគ្នានេះដែរ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានបញ្ជាក់យ៉ាងច្បាស់ត្រង់មាត្រា៩៤៨ បានបញ្ញត្តិថា បុរស និងនារី ដែលមិនទាន់ដល់នីតិភាពមិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ[6]។ ត្រង់ចំណុចនេះយើងអាចបញ្ជាក់បានថា មានតែបុគ្គលដែលមានភេទផ្ទុយគ្នាតែប៉ុណ្ណោះ ទើបអាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានហើយទើបសង្គមយើងបច្ចុប្បន្នទទួលស្គាល់និងឱ្យតម្លៃ ប៉ុន្តែករណីដែលមានភេទដូចគ្នារៀបអាពាហ៍ពិពាហ៍ គឺសង្គមយើងបច្ចុប្បន្នពុំមានការទទួលស្គាល់ថាត្រឹមត្រូវនៃល័ក្ខខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍នោះទេ។

### ១.១.៣ អាយុរបស់ភាគី

នៅក្នុងការរៀបអាពាហ៍ពិពាហ៍ អាយុ គឺជាចំណុចសំខាន់ដែលអាចឱ្យអាពាហ៍ពិពាហ៍នោះ ប្រព្រឹត្តទៅស្របតាមច្បាប់។ បើយើងក្រឡេកមកមើលប្រទេសកម្ពុជាវិញ ការរៀបអាពាហ៍ពិពាហ៍ ក៏ត្រូវបានកំណត់អំពីអាយុផងដែរ។ ជាគោលការណ៍ បុគ្គលដែលអាចរៀបអាពាហ៍ពិពាហ៍បាន លុះត្រាតែបុគ្គលនោះជានីតិជន។ នីតិជន សំដៅលើជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ[7]។ ជាក់ស្តែងនៅក្នុងមាត្រា ៩៤៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានកំណត់អំពីអាយុគ្រប់លក្ខណៈរៀបអាពាហ៍ពិពាហ៍ ដោយចែងថា បុរស និងនារី ដែលមិនទាន់ដល់នីតិភាព មិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ[8]។ មានន័យថា ទាល់តែបុរស និងនារីដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍នោះ មានអាយុ ១៨ឆ្នាំ ទើបគ្រប់លក្ខណៈអាចរៀបអាពាហ៍ពិពាហ៍ ស្របតាមច្បាប់កំណត់។ ចំពោះបុគ្គលដែលជាអនីតិជនវិញ ច្បាប់មិនអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍បានឡើយ។

[5] មាត្រា៤៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

[6] មាត្រា៩៤៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[7] សន្ទានុក្រមផ្នែករដ្ឋប្បវេណី

[8] មាត្រា៩៤៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

អនីតិជន សំដៅទៅលើ ជនដែលមានអាយុក្រោម១៨ឆ្នាំ[9]។ ប៉ុន្តែ ក៏មានករណីពិសេស ដែលច្បាប់អនុញ្ញាតឱ្យអនីតិជនអាចរៀបអាពាហ៍ពិពាហ៍បានដែរ។ ក្នុងករណីដែលភាគីម្ខាង បានដល់នីតិភាព ហើយភាគីម្ខាងទៀតជាអនីតិជនដែលមានអាយុមិនតិចជាង ១៦ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍បាន ដោយទទួលការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់អនីតិជននោះ[10]។ ប្រសិនបើអនីតិជនបានរៀបអាពាហ៍ពិពាហ៍ អនីតិជននោះត្រូវបានចាត់ទុកថា បានដល់នីតិភាពដោយអាពាហ៍ពិពាហ៍នោះ[11]។ លើសពីនេះទៅទៀត ក្នុងករណីដែលអនីតិជនដែលបានដល់អាយុ ១៦ឆ្នាំ ហើយទទួលបានអត្តាធីនភាព[12] អនីតិជននោះ ក៏អាចរៀបអាពាហ៍ពិពាហ៍បានដែរ។

ម្យ៉ាងទៀត ប្រសិនបើអនីតិជន ដែលពុំទាន់គ្រប់អាយុរៀបអាពាហ៍ពិពាហ៍ តែមានបំណងចង់រៀបអាពាហ៍ពិពាហ៍ គឺអាចរៀបអាពាហ៍ពិពាហ៍បាន ដោយគ្រាន់តែមានការយល់ព្រមពីសំណាក់អ្នកដែលមានអំណាចមេបា ឬ អាណាព្យាបាលសម្រាប់អនីតិជននោះ ប៉ុន្តែក្នុងករណីអ្នកដែលមានអំណាចមេបាម្ខាងមិនយល់ព្រមឱ្យរៀបអាពាហ៍ពិពាហ៍ ក៏នៅតែអាចរៀបអាពាហ៍ពិពាហ៍បាន ដោយគ្រាន់តែមានការយល់ព្រមពីសំណាក់អ្នកដែលមានអំណាចមេបាម្ខាងទៀតជាការស្រេច។

ផ្ទុយមកវិញ ប្រសិនបើអ្នកមានអំណាចមេបា ឬ អាណាព្យាបាលសម្រាប់អនីតិជនបដិសេធការយល់ព្រមដោយគ្មានមូលហេតុសមរម្យ អនីតិជនដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ អាចទាមទារទៅតុលាការឱ្យសម្រេចសេចក្តីជំនួសការយល់ព្រមនោះបាន[13]។

### ១.១.៤ ការហាមឃាត់មិនឱ្យមានការរៀបអាពាហ៍ពិពាហ៍

ចំពោះអាពាហ៍ពិពាហ៍មួយដែលអាចប្រព្រឹត្តទៅបាន លុះត្រាតែមានការយល់ព្រមពីភាគីទាំងសងខាងជាមុនសិន ដូចបានបកស្រាយចាប់ពីចំណុច ១.១ (គោលការណ៍គ្រឹះនៃការបង្កើតអាពាហ៍ពិពាហ៍) ខាងលើនេះ។

ទោះជាយ៉ាងនេះក្តី ស្ថិតក្នុងកាលៈទេសៈមួយ ដែលភាគីទាំងសងខាងយល់ព្រមថានឹងរៀបអាពាហ៍ពិពាហ៍ដោយស្ម័គ្រចិត្តជាមួយគ្នាក៏ដោយ ក៏ច្បាប់នៅតែមានចំណុចមួយចំនួនដែលត្រូវបានហាមឃាត់ពុំឱ្យមានការរៀបអាពាហ៍ពិពាហ៍កើតឡើងដែរ ប្រសិនបើភាគីទាំងសងខាង ឬភាគីណាម្ខាងបានធ្វើខុសនឹងលក្ខខណ្ឌដែលច្បាប់បានបញ្ញត្តិទុកមួយចំនួនដូចខាងក្រោម៖

---

[9] មាត្រា១៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[10] មាត្រា៩៤៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[11] មាត្រា៩៦៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[12] អត្តាធីនភាព គឺជាស្ថានភាពមួយដែលផ្តល់ឱ្យអនីតិជនបានរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬរួចផុតពីអំណាចមេបា ហើយមានសមត្ថភាពដូចនីតិជនដែរ។

[13] មាត្រា៩៥៣ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

### ១.១.៤.១ ការហាមឃាត់មិនឱ្យមានទ្វេពន្ធភាព

ទ្វេពន្ធភាព សំដៅទៅលើភាពនៃបុគ្គលម្នាក់ដែលពុំទាន់រំលាយចំណងអាពាហ៍ពិពាហ៍មុនផង ហើយបានទៅរៀបអាពាហ៍ពិពាហ៍ថ្មីមួយទៀតឬភាពមានប្រពន្ធពីរឬប្តីពីរ[14]។ម្យ៉ាងទៀតនៅក្នុងច្បាប់ស្តីពីឯកពន្ធភាព ឆ្នាំ២០០៦ បានកំណត់និយមន័យ ទ្វេពន្ធភាព ថា ជាចំណងអាពាហ៍ពិពាហ៍ដែលបុរសមានប្រពន្ធពីរ ឯស្ត្រីមានប្តីពីរ ហើយត្រូវបានចាត់ទុកថាមានពិរុទ្ធភាពក្នុងបទទ្វេពន្ធភាព បើបុរស និងស្ត្រីណាដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយនៅឡើយ ហើយបានទៅចុះបញ្ជីអាពាហ៍ពិពាហ៍ថ្មីមួយទៀត[15]។ ដូចគ្នានេះដែរ នៅក្នុងរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់ប្រទេសកម្ពុជាយើង ក៏បានចែងពាក់ព័ន្ធនឹងគោលការណ៍ឯកពន្ធភាពនៃការរៀបអាពាហ៍ពិពាហ៍ផងដែរ ដែលត្រូវបានកំណត់នៅក្នុងមាត្រា៤៥ កថាខណ្ឌទី៤ ដោយមាត្រានេះ បានបញ្ញត្តិថា អាពាហ៍ពិពាហ៍ ត្រូវធ្វើតាមលក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្ត ប្តីមួយប្រពន្ធមួយ[16]។ ជាក់ស្តែងប្រទេសកម្ពុជាយើងបានប្រកាន់យក របបឯកពន្ធភាពដែលនាំឱ្យមានការហាមឃាត់មិនឱ្យមានការរៀបអាពាហ៍ពិពាហ៍ដែលមានភាពជាន់គ្នា ត្រង់ចំណុចនេះមានន័យថា ភាគីដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ មិនថាជាភាគីខាងបុរស ឬជាភាគីខាងនារីនោះទេ ប្រសិនបើធ្លាប់បានរៀបអាពាហ៍ពិពាហ៍រួចហើយ មិនអាចរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបាននោះទេ លើកលែងតែក្នុងករណីមានការលែងលះ ឬសហព័ទ្ធណាម្ខាងបានទទួលមរណភាព។ គួរបញ្ជាក់ផងដែរថា ចំពោះអាពាហ៍ពិពាហ៍មួយត្រូវបានរំលាយ លុះត្រាតែស្ថិតក្នុងករណីណាមួយដែលច្បាប់បានកំណត់រួមមាន ទី១ សហព័ទ្ធណាមួយបានស្លាប់ ទី២ មានសេចក្តីសម្រេចរំលាយចំណងអាពាហ៍ពិពាហ៍ជាស្ថាពររបស់តុលាការ និងទី៣ សហព័ទ្ធណាម្នាក់បាត់ខ្លួនហួសពីមួយឆ្នាំ ដោយគ្មានដំណឹងអ្វីសោះ មិនដឹងថាស្លាប់ ឬ រស់[17]។

### ១.១.៤.២ អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មី

ជាទូទៅ ចំពោះអាពាហ៍ពិពាហ៍មួយ ប្រសិនបើបានរំលាយហើយ ឬមួយក៏ភាគីខាងបុរសទទួលមរណៈភាព ក្នុងករណីនេះច្បាប់បានកំណត់យ៉ាងច្បាស់ថា នារី គឺពុំអាចរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបានភ្លាមៗនោះឡើយ កាលណាបើអំឡុងពេល ១២០ថ្ងៃ ពុំទាន់បានកន្លងផុត គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍មុន ត្រូវបានរលាយ ឬ លុបចោល[18]។ មានន័យថា ករណីដែលនារីទើបតែរំលាយអាពាហ៍ពិពាហ៍មុនរួច ពុំអាចរៀបអាពាហ៍ពិពាហ៍បានភ្លាមនោះទេ លុះត្រាតែរង់ចាំរហូតដល់ផុតរយៈពេល ១២០ថ្ងៃសិន ទើបអាចរៀបអាពាហ៍ពិពាហ៍ថ្មី

---

14 សន្ធានុក្រមផ្នែករដ្ឋប្បវេណីឆ្នាំ២០០៧

15 មាត្រា៤ នៃច្បាប់ស្តីពីឯកពន្ធភាព ឆ្នាំ២០០៦

16 មាត្រា៤៥ កថាខណ្ឌទី៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

17 មាត្រា៣ កថាខណ្ឌទី២ នៃច្បាប់ស្តីពីឯកពន្ធភាព ឆ្នាំ២០០៦

18 មាត្រា៩៥០ កថាខណ្ឌទី១ នៃរដ្ឋប្បវេណីឆ្នាំ២០០៧

បាន។ អំឡុងពេលហាមឃាត់ការរៀបអាពាហ៍ពិពាហ៍ថ្មី គឺដើម្បីសន្មតបិតុភាពរបស់កូន ដែលមានន័យថា កូនដែលកើតមកត្រូវជាកូនរបស់ប្ដីដែលរៀបអាពាហ៍ពិពាហ៍មុន ឬ ជាកូនរបស់ប្ដីដែលរៀបអាពាហ៍ពិពាហ៍ក្រោយ។ ប៉ុន្តែចំពោះករណីដែលនារីមានផ្ទៃពោះនៅមុនពេលដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬលុបចោល ហើយបានសម្រាលកូន ឬ ចំពោះករណីដែលមានលិខិតបញ្ជាក់ពីការគ្មានផ្ទៃពោះពីវេជ្ជបណ្ឌិតរួចហើយ នារីនោះអាចរៀបអាពាហ៍ពិពាហ៍ថ្មីបាន ដោយមិនចាំបាច់រង់ចាំរយៈពេល ១២០ថ្ងៃ បន្ទាប់ពីអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬលុបចោលនោះទេ[19]។

### ១.១.៤.៣ ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិត

ជាទូទៅ ភាគីទាំងសងខាង ទាំងបុរស និងនារី ដែលជាភាគីនៃអាពាហ៍ពិពាហ៍ ទោះបីជាដល់នីតិភាពហើយក៏ដោយ និងបានព្រមព្រៀងបង្ហាញឆន្ទៈថានឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាក៏ដោយ ប៉ុន្តែទោះបីជាបែបនេះក៏ដោយ អាពាហ៍ពិពាហ៍ក៏ពុំអាចកើតមានឡើងបានដែរ ប្រសិនបើភាគីទាំងសងខាងជាញាតិលោហិតខ្សែផ្ទាល់ ឬ សាខាញាតិនឹងគ្នា។ អាពាហ៍ពិពាហ៍មួយ មិនអាចធ្វើបានឡើយ រវាងញាតិលោហិតផ្ទាល់ ឬសាខាញាតិលោហិតក្នុង ៣ថ្នាក់ រាប់ទាំងថ្នាក់ទី ៣ផង[20]។

ដូចគ្នានេះដែរ ចំពោះអត្ថន័យនៃពាក្យ ញាតិលោហិត នៅក្នុងសន្ទានុក្រមផ្នែករដ្ឋប្បវេណីបានឱ្យនិយមន័យថា ជាញាតិដែលមានឈាមជ័រជាមួយគ្នា ដូចជា ឪពុក និងកូន ឬម្ដាយ និងកូនជាដើម[21]។ រីឯពាក្យថា ញាតិលោហិតខ្សែផ្ទាល់ គឺជាញាតិដែលមានឈាមជ័រជាមួយគ្នា ហើយកើតតគ្នាពីមួយទៅមួយតាមលំដាប់ គឺ ឪពុក ម្ដាយ កូន ចៅ ចៅទួត[22]។

ចំពោះការហាមឃាត់មិនឱ្យមានការរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិតនេះ ដោយហេតុថា វាមានផលប៉ះពាល់ទាក់ទងនឹងសីលធម៌សង្គម ព្រោះការរៀបអាពាហ៍ពិពាហ៍បែបនេះគឺពុំមានភាពសមរម្យឡើយ មួយវិញទៀតបើផ្អែកតាមវិទ្យាសាស្ត្រ បានឱ្យដឹងថា ការរួមរស់ជាមួយគ្នារវាងញាតិលោហិតសាច់ឯង ប្រសិនបើមានកូន ករណីនេះ កូនដែលកើតមកអាចនឹងមានសុខភាពមិនល្អ ចុះខ្សោយផ្នែកបញ្ញាស្មារតីថែមទៀតផង ហេតុនេះហើយទើបច្បាប់បានធ្វើការហាមឃាត់មិនឱ្យមានការរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិត។

ដោយឡែកប្រសិនបើនៅក្រោយពេលដែលទំនាក់ទំនងញាតិត្រូវបានបញ្ចប់ ដោយការបញ្ចប់នូវញាតិភាពជាមួយនឹងឪពុកម្ដាយបង្កើត និងការកាត់កាល់នៃសុំកូនពេញលេញក៏ដោយ ប៉ុន្តែចំពោះទំនាក់ទំនងផ្នែកតាមធម្មជាតិ ក៏ពុំត្រូវបានបញ្ចប់ ឬកាត់ផ្ដាច់នោះដែរ ជារួមក៏ច្បាប់នូវតែធ្វើការហាមឃាត់មិនឱ្យមានការរៀប

[19] មាត្រា ៩៥០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[20] មាត្រា ៩៥១ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[21] សន្ទានុក្រមផ្នែករដ្ឋប្បវេណីឆ្នាំ២០០៧

[22] សន្ទានុក្រមផ្នែករដ្ឋប្បវេណីឆ្នាំ២០០៧

អាពាហ៍ពិពាហ៍ចំពោះខ្សែលោហិតនេះដដែល។ គួរបញ្ជាក់ផងដែរថា ការរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិត អាចបណ្តាលឱ្យមានពន្ធុខ្សោយជាប់គ្នាជាតំណ ហើយលទ្ធភាពនៃពិការភាពចំពោះកូនដែលកើតមកមានកម្រិតខ្ពស់។

### ១.១.៤.៤ ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធ

ញាតិពន្ធ គឺជាចំណងគតិយុត្តរវាងសហព័ទ្ធម្ខាង និងញាតិលោហិតរបស់សហព័ទ្ធម្ខាងទៀត ឬហៅថាសាច់ថ្លៃ[23] ។ ការរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធនៃខ្សែផ្ទាល់[24] និងរវាងជនដែលធ្លាប់ជាញាតិពន្ធ ត្រូវបានហាមឃាត់ ដោយសារញាតិលោហិតនៃខ្សែផ្ទាល់របស់សហព័ទ្ធ មានទំនាក់ទំនងប្រហាក់ប្រហែលគ្នាទៅនឹងញាតិលោហិតខ្សែផ្ទាល់របស់ខ្លួនផ្ទាល់ ដែលស្រដៀងគ្នាទៅនឹងទំនាក់ទំនងឪពុកម្តាយ និងកូន ដូច្នេះ តាមសីលធម៌សង្គម ការរៀបអាពាហ៍ពិពាហ៍បែបនេះ ក៏ពុំមានភាពសមរម្យ ឬជាការគួរដែរ[25]។

ម៉្យាងវិញទៀត ទោះបីជាសាខាញាតិក្នុង៣ថ្នាក់ ដោយរាប់ទាំងថ្នាក់ទី៣ផងដែរក៏ដោយ ក៏អាពាហ៍ពិពាហ៍រវាងបុគ្គលទាំងនោះត្រូវបានហាមឃាត់ដែរ ដោយសារតែនៅក្នុងសង្គមកម្ពុជា សាខាញាតិពន្ធនេះមាននិន្នាការបង្កើតទំនាក់ទំនងញាតិជារួម ដែលមានលក្ខណៈជិតស្និតស្រដៀងគ្នាទៅនឹងញាតិលោហិតខ្សែផ្ទាល់ និងសាខាញាតិលោហិតដែរ។

ប៉ុន្តែដោយសារតែទំនៀមទម្លាប់នៅក្នុងប្រទេសកម្ពុជា មានករណីអាពាហ៍ពិពាហ៍ជាមួយបងប្អូនថ្លៃ ដូចជាក្នុងករណីដែលប្តីទទួលមរណៈភាពទៅ ហើយប្រពន្ធបានទៅរៀបអាពាហ៍ពិពាហ៍ជាមួយបង ឬ ប្អូនប្រុសដែលនៅលីវរបស់សពប្តី ឬករណីដែលប្រពន្ធទទួលមរណៈភាពហើយប្អូនស្រី ឬបងស្រីរបស់សពប្រពន្ធទៅរៀបអាពាហ៍ពិពាហ៍ជាមួយប្តី ដើម្បីមើលថែកូនរបស់បុគ្គលដែលទទួលមរណៈភាពនោះជាដើម[26]។

ជាក់ស្តែង នៅក្នុងសង្គមខ្មែរបច្ចុប្បន្ន អាពាហ៍ពិពាហ៍រវាងបងប្អូនបង្កើតរបស់ប្តី និងបងប្អូនបង្កើតរបស់ប្រពន្ធ ក៏ឃើញកើតមានផងដែរ ទើបមាត្រា ៩៥២ កថាខណ្ឌទី២ ត្រូវបានបញ្ញត្តិឡើងថា បើសហព័ទ្ធណាម្ខាងបានទទួលមរណៈភាព សហព័ទ្ធដែលនៅរស់អាចរៀបអាពាហ៍ពិពាហ៍ជាមួយបុគ្គលដែលធ្លាប់ជាសាខាញាតិពន្ធនៅក្នុង ៣ថ្នាក់បាន[27]។

---

[23] សន្ទានុក្រមផ្នែករដ្ឋប្បវេណីឆ្នាំ២០០៧

[24] ញាតិពន្ធខ្សែផ្ទាល់ ជាញាតិលោហិតផ្ទាល់ខាងសាច់ថ្លៃ ដែលកើតពីមួយទៅមួយតាមលំដាប់ដូចជា ជីដូនជីតាក្មេក ឪពុក ម្តាយក្មេក កូនបង្កើតរបស់សហព័ទ្ធម្ខាងទៀត

[25] សេចក្តីកំណត់មាត្រា៩៥២ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០១០

[26] សេចក្តីកំណត់មាត្រា៩៥២ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០១០

[27] មាត្រា ៩៥២ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

### ១.១.៤.៥ ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍តាមរយៈភ្នាក់ងារជ្រើសរើសគូស្រករ

បានជាមានការហាមឃាត់ចំពោះការរៀបអាពាហ៍ពិពាហ៍ ដែលធ្វើឡើងតាមរយៈភ្នាក់ងារជ្រើសរើសគូស្រករ ព្រោះប្រសិនបើប្រជាជនខ្មែរយើងរៀបអាពាហ៍ពិពាហ៍បែបនេះជាមួយជនបរទេស គឺហានិភ័យមានភាគរយខ្ពស់ណាស់ក្នុងការចាញ់បោក ឬគេងបន្លំរបស់មេខ្យល់មួយចំនួន ក្នុងគោលបំណងបង្កើតនូវចំណងអាពាហ៍ពិពាហ៍ក្លែងក្លាយរវាងពលរដ្ឋខ្មែរ និងជនបរទេស ដើម្បីធានាឱ្យសាមីខ្លួនដែលជាជនជាតិខ្មែរអាចទៅរស់នៅស្រុកកំណើត ឬប្រទេសរបស់សហព័ទ្ធខ្លួនដែលជាជនបរទេសបាន បន្ទាប់មកនឹងធ្វើការលែងលះគ្នាព្រោះការរៀបអាពាហ៍ពិពាហ៍នោះ គឺក្នុងគោលបំណងដើម្បីទទួលបានសញ្ជាតិ និងរស់នៅប្រកបអាជីវកម្មផ្សេងៗតែប៉ុណ្ណោះ។ ដោយហេតុថាច្បាប់ធ្វើការហាមឃាត់មិនឱ្យមានការរៀបអាពាហ៍ពិពាហ៍នេះ គឺដើម្បីការពារប្រជាពលរដ្ឋខ្មែរ ពីករណីឆបោកផ្សេងៗ។

ដូចនេះ ច្បាប់បានហាមឃាត់ចំពោះជនណាដែលលក់ដូរជនដទៃ ដោយមានគោលដៅស្វែងរកប្រយោជន៍ ឈ្លានពានខាងផ្លូវភេទ ផលិតរូបភាពអាសអាភាស រៀបអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ សុំកូន ឬទម្រង់នៃការកេងប្រវ័ញ្ចផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ឆ្នាំ ដល់ ១៥ឆ្នាំ។ម្យ៉ាងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ឆ្នាំ ដល់ ២០ឆ្នាំ ក្នុងករណីដែលជនរងគ្រោះជាអនីតិជន ឬ អំពើល្មើសប្រព្រឹត្តឡើងដោយមន្ត្រីសាធារណៈដែលបំពានដោយអំណាចរបស់ខ្លួនមកលើជនរងគ្រោះ ឬ អំពើល្មើសប្រព្រឹត្តឡើងដោយក្រុមមានការចាត់តាំង[28]។

ជាក់ស្តែងកន្លងមក យើងសង្កេតឃើញថា មានស្ត្រីរងគ្រោះជាច្រើននាក់ដែលត្រូវបានជនបរទេស ឬមេខ្យល់ បោកបញ្ឆោត និងយកទៅប្រទេសរបស់ខ្លួនហើយបង្ខំឱ្យធ្វើអ្វីដែលមិនស្របទៅនឹងឆន្ទៈ ឬការព្រមព្រៀងរបស់ជនរងគ្រោះ និងពេលខ្លះអាចឈានទៅដល់ការជួញដូរផ្លូវភេទស្ត្រីថែមទៀតផង។

ដូច្នេះហើយ ទើបរាជរដ្ឋាភិបាលដែលជាថ្នាក់ដឹកនាំរបស់ប្រទេសកម្ពុជាយើង បានឯកភាព និងព្រមចុះហត្ថលេខាលើអនុក្រឹត្យស្តីពី ការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសដែលមានបញ្ញត្តិថាត្រូវបានហាមឃាត់ដាច់ខាត ចំពោះអាពាហ៍ពិពាហ៍ ដែលធ្វើឡើងតាមរយៈភ្នាក់ងារជ្រើសរើសគូស្រករ ឈ្មួញកណ្តាល ឬ ក្រុមហ៊ុនអាជីវកម្ម[29]។ករណីមួយទៀត គឺត្រូវបានហាមឃាត់ដាច់ខាតចំពោះអាពាហ៍ពិពាហ៍ក្លែងក្លាយ បោកបញ្ឆោត ក្នុងគោលបំណងកេងប្រវ័ញ្ចពលកម្ម ជួញដូរមនុស្ស ឬធ្វើអាជីវកម្មផ្លូវភេទ[30]។

---

[28] មាត្រា ១៥ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ

[29] មាត្រា៣ នៃអនុក្រឹត្យស្តីពី ការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

[30] មាត្រា៤ នៃអនុក្រឹត្យស្តីពី ការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

## ១.២ ទណ្ឌកម្មនៃការមិនគោរពលក្ខខណ្ឌនៃការរៀបអាពាហ៍ពិពាហ៍

### ១.២.១ មោឃភាពនៃអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍នឹងត្រូវចាត់ទុកជាមោឃៈ ប្រសិនបើគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍រវាងភាគី ដោយសារការភាន់ច្រឡំលើមនុស្ស ការបង្ខំ និងមូលហេតុផ្សេងទៀត[31]។ មានន័យថា ប្រសិនបើភាគីណាម្ខាងមិនមានឆន្ទៈក្នុងការរៀបអាពាហ៍ពិពាហ៍ ឬមួយឆន្ទៈនោះ កើតចេញពីការបង្ខិតបង្ខំ ពីសំណាក់ឪពុកម្តាយ ឬអាណាព្យាបាល ឬតតិយជនណាមួយ នាំឱ្យអាពាហ៍ពិពាហ៍នោះនឹងត្រូវមោឃភាព ដោយសារអាពាហ៍ពិពាហ៍នោះ កើតឡើងផ្ទុយពីឆន្ទៈពិតរបស់បុគ្គល។ ម្យ៉ាងទៀត អាពាហ៍ពិពាហ៍ក៏ត្រូវទទួលរងមោឃភាពផងដែរ ប្រសិនបើមានការភាន់ច្រឡំលើបុគ្គលដែលមានមុខដូចគ្នា (បងប្អូនភ្លោះ) ជាដើម។ មួយវិញទៀត អាពាហ៍ពិពាហ៍ក៏ត្រូវចាត់ទុកជាមោឃៈផងដែរ ប្រសិនបើភាគីមិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ឬមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ ។ ប៉ុន្តែប្រសិនបើគ្រាន់តែមានវិការៈតែបន្តិចបន្តួចលើនីតិវិធី ដូចជាការសរសេរខុសអក្ខរាវិរុទ្ធ ឬខុសថ្ងៃខែឆ្នាំកំណើតរបស់ភាគី នោះអាពាហ៍ពិពាហ៍នៅតែមានអានុភាពដដែល[32]។

### ១.២.២ ការលុបចោលអាពាហ៍ពិពាហ៍

ការលុបចោលអាពាហ៍ពិពាហ៍ គឺជាការប្រកាសទណ្ឌកម្មដែលលុបចោលអានុភាពនៃអាពាហ៍ពិពាហ៍ឆ្ពោះទៅពេលអនាគត ហើយអាពាហ៍ពិពាហ៍នោះ មិនមានអានុភាពដែលត្រូវបានច្បាប់ទទួលស្គាល់នោះទេ។ អាពាហ៍ពិពាហ៍ នឹងត្រូវបានលុបចោល ប្រសិនបើមានមូលហេតុណាមួយដែលត្រូវបានកំណត់ក្នុងច្បាប់ ដែលមូលហេតុទាំងនោះមានដូចជា ការលុបចោលអាពាហ៍ពិពាហ៍ដែលមិនត្រឹមត្រូវតាមច្បាប់ (១.២.២.១) ការលុបចោលអាពាហ៍ពិពាហ៍ធ្វើនៅក្នុងអំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត (១.២.២.២) ការលុបចោលអាពាហ៍ពិពាហ៍ដោយការឆបោក ឬការគម្រាម (១.២.២.៣)។

#### ១.២.២.១ ការលុបចោលអាពាហ៍ពិពាហ៍ដែលមិនត្រឹមត្រូវតាមច្បាប់

អាពាហ៍ពិពាហ៍នឹងត្រូវបានលុបចោល ប្រសិនបើអាពាហ៍ពិពាហ៍នោះ មិនគោរពតាមបញ្ញត្តិច្បាប់ ឬលក្ខខណ្ឌមួយចំនួននៃការរៀបអាពាហ៍ពិពាហ៍។ ប្រសិនបើអាពាហ៍ពិពាហ៍ដែលបានធ្វើផ្ទុយនឹងបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ភាគីនីមួយៗ ញាតិសន្តានរបស់ជននោះ ឬតំណាងអយ្យការ អាចទាមទារទៅតុលាការឱ្យលុបចោលបាន[33]។ មានមូលហេតុជាច្រើនដែលនាំឱ្យមានការលុបចោលអាពាហ៍ពិពាហ៍នេះ ដូចជាក្នុងករណី ជនដែលមិនទាន់គ្រប់អាយុបានរៀបអាពាហ៍ពិពាហ៍ មានន័យថា បុរស និងនារី ជាអនីតិជនដែលមានអាយុក្រោម

[31] មាត្រា ៩៥៨ ចំណុច-ក នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[32] មាត្រា ៩៥៨ ចំណុច-ខ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[33] មាត្រា ៩៦០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

១៨ឆ្នាំ បានរៀបការជាមួយគ្នា នោះភាគីនីមួយៗ ញាតិសន្តានរបស់ជននោះ ឬតំណាងអយ្យការ អាចទាមទារទៅតុលាការឱ្យលុបចោលបាន។ ម្យ៉ាងទៀត ចំពោះបុគ្គលដែលមានសហព័ទ្ធរួចហើយ ប៉ុន្តែបែរជាទៅរៀបអាពាហ៍ពិពាហ៍ថ្មីជាមួយអ្នកដទៃ សហព័ទ្ធរបស់ភាគីឬសហព័ទ្ធមុននោះ ក៏អាចទាមទារឱ្យលុបចោលអាពាហ៍ពិពាហ៍នោះបានដែរ[34]។

មួយវិញទៀត អាពាហ៍ពិពាហ៍ក៏ត្រូវចាត់ទុកជាមោឃៈផងដែរ បើសិនជាមានការរៀបអាពាហ៍ពិពាហ៍ដែលបានធ្វើឡើងរវាងញាតិលោហិត ដូចបានបកស្រាយក្នុងចំណុច (១.១.៤.៣) និងការរៀបអាពាហ៍ពិពាហ៍ដែលបានធ្វើឡើងរវាងញាតិពន្ធ ដូចបានបកស្រាយក្នុងចំណុច (១.១.៤.៤) ខាងលើ នោះភាគីនីមួយៗ ញាតិសន្តានរបស់ជននោះ ឬតំណាងអយ្យការ អាចទាមទារទៅតុលាការឱ្យលុបចោល បាន។

#### ១.២.២.២ ការលុបចោលអាពាហ៍ពិពាហ៍ធ្វើក្នុងអំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ ពិពាហ៍ថ្មីទៀត

ប្រសិនបើនារីបានរៀបអាពាហ៍ពិពាហ៍ថ្មីក្នុងអំឡុងពេលហាមឃាត់ ដូចបានបកស្រាយក្នុងចំណុច (១.១.៤.២) នោះអាពាហ៍ពិពាហ៍ថ្មីដែលបានធ្វើឡើងនេះនឹងត្រូវលុបចោល។ អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀតនេះ គឺផ្តោតទៅលើនារីត្រូវរង់ចាំរយៈពេល ១២០ថ្ងៃ បន្ទាប់ពីអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬលុបចោល ទើបនារីនោះអាចរៀបអាពាហ៍ពិពាហ៍ថ្មីបាន ដើម្បីសន្មតពីភាពជាឪពុករបស់កូន។ ក្នុងករណីនេះ ប្រសិនបើកូនដែលបានកើតនៅក្រោយអំឡុងពេល ១៨០ថ្ងៃ ឬ ក្នុងអំឡុងពេល ៣០០ថ្ងៃ គិតចាប់ពីពេលដែលបានរំលាយ ឬលុបចោលអាពាហ៍ពិពាហ៍ ត្រូវសន្មតថា មានគភ៌ នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍នោះ [35] ។ ប៉ុន្តែក្នុងករណីដែលនារីមានផ្ទៃពោះ នៅមុនពេលដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬ លុបចោល ហើយបានសម្រាលកូន ឬ ចំពោះករណីដែលមានលិខិតបញ្ជាក់ពីការគ្មានផ្ទៃពោះពីវេជ្ជបណ្ឌិត នារីនោះអាចរៀបអាពាហ៍ពិពាហ៍ថ្មីបាន ដោយមិនចាំបាច់រង់ចាំរយៈពេល ១២០ថ្ងៃ បន្ទាប់ពីអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬលុបចោលនោះទេ[36]។ ម្យ៉ាងទៀត ប្រសិនបើរយៈពេល ១២០ថ្ងៃ បានកន្លងផុត គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬលុបចោល ឬប្រសិនបើនារីមានផ្ទៃពោះក្រោយពីបានរៀបអាពាហ៍ពិពាហ៍ថ្មីទៀត អាពាហ៍ពិពាហ៍ដែលបានធ្វើឡើងក្រោយនេះ មិនអាចទាមទារឱ្យលុបចោលវិញបាននោះទេ[37]។

---

[34] មាត្រា ៩៦០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[35] មាត្រា ៩៨៨ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[36] មាត្រា ៩៥០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[37] មាត្រា ៩៦២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

### ១.២.២.៣ ការលុបចោលអាពាហ៍ពិពាហ៍ដោយការឆបោក ឬការគម្រាម

ការឆបោក ឬការគម្រាមគឺជាឧបាយកលណាមួយដែលធ្វើឱ្យភាគីម្ខាងទៀតរៀបអាពាហ៍ពិពាហ៍ដោយឆន្ទៈមិនពិត ឬទទួលរងសម្ពាធអ្វីមួយដើម្បីយល់ព្រមរៀបអាពាហ៍ពិពាហ៍។ ប្រសិនបើបុគ្គលដែលបានរៀបអាពាហ៍ពិពាហ៍ដោយការឆបោក ឬការគម្រាម បុគ្គលនោះអាចទាមទារទៅតុលាការឱ្យលុបចោលអាពាហ៍ពិពាហ៍នោះបាន[38]។ ប៉ុន្តែសិទ្ធិលុបចោលនេះ ត្រូវរលត់ បើភាគីបានរកឃើញការឆបោក ឬបើអំឡុងពេល ៣ខែបានកន្លងផុត ក្រោយពីបានរួចខ្លួនផុតពីការគម្រាម ឬបើបានធ្វើសច្ចានុមតិ[39]។

[38] មាត្រា ៩៦៣ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[39] មាត្រា ៩៦៣ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

# ជំពូកទី២
# បែបបទនៃការរៀបអាពាហ៍ពិពាហ៍
# រវាងពលរដ្ឋខ្មែរ និងជនបរទេស

# ជំពូកទី២

# បែបបទនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

## ២.១ នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

### ២.១.១ ការបំពេញបែបបទ

ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស គឺមានភាពប្រហាក់ប្រហែលគ្នាទៅនឹងការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរដែរ គ្រាន់តែមានចំណុចមួយចំនួនតែប៉ុណ្ណោះដែលខុសគ្នា។ ការរៀបអាពាហ៍ពិពាហ៍ដែលសមស្របទៅតាមផ្លូវច្បាប់ គឺមិនមែនត្រឹមតែគោរពតាមលក្ខខណ្ឌគ្រឹះតែម្យ៉ាងនោះទេ តែទាមទារឱ្យគោរពតាមលក្ខខណ្ឌទម្រង់ផងដែរ មានន័យថា ទាក់ទងទៅនឹងនីតិវិធី ឬបែបបទ នៃការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីនៅមន្ត្រីអត្រានុកូលដ្ឋានជាដើម។

គួរបញ្ជាក់ផងដែរថា ចំពោះជនបរទេសដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ ជាមួយពលរដ្ឋខ្មែរ ចាំបាច់ត្រូវតែគោរពតាមលក្ខខណ្ឌដែលច្បាប់បានកំណត់ ហើយត្រូវតែមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាផងដែរ ដើម្បីបំពេញបែបបទ និងនីតិវិធីផ្សេងៗក្នុងការរៀបអាពាហ៍ពិពាហ៍នេះ។ យោងតាមអនុក្រឹត្យស្ដីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស បានកំណត់ថា អាពាហ៍ពិពាហ៍នឹងមានអានុភាពពេញលក្ខណៈបាន លុះត្រាតែភាគីសាមីខ្លួនបុរស និងនារីចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ តាមរយៈការចុះបញ្ជីអាពាហ៍ពិពាហ៍ដោយសាមីខ្លួនផ្ទាល់ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានដែលសាមីខ្លួនទាំងពីរបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍។

ជារួមមកចំពោះនីតិវិធី និងបែបបទដែលភាគីទាំងសងខាងត្រូវបំពេញដើម្បីឱ្យការរៀបអាពាហ៍ពិពាហ៍របស់ខ្លួនប្រព្រឹត្តទៅបានត្រឹមត្រូវ និង សមស្របទៅតាមការកំណត់របស់ច្បាប់ ត្រូវគោរពតាមដំណាក់កាលនីមួយៗដូចខាងក្រោម៖

#### ២.១.១.១ នីតិវិធីបំពេញបែបបទនៅក្រសួងការបរទេស

សាមីខ្លួនដែលជាជនបរទេស ដែលចង់រៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ នៅក្នុងប្រទេសកម្ពុជាដាច់ខាតត្រូវតែមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីបំពេញបែបបទ និងនីតិវិធី។ ដើម្បីរៀបអាពាហ៍ពិពាហ៍បានជាមួយពលរដ្ឋខ្មែរ សាមីខ្លួនជាជនបរទេស ត្រូវបំពេញបែបបទទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា ដោយភ្ជាប់នូវសំណុំឯកសារដូចខាងក្រោម៖

- ឯកសារថតចម្លងនៃលិខិតឆ្លងដែនរបស់សាមីខ្លួនជនបរទេសមានទិដ្ឋាការចូលប្រទេសកម្ពុជា ដែលនៅមានសុពលភាព

- លិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយ ចេញដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនដែលជាជនបរទេស
- ពាក្យសុំរៀបអាពាហ៍ពិពាហ៍
- លិខិតបញ្ជាក់សុខភាពចេញដោយសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា
- លិខិតថ្កោលទោសចេញដោយសមត្ថកិច្ចនៃប្រទេសសាមីខ្លួនជនបរទេស
- លិខិតបញ្ជាក់អំពីមុខរបរពិតប្រាកដរបស់សាមីខ្លួនជនបរទេសដែលធានាដល់ជីវភាពរស់នៅ ចេញដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស។

ម្យ៉ាងទៀត ចំពោះឯកសារថតចម្លងនៃលិខិតឆ្លងដែន និងលិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយ ត្រូវមានការបញ្ជាក់នីត្យានុកូលភាពពីស្ថានទូត ឬ ស្ថានតំណាងនៃប្រទេសរបស់សាមីខ្លួនជនបរទេសប្រចាំនៅព្រះរាជាណាចក្រកម្ពុជា[40]។

សាមីខ្លួនដែលជាជនបរទេស ត្រូវបំពេញបែបបទទាំងនេះនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា ហើយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិមានភារកិច្ចពិនិត្យ និងផ្តល់យោបល់លើសំណុំឯកសាររបស់ជនបរទេស ដែលសុំរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ និងត្រូវជូនដំណឹងទៅសាមីខ្លួនដែលជាជនបរទេសវិញ ក្នុងរយៈពេលយ៉ាងយូរ ០៥ថ្ងៃការងារ។ក្រោយពីបានពិនិត្យ និងផ្តល់យោបល់លើសំណុំឯកសាររបស់ជនបរទេសហើយ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវបញ្ជូនសំណុំឯកសារទាំងនោះទៅក្រសួងមហាផ្ទៃ និងជូនពត៌មានទៅស្ថាប័នពាក់ព័ន្ធ[41]។

#### ២.១.១.២ នីតិវិធីបំពេញបែបបទនៅក្រសួងមហាផ្ទៃ

បន្ទាប់ពីទទួលបាននូវសំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ដែលបានបញ្ជូនមកពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជាមក ដោយផ្អែកតាមសេចក្តីណែនាំស្តីពីការអនុវត្តអនុក្រឹត្យស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស បាននិយាយអំពីភារកិច្ច នៅថ្នាក់ក្រសួងថា នាយកដ្ឋានរដ្ឋបាលទូទៅនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ជាសេនាធិការឱ្យក្រសួងលើការងារស្ថិតិ និងអត្រានុកូលដ្ឋាន និងមានភារកិច្ចៈ

- ចុះបញ្ជីសំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍របស់សាមីខ្លួនជនបរទេសដែលបានផ្ញើមកពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

[40] មាត្រា៦ នៃអនុក្រឹត្យ ស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស។

[41] មាត្រា៧ នៃអនុក្រឹត្យ ស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស។

- ជូនឯកសារសាមីខ្លួនជនបរទេសទៅអង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ ដើម្បីសហការផ្តល់ព័ត៌មានពីអត្តសញ្ញាណជនបរទេសនោះ។
- ជូនដំណឹងអំពីការសុំរៀបអាពាហ៍ពិពាហ៍របស់សាមីខ្លួនជនបរទេស ទៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សាមីខ្លួន និងមន្ត្រីអត្រានុកូលដ្ឋាន ឃុំ-សង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ និងជូនដំណឹង ព្រមទាំងប្រគល់សំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍ទៅសាមីខ្លួនជនបរទេស ក្នុងរយៈពេលយ៉ាងយូរ ០៥ថ្ងៃការងារ ដើម្បីសាមីខ្លួនដាក់សំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋាន ឃុំ-សង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ។
- ត្រូវពិនិត្យនីត្យានុកូលភាពលើសំណុំឯកសារដែលចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ-សង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនដែលជាពលរដ្ឋខ្មែរ[42]។

#### ២.១.១.៣ នីតិវិធីបំពេញបែបបទនៅចំពោះមន្ត្រីអត្រានុកូលដ្ឋាន

សាមីខ្លួនជនបរទេស បន្ទាប់ពីបានទទួលការត្រួតពិនិត្យ និងផ្តល់យោបល់លើសំណុំឯកសារ និងបានចុះបញ្ជីសំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍រួចហើយ សាមីខ្លួនត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋាន ឃុំ-សង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ។

សំណុំឯកសារដែលជនបរទេសត្រូវមានៈ

- ពាក្យសុំរៀបអាពាហ៍ពិពាហ៍ មានបិទរូបថតរបស់សាមីខ្លួនបុរស និងសាមីខ្លួននារី ទំហំ ៤ X ៦ ថតចំពីមុខ ក្នុងរយៈពេល ៣ខែចុងក្រោយ។
- ឯកសារថតចម្លង នៃលិខិតឆ្លងដែនរបស់សាមីខ្លួនជនបរទេសមានទិដ្ឋាការចូលប្រទេសកម្ពុជា ដែលនៅមានសុពលភាព។
- លិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយ ចេញដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស។
- លិខិតបញ្ជាក់សុខភាពចេញដោយសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។
- លិខិតថ្កោលទោសចេញដោយសមត្ថកិច្ច នៃប្រទេសសាមីខ្លួនជនបរទេស។
- លិខិតបញ្ជាក់អំពីមុខរបរពិតប្រាកដរបស់សាមីខ្លួនជនបរទេស ដែលធានាដល់ជីវភាពរស់នៅចេញដោយសមត្ថកិច្ច នៃប្រទេសសាមីខ្លួនជនបរទេស។

ចំពោះសាមីខ្លួនពលរដ្ឋខ្មែរ ដែលត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេសនោះ ក៏ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋាន ឃុំ-សង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍ដែលខ្លួនរស់នៅដោយមានភ្ជាប់នូវ

[42] សេចក្តីណែនាំស្តីពី ការអនុវត្តអនុក្រឹត្យស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស។

សំណុំឯកសារដូចខាងក្រោម៖

- ពាក្យសុំរៀបអាពាហ៍ពិពាហ៍ មានបិទរូបថតរបស់សាមីខ្លួនបុរស និងសាមីខ្លួននារី ទំហំ ៤ X ៦ ថតចំពីមុខ ក្នុងរយៈពេល ៣ខែចុងក្រោយ
- សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់សាមីខ្លួនពលរដ្ឋខ្មែរ
- លិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយ ចេញដោយមេឃុំ ឬចៅសង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ (ករណីពោះម៉ាយ ឬមេម៉ាយដោយប្រពន្ធ ឬប្តីស្លាប់ ត្រូវមានសំបុត្រមរណភាពរបស់សហព័ទ្ធ បើពោះម៉ាយ ឬមេម៉ាយដោយលែងលះត្រូវមានសាលក្រមពីសាលាដំបូង)
- លិខិតបញ្ជាក់សុខភាពចេញដោយមន្ទីរពេទ្យ ដែលទទួលស្គាល់ជាផ្លូវការ ពីក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា[43]។

ពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងសំណុំឯកសារសាមីខ្លួនជាពលរដ្ឋខ្មែរ និងជនបរទេសត្រូវដាក់ស្របពេលជាមួយគ្នា ទៅមន្ត្រីអត្រានុកូលដ្ឋាន ឃុំ-សង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ ដោយអនុវត្តតាមទម្រង់បែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន។

មួយវិញទៀតដោយយោងតាមមាត្រា១០នៃអនុក្រឹត្យស្តីពី ការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស មន្ត្រីអត្រានុកូលដ្ឋានឃុំ-សង្កាត់ មានភារកិច្ច ពិនិត្យ និងសម្រេចលើពាក្យស្នើសុំរៀបអាពាហ៍ពិពាហ៍សាមីខ្លួនបុរស និងនារី ក្នុងរយៈពេលយ៉ាងយូរ ០៣ថ្ងៃការងារបន្ទាប់ពីបានទទួលពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងសំណុំឯកសារភ្ជាប់។ បន្ទាប់ពីពិនិត្យពាក្យសុំ និងសំណុំឯកសារភ្ជាប់របស់សាមីខ្លួនបុរស និងនារី បានត្រឹមត្រូវតាមគោលការណ៍ច្បាប់រួចហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវរៀបចំប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ដោយមានវត្តមានផ្ទាល់របស់សាមីខ្លួន បុរស និងនារី ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ឃុំ-សង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ។

នៅពេលទទួលបានពាក្យសុំរៀបអាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលដ្ឋានត្រូវពិនិត្យឱ្យបានហ្មត់ចត់ ចំពោះបុរស និងនារីដែលបានដាក់ពាក្យសុំនោះ។ប្រសិនបើពិនិត្យទៅឃើញថា មិនមានលក្ខណៈត្រឹមត្រូវទៅតាមលក្ខខណ្ឌនៃក្រមរដ្ឋប្បវេណី និងបទប្បញ្ញត្តិនៃអត្រានុកូលដ្ឋានទេ មន្ត្រីអត្រានុកូលដ្ឋានមិនអាចអនុញ្ញាតឱ្យបុរស និងនារី នោះរៀបអាពាហ៍ពិពាហ៍បាននោះឡើយ។

ប៉ុន្តែ ប្រសិនបើពិនិត្យទៅឃើញថា មានលក្ខណៈត្រឹមត្រូវទៅតាមលក្ខខណ្ឌនៃក្រមរដ្ឋប្បវេណី និងបទប្បញ្ញត្តិនៃអត្រានុកូលដ្ឋានហើយ នោះមន្ត្រីអត្រានុកូលដ្ឋានត្រូវចេញប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ជាសាធារណៈចំនួន ០៥ច្បាប់ ដូចខាងក្រោម៖

[43] សេចក្តីណែនាំស្តីពីការអនុវត្តអនុក្រឹត្យស្តីពី ការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស។

- ០១ច្បាប់ បិទផ្សាយជាសាធារណៈ នៅលំនៅដ្ឋានសាមីខ្លួននារី
- ០១ច្បាប់ បិទផ្សាយជាសាធារណៈ នៅសាលាឃុំ ឬសង្កាត់សាមីខ្លួននារី
- ០១ច្បាប់ រក្សាទុកជាឯកសារនៅសាលាឃុំ ឬសង្កាត់សាមីខ្លួននារី
- ០១ច្បាប់ បិទផ្សាយជាសាធារណៈនៅ ស្ថានទូត ឬស្ថានតំណាងនៃប្រទេសសាមីខ្លួនជនបរទេស ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា
- ០១ច្បាប់ បិទផ្សាយជាសាធារណៈនៅលំនៅដ្ឋាន ឬទីកន្លែងស្នាក់នៅនៃសាមីខ្លួនជនបរទេស (ករណីជនបរទេសនោះ មានលំនៅដ្ឋាន ឬទីកន្លែងស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា)។

ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍នេះត្រូវបិទផ្សាយរយៈពេល ១០ថ្ងៃ នៅទីកន្លែងដែលបានកំណត់ខាងលើមុនថ្ងៃរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី ឬថ្ងៃចុះបញ្ជីអាពាហ៍ពិពាហ៍ ដើម្បីឱ្យជនដែលមានប្រយោជន៍ក្នុងរឿងនោះ អាចប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នេះបាន។

ផុតរយៈពេល ១០ថ្ងៃ អាពាហ៍ពិពាហ៍អាចធ្វើទៅបាន បើគ្មានការប្តឹងជំទាស់ តែបើក្នុងករណីមានការប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នេះ មុននឹងអាចរៀបអាពាហ៍ពិពាហ៍បាន លុះត្រាតែបណ្តឹងទាស់ត្រូវបានដោះស្រាយរួចរាល់តាមគោលការណ៍ដែលបានចែងក្នុងក្រមរដ្ឋប្បវេណី និងបទប្បញ្ញត្តិនៃអត្រានុកូលដ្ឋាន។

មន្ត្រីអត្រានុកូលដ្ឋានត្រូវសរសេរប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ដែលមានខ្លឹមសារដូចតទៅៈ

- នាមត្រកូល និងនាមខ្លួន
- សញ្ជាតិ
- ថ្ងៃខែឆ្នាំកំណើត
- ទីកន្លែងកំណើត
- មុខរបរ
- ទីលំនៅបច្ចុប្បន្ន នៃអនាគតប្តី ឬប្រពន្ធ
- និង នាមត្រកូល និងនាមខ្លួន
- ថ្ងៃខែឆ្នាំកំណើត
- មុខរបរ
- ទីលំនៅបច្ចុប្បន្នរបស់ឪពុកម្តាយ នៃអនាគតប្តី ឬប្រពន្ធ (បើឪពុក ឬម្តាយស្លាប់ ត្រូវដាក់ថាស្លាប់ផង)។

អាពាហ៍ពិពាហ៍នឹងមានអានុភាពពេញលក្ខណៈត្រឹមត្រូវស្របតាមច្បាប់បាន លុះត្រាតែសាមីខ្លួនបុរសនិងនារី ចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ តាមរយៈការចុះបញ្ជីរៀបអាពាហ៍ពិពាហ៍ ដោយសាមីខ្លួនផ្ទាល់ នៅចំពោះមុខ

មន្ត្រីអត្រានុកូលដ្ឋាននៃ ឃុំ-សង្កាត់ ដែលសាមីខ្លួនដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ដោយនាំមកជាមួយនូវសាក្សីគ្រប់អាយុរៀបការចំនួន ០២រូប ផង ស្របទៅតាមទម្រង់បែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន[44]។

មន្ត្រីអត្រានុកូលដ្ឋាន ឃុំ-សង្កាត់ ក្រោយពីចុះបញ្ជីអាពាហ៍ពិពាហ៍តាមទម្រង់បែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋានហើយ ត្រូវចេញសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើមចំនួន ០១សន្លឹក និងចេញសេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍តាមការស្នើសុំរបស់សាមីខ្លួន ដើម្បីយកទៅប្រើប្រាស់ ហើយត្រូវធ្វើរបាយការណ៍ជាបន្ទាន់ផ្ញើមកក្រសួងមហាផ្ទៃ តាមរយៈ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត បន្ទាប់ពីបានចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសនីមួយៗរួចហើយ ដោយបញ្ជាក់អំពី៖

- លេខបញ្ជី
- លេខសៀវភៅ
- ថ្ងៃ ខែ ឆ្នាំចុះបញ្ជី
- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត
- និងសញ្ជាតិរបស់សាមីខ្លួនទាំងពីរ[45]។

### ២.១.២ ការបង់កម្រៃសេវារដ្ឋបាល

ជាទូទៅ រដ្ឋតែងតែសម្របសម្រួលដល់ប្រជាពលរដ្ឋដោយមិនត្រូវការកម្រៃតបស្នង ប៉ុន្តែដើម្បីធានាដល់សេវាផ្នែករដ្ឋបាល គឺតែងតែមានការបង់កម្រៃសេវារដ្ឋបាល ដើម្បីធ្វើការធានាឱ្យសេវានោះមានភាពល្អប្រសើរ និងមានភាពឆាប់រហ័ស។

យ៉ាងណាមិញចំពោះការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ក៏តម្រូវឱ្យមានការបង់នូវកម្រៃសេវារដ្ឋបាលចូលស្ថាប័នដែលពាក់ព័ន្ធផងដែរ។

#### ២.១.២.១ នៅក្រសួងការបរទេស

ចំពោះការបង់កម្រៃផ្នែករដ្ឋបាល លើសំណុំឯកសារដែលត្រូវបំពេញចំពោះនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវបានកំណត់យកតម្លៃ ១០.០០០ រៀល ហើយរយៈពេលនៃការផ្ដល់សេវាមានរយៈពេល ០៥ថ្ងៃ គិតតែថ្ងៃធ្វើការប៉ុណ្ណោះ ដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធនៃប្រកាសរួមរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ស្ដីពីការផ្ដល់សេវាសាធារណៈរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ[46]។

[44] មាត្រា ១០ នៃអនុក្រឹត្យ ស្ដីពី ការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស។
[45] សេចក្ដីណែនាំស្ដីពីការអនុវត្តអនុក្រឹត្យស្ដីពី ការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស។
[46] តារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ ១០៣៩ សហវ ប្រក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៦ ស្ដីពីការផ្ដល់សេវាសាធារណៈរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

#### ២.១.២.២ នៅក្រសួងមហាផ្ទៃ

ចំពោះការបំពេញបែបបទទៅលើសំណុំឯកសារនៃការស្នើសុំរៀបអាពាហ៍ពិពាហ៍របស់ជនបរទេស ជាមួយប្រជាពលរដ្ឋខ្មែរ ក្រសួងមហាផ្ទៃ មិនតម្រូវឱ្យបង់សេវារដ្ឋបាលឡើយ ហើយរយៈពេលនៃការផ្តល់សេវា មានរយៈពេល ២៣ថ្ងៃ[47]។

#### ២.១.២.៣ នៅរដ្ឋបាលឃុំ សង្កាត់

ដូចគ្នាទៅនឹងក្រសួងមហាផ្ទៃដែរ ចំពោះការដាក់ពាក្យបំពេញបែបបទ ទៅលើសំណុំឯកសារនៃការស្នើសុំរៀបអាពាហ៍ពិពាហ៍របស់ជនបរទេស ជាមួយប្រជាពលរដ្ឋខ្មែរ ទៅកាន់សាលាឃុំ សង្កាត់ ក៏មិនតម្រូវឱ្យបង់សេវារដ្ឋបាលអ្វីឡើយ ប៉ុន្តែរយៈពេលនៃការផ្តល់សេវា មានរយៈពេលត្រឹមតែ ៣ថ្ងៃ ប៉ុណ្ណោះ[48]។

## ២.២ អានុភាពនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

### ២.២.១ ចំពោះទំនាក់ទំនងបុគ្គល

ចំពោះការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស អាចមានរូបភាពពីរយ៉ាងគឺ ទីមួយការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស នៅឯបរទេស និងទីពីរ គឺការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស នៅក្នុងប្រទេសកម្ពុជា។ ជាក់ស្តែងប្រសិនបើការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស នៅក្នុងប្រទេសកម្ពុជា គឺមានការទំនាក់ទំនងគ្នារវាងបុគ្គលជាច្រើន ហើយចំពោះអានុភាពនៃអាពាហ៍ពិពាហ៍ គឺផ្តោតទៅលើទំនាក់ទំនងញាតិ ដូចបានកំណត់នៅក្នុងចំណុច ២.២.១.១ (ការបង្កើតបានជាទំនាក់ទំនងញាតិពន្ធ) និង ២.២.១.២ (ការបង្កើតស្ម៊ុំកូនពេញលេញ) ២.២.១.៣ (នាមត្រកូលរបស់សហព័ទ្ធ) ២.២.១.៤ (ការទទួលបាននីតិភាព) និង ២.២.១.៥ (ការទទួលបានសញ្ជាតិ)។

#### ២.២.១.១ ការបង្កើតបានជាទំនាក់ទំនងញាតិពន្ធ

ដោយយោងតាមក្រមរដ្ឋប្បវេណី គឺពុំមានកំណត់ច្បាស់លាស់អំពីការរៀបអាពាហ៍ពិពាហ៍រួច បណ្តាលឱ្យមានអានុភាពក្នុងការបង្កើតបានជាទំនាក់ទំនងញាតិពន្ធនោះទេ ប៉ុន្តែបើយើងក្រឡេកទៅមើល មាត្រា៩៤១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានបញ្ញត្តិអំពីការរំលត់នៃទំនាក់ទំនងញាតិពន្ធ តាមរយៈករណីដែលសហព័ទ្ធណាម្ខាងបានទទួលមរណភាព ហើយសហព័ទ្ធដែលនៅរស់បានទៅរៀបអាពាហ៍ពិពាហ៍ថ្មីទៀត ឬបានបង្ហាញឆន្ទៈបញ្ចប់ទំនាក់ទំនងញាតិពន្ធ[49]។

---

[47] តារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសអន្តរក្រសួងលេខ ១៤៤១៤ ប្រក ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់ក្រសួងមហាផ្ទៃ។

[48] តារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសអន្តរក្រសួងលេខ ១៤៣៤២ ប្រក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

[49] មាត្រា ៩៤១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

តាមការបកស្រាយដោយយោងតាមបញ្ញត្តិខាងលើ យើងអាចសន្និតបានថា ការរៀបអាពាហ៍ពិពាហ៍អាចមានអានុភាពបង្កើតបាននូវទំនាក់ទំនងញាតិថ្មី ពោលគឺ ញាតិពន្ធ ប៉ុន្តែក្រមរដ្ឋប្បវេណី បានកំណត់ត្រឹមតែទំហំញាតិពន្ធត្រឹមថ្នាក់ទី៣ ប៉ុណ្ណោះ។

ជារួមមក កាលណាភាគីទាំងសងខាងបានសម្រេចចិត្តរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ដោយបានចុះបញ្ជីអាពាហ៍ពិពាហ៍រួច ទំនាក់ទំនងរវាងសហព័ទ្ធទៅនឹងញាតិពន្ធត្រូវបានចាប់ផ្តើមដោយស្វ័យប្រវត្តិ។

**២.២.១.២ ការបង្កើតសុំកូនពេញលេញ**

ការសុំកូនពេញលេញ គឺជាការបង្កើតទំនាក់ទំនងញាតិលោហិតតាមផ្លូវច្បាប់ រវាងបុគ្គលដែលជាឪពុកម្តាយចិញ្ចឹម ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹម និងកូនសុំ។ ការសុំកូនពេញលេញ គឺជាការផ្តល់នូវគ្រួសារដែលមានឪពុកម្តាយ និងមានលំនឹងគ្រប់គ្រាន់ ដល់កុមារដែលអភ័ព្វ ដូច្នេះហើយ ក្រមរដ្ឋប្បវេណីបានបញ្ញត្តិយកមាត្រា ១០០៨ ជាគោលការណ៍នៃការសុំកូនដោយសហការរវាងប្តីប្រពន្ធ[50]។ ចំពោះការសុំកូនពេញលេញនេះ បុគ្គលដែលអាចក្លាយជាឪពុក ឬ ម្តាយចិញ្ចឹមបាន ត្រូវតែជាបុគ្គលដែលបានរៀបអាពាហ៍ពិពាហ៍រួច ឬ ជាបុគ្គលដែលមានសហព័ទ្ធ មានន័យថា សហព័ទ្ធទាំងពីរនឹងទទួលបានឋានៈជាអ្នកមានអំណាចមេបាទៅលើកូនសុំនេះ។ មិនតែប៉ុណ្ណោះ ការសុំកូនពេញលេញនេះ ត្រូវតែមានការសហការគ្នារវាងប្តី និងប្រពន្ធផងដែរ។ ទំនាក់ទំនងទាំងនេះក៏មានគោលបំណងបង្ហាញឱ្យឃើញថា ចំពោះការទទួលបន្តនូវមត៌ក ទោះបីជាកូនបង្កើតក្តី ឬ កូនសុំក្តី គឺត្រូវមានចំណែកមត៌កស្មើៗគ្នា ជារួមគឺក្លាយជាសន្តតិជនដែលមានលំដាប់ទី១។ ការសុំកូននេះ គឺប្រៀបបាននឹងការបង្កើតគ្រួសារថ្មីមួយ និងផ្តល់ភាពកក់ក្តៅទៅដល់កូនសុំ ប្រសិនបើសហព័ទ្ធទាំងសងខាងបានបង្ហាញឆន្ទៈដូចគ្នា តែបើភាគីដែលជាសហព័ទ្ធម្ខាងមិនយល់ស្របទេ ការសុំកូននេះ មិនអាចប្រព្រឹត្តទៅបាននោះទេ ព្រោះការគ្រប់គ្រងកូននឹងមិនមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងមិនមានភាពល្អប្រសើរនោះទេ។

**២.២.១.៣ នាមត្រកូលរបស់សហព័ទ្ធ**

ក្រោយពីបានចុះបញ្ជីអាពាហ៍ពិពាហ៍ នឹងបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាហើយ ភាគីទាំងសងខាងនឹងក្លាយទៅជាសហព័ទ្ធនឹងគ្នាពេញសិទ្ធិ ហើយនៅក្នុងក្រមរដ្ឋប្បវេណីក៏បានកំណត់ថា ក្រោយពេលដែលរៀបអាពាហ៍ពិពាហ៍រួច ប្តី និងប្រពន្ធអាចប្រើប្រាស់នាមត្រកូលប្តីក៏បាន ប្រពន្ធក៏បាន ឬនាមត្រកូលរៀងៗខ្លួនដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍ក៏បានដែរ[51]។មានន័យថា ចំពោះនាមត្រកូលនេះ គឺគោរពសិទ្ធិស្វ័យសម្រេចចំពោះនាមត្រកូល និងសិទ្ធិបុគ្គលដែលជាសហព័ទ្ធ។ ជាគោលការណ៍ ប្តីប្រពន្ធនៅប្រទេសកម្ពុជា ប្រើនាមត្រកូលខុសគ្នា ដោយសារតែនាមត្រកូលបង្ហាញឱ្យឃើញពីតំណរខ្សែលោហិត និង ឬសគល់នៃឪពុកម្តាយ

[50] សេចក្តីកំណត់ចំពោះមាត្រា១០០៨ នៃក្រមរដ្ឋប្បវេណី ភាគទី៥ គន្ថីទី៧

[51] មាត្រា៩៦៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ដូនតា ជាពិសេសសម្គាល់នូវអត្តសញ្ញាណរបស់ជនគ្រប់រូបជាមួយនឹងនាមខ្លួន ទើបច្បាប់សម្រេចយកយន្តការ ដែលឱ្យជនគ្រប់រូបអាចជ្រើសរើសដោយសេរីនូវនាមត្រកូល បន្ទាប់ពីបានរៀបអាពាហ៍ពិពាហ៍រួច។ ជារួមមក មានន័យថា ទោះបីជាសហព័ទ្ធចង់ប្រើប្រាស់នាមត្រកូលរួម ឬ នាមត្រកូលដោយឡែកក៏ពុំមានបញ្ហាអ្វីដែរ។

#### ២.២.១.៤ ការទទួលបាននីតិភាព

នីតិភាពសំដៅលើភាពដែលមានអាយុគ្រប់តាមច្បាប់កំណត់ ហើយមានសមត្ថភាពឯករាជ្យខាងអំពើ។ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានកំណត់យកអាយុ ១៨ឆ្នាំ បានដល់នីតិភាព។ ប៉ុន្តែ មានលក្ខខណ្ឌពិសេសមួយចំនួនទៀតដែលអាចឱ្យអនីតិជនទទួលបាននីតិភាព។ ដូច្នេះហើយ ប្រសិនបើអនីតិជនបានរៀបអាពាហ៍ពិពាហ៍ អនីតិជននោះត្រូវបានចាត់ទុកថា បានដល់នីតិភាពដោយអាពាហ៍ពិពាហ៍នោះ[52]។ មានន័យថា អាពាហ៍ពិពាហ៍ នាំឱ្យបុគ្គលដល់នីតិភាពដោយស្វ័យប្រវត្តិ ហើយប្រសិនបើមានការលែងលះកើតឡើង ក៏នីតិភាពនេះ មិនរលត់ទៅតាមការលែងលះវិញដែរ។

#### ២.២.១.៥ ការទទួលបានសញ្ជាតិ

ជនបរទេស មិនថាជាបុរស ឬស្ត្រីនោះទេ ប្រសិនបើយកប្តី ឬប្រពន្ធជាពលរដ្ឋខ្មែរដោយបានរៀប អាពាហ៍ពិពាហ៍ អាចទាមទារសញ្ជាតិខ្មែរបាន លុះត្រាតែស្ត្រី ឬបុរសនោះបានរស់នៅជាមួយគ្នា រយៈពេល ៣ឆ្នាំ ក្រោយចុះបញ្ជីអាពាហ៍ពិពាហ៍ និងបានស្នាក់នៅយ៉ាងហោចរយៈពេល ១២ខែ ពេញលេញក្នុងព្រះរាជាណាចក្រកម្ពុជា [53] ។បន្ថែមទៅលើលក្ខខណ្ឌទាំងនេះ ជនបរទេសដែលអាចសុំទាមទារសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍ បាន ត្រូវបំពេញលក្ខខណ្ឌមួយចំនួនដូចជាៈ

- មានគំនិត មារយាទ និងសីលធម៌ល្អ។
- ពុំដែលមានទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ។
- មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅពេលដាក់ពាក្យសុំទាមទារសញ្ជាតិខ្មែរ ដោយអាពាហ៍ពិពាហ៍។
- ចេះនិយាយភាសាខ្មែរ ចេះអក្សរខ្មែរ និងយល់ដឹងប្រវត្តិសាស្ត្រខ្មែរខ្លះៗ។
- មានបញ្ញា និងកាយសម្បទាដែលមិននាំឱ្យគ្រោះថ្នាក់ ឬនាំឱ្យមានបន្ទុកដល់ជាតិ[54]។

ជនបរទេសដែលបានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ជាមួយពលរដ្ឋខ្មែរ អាចទាមទារសញ្ជាតិខ្មែរបាន ដោយត្រូវដាក់ពាក្យសុំ និងបំពេញបែបបទនៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ[55]។

---

[52] មាត្រា៩៦៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[53] មាត្រា១១ នៃច្បាប់ស្តីពីសញ្ជាតិ

[54] មាត្រា១២ នៃច្បាប់ស្តីពីសញ្ជាតិ

[55] មាត្រា៤ នៃអនុក្រឹត្យស្តីពី ការអនុវត្តច្បាប់ស្តីពីសញ្ជាតិ

ជនបរទេសដែលទាមទារសញ្ជាតិខ្មែរត្រូវមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅពេលដាក់ពាក្យសុំ និងត្រូវបំពេញបែបបទដូចខាងក្រោមៈ

- ពាក្យទាមទារសញ្ជាតិខ្មែរចំនួន ២ច្បាប់
- ជីវប្រវត្តិសង្ខេបរបស់សាមីខ្លួនចំនួន ២ច្បាប់ ដោយមានបិទរូបថតទំហំ ៤cm x ៦cm
- រូបថត ត្រូវថតថ្មីចំពីមុខ គ្មានពាក់មួក និងគ្មានពាក់វ៉ែនតាទំហំ ៤cm x ៦cm ចំនួន ១០សន្លឹក
- សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍របស់សាមីខ្លួនចំនួន ២ច្បាប់
- លិខិតបញ្ជាក់ទីលំនៅចេញដោយមេឃុំ ចៅសង្កាត់នៃទីលំនៅរបស់សាមីខ្លួនចំនួន ២ច្បាប់
- ឯកសារបញ្ជាក់ការស្នាក់នៅរយៈពេល ១២ខែ ពេញលេញក្នុងព្រះរាជាណាចក្រកម្ពុជាចំនួន ២ច្បាប់
- ច្បាប់ថតចម្លងលិខិតឆ្លងដែន និងទិដ្ឋាការរបស់សាមីខ្លួនដែលនៅមានសុពលភាពចំនួន ២ច្បាប់
- លិខិតបញ្ជាក់គំនិតមាយាទ និងសីលធម៌ចេញដោយមេឃុំ ចៅសង្កាត់នៃទីលំនៅរបស់សាមីខ្លួនចំនួន ២ច្បាប់
- លិខិតថ្កោលទោសមានសុពលភាពគិតត្រឹមថ្ងៃដាក់ពាក្យ ចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនចំនួន ១ច្បាប់
- លិខិតថ្កោលទោសមានសុពលភាព គិតត្រឹមថ្ងៃដាក់ពាក្យ ចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជាចំនួន ១ច្បាប់
- លិខិតបញ្ជាក់សុខភាព ចេញដោយគ្រូពេទ្យជំនាញនៃមន្ទីរពេទ្យរដ្ឋ នៃព្រះរាជាណាចក្រកម្ពុជាចំនួន ២ ច្បាប់[56]។

### ២.២.១.៦ សិទ្ធិទទួលបានសន្តតិកម្ម

ជនបរទេស ក៏អាចក្លាយជាសន្តតិជន ឬទទួលបានមត៌កពីមតកជនផងដែរ ប៉ុន្តែមិនអាចទទួលបាននូវមត៌កជាអចលនវត្ថុបានទេ។ អចលនវត្ថុ សំដៅទៅលើ ដីធ្លី និងវត្ថុជាប់នៅលើដី ហើយមិនអាចផ្លាស់ប្តូរទីកន្លែងបាន ដូចជា អាគារ សំណង់ ដំណាំ រុក្ខជាតិ ជាអាទិ៍[57]។ មានន័យថា រាល់អចលនវត្ថុដូចជាដីធ្លីជាដើម សន្តតិជនជាជនបរទេសមិនអាចទទួលបានតាមរយៈសន្តតិកម្ម ឬអច្ច័យទានពីមតកជនបានទេ។ ប៉ុន្តែក៏មានបញ្ញត្តិពិសេស ដែលបានផ្តល់សិទ្ធិខ្លះចំពោះជនបរទេសទៅលើចំណែកសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិផងដែរ។ អគារសហកម្មសិទ្ធិ សំដៅដល់អគារ ឬសំណង់ដែលមានកម្មសិទ្ធិករច្រើននាក់រស់នៅ។ អគារសហកម្មសិទ្ធិ មានចំណែកខ្លះជាកម្មសិទ្ធិផ្តាច់មុខរបស់សហកម្មសិទ្ធិករនីមួយៗហៅថា **ចំណែកឯកជន** និងមានចំណែកខ្លះជាលំហរួម សម្រាប់ការប្រើប្រាស់រួមរបស់សហកម្មសិទ្ធិករទាំងអស់ហៅថា **ចំណែករួម**។ ជន

[56] មាត្រា៥ នៃអនុក្រឹត្យ ស្តីពីការអនុវត្តច្បាប់ស្តីពីសញ្ជាតិ

[57] មាត្រា ១២០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

បរទេស ក៏អាចមានសិទ្ធិទទួលបានចំណែកសិទ្ធិកម្មសិទ្ធិ លើចំណែកឯកជននៃអគារសហកម្មសិទ្ធិតាមរយៈ សន្តតិកម្មផងដែរ ប៉ុន្តែជនបរទេសអាចមានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិចាប់ពីជាន់ទី ០១ ឡើងទៅ ចំណែកឯជាន់ផ្ទាល់ដី និងជាន់ក្រោមដី មិនត្រូវបានអនុញ្ញាតឱ្យជនបរទេសមានសិទ្ធិកម្មសិទ្ធិ នោះឡើយ[58]។

ជាគោលការណ៍ ច្បាប់ទទួលស្គាល់ថា ជនណាមានសញ្ជាតិខ្មែរ ជាប្រជាពលរដ្ឋខ្មែរ[59]។ ដូចនេះនៅ ពេលដែលជនបរទេសទទួលបានសញ្ជាតិខ្មែរ តាមរយៈការរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ ជនបរទេស នោះមានសិទ្ធិ កាតព្វកិច្ច និងករណីកិច្ចក្នុងការទទួលបាននូវមត៌កតាមរយៈសន្តតិកម្មដូចគ្នាទៅនឹងពលរដ្ឋខ្មែរ ផងដែរ ទាំងចលនវត្ថុ និងអចលនវត្ថុជាដីធ្លីជាដើម។

### ២.២.២ ភាតព្វកិច្ចកំណត់ដោយក្រមរដ្ឋប្បវេណី

#### ២.២.២.១ ករណីកិច្ចរួមរស់នឹងគ្នា សហការ និង សង្គ្រោះគ្នាទៅវិញទៅមក

អាពាហ៍ពិពាហ៍ ជាសម្ព័ន្ធភាពផ្លូវចិត្ត រាងកាយ និងសេដ្ឋកិច្ច របស់ប្ដីប្រពន្ធដែលបានរៀបអាពាហ៍ពិពាហ៍ នឹងគ្នា ហើយករណីកិច្ចចម្បងគឺត្រូវស្រឡាញ់ស្មោះស្ម័គ្រជាមួយគ្នាទៅវិញទៅមក រួមរស់ជាមួយគ្នាបង្កើតកូនចៅ មិនថាជាសុខ ឬជាទុក្ខឡើយ គប្បីសហការគ្នា បើភាគីណាម្ខាងជួបបញ្ហា ភាគីម្ខាងទៀតត្រូវជួយសង្គ្រោះគ្នាទៅ វិញទៅមក។ ត្រង់ចំណុចនេះ មានចែងយ៉ាងច្បាស់នៅត្រង់មាត្រា៩៦៦ នៃក្រមរដ្ឋប្បវេណី ដែលបានប្បញ្ញតិថា ប្ដីប្រពន្ធត្រូវរួមរស់ជីវភាពជាមួយគ្នា ហើយត្រូវសហការ សង្គ្រោះគ្នាទៅវិញទៅមក[60]។ ជារួមមក ប្ដីប្រពន្ធដែល បានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ជាមួយគ្នាហើយ មានសិទ្ធិស្មើគ្នាក្នុងការសហការជួយគ្នាទៅវិញទៅមក ដើម្បី ឈានទៅកាន់វឌ្ឍនភាព ព្រមទាំងកសាងគ្រួសារមួយ មានទាំងសាមគ្គីភាព និងប្រកបដោយសុភមង្គល ជា គុណប្រយោជន៍ដល់គ្រួសារទាំងមូល ជាពិសេសចេះគោរពគ្នា ថែរក្សាឱ្យតម្លៃគ្នាទៅវិញទៅមក។

#### ២.២.២.២ សេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ និង សិទ្ធិចូលរួមក្នុងសកម្មភាព សង្គម

ដើម្បីស្តែងឱ្យឃើញពីភាពស្មើគ្នា និងទទួលស្គាល់ថាប្តី និងប្រពន្ធមានសេរីភាពក្នុងការជ្រើសរើសយក វិជ្ជាជីវៈដែលខ្លួនស្រឡាញ់បាន និងមានសិទ្ធិចូលរួមប្រាស្រ័យដោយសេរី រាល់សកម្មភាពនានាដែលខ្លួនពេញ ចិត្ត ទាំងនយោបាយ វប្បធម៌ និងសង្គម ត្រង់ចំណុចនេះសបញ្ជាក់ឱ្យឃើញថា សហព័ទ្ធទាំងសងខាងមានសិទ្ធិ សេរីភាពគ្រប់គ្រាន់ ក្នុងការសម្រេចចិត្តពេញលេញ ដោយពុំមានការគាបសង្កត់ពីភាគីណាម្ខាងនោះឡើយ។ ជាក់ស្តែង ក្រមរដ្ឋប្បវេណីក៏បានបញ្ញត្តិគាំទ្រយ៉ាងច្បាស់លាស់នៅក្នុងមាត្រា៩៦៧ ដែលបានចែងថា ប្ដីប្រពន្ធ

[58] មាត្រា ៦ នៃច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស

[59] មាត្រា ៦ កថាខណ្ឌទី១ នៃច្បាប់ស្តីពីសញ្ជាតិ

[60] មាត្រា៩៦៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

មានសេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ ហើយអាចចូលរួមក្នុងសកម្មភាពនយោបាយ វប្បធម៌ និងសង្គមរៀងៗខ្លួន[61]។

### ២.២.២.៣ ការទទួលខុសត្រូវដោយសាមគ្គីភាព

ប្តីប្រពន្ធដែលរៀបអាពាហ៍ពិពាហ៍រួចហើយ ត្រូវទទួលខុសត្រូវដោយសាមគ្គីភាព ចំពោះកាតព្វកិច្ចរួមដូចជាៈ

- សោហ៊ុយដើម្បីរក្សាជីវភាពរួមរបស់ប្តីប្រពន្ធ និងសោហ៊ុយដើម្បីការអប់រំ ឬការព្យាបាល ថែទាំកូន។
- កាតព្វកិច្ច និងករណីកិច្ចផ្សេងៗទៀត ដែលប្តី ឬប្រពន្ធទាំងសងខាងបានព្រមព្រៀងតាមលិខិតជាលាយលក្ខណ៍អក្សរ ជាមួយម្ចាស់បំណុល នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ឬកាតព្វកិច្ច និងករណីកិច្ចផ្សេងៗទៀត ដែលប្តី ឬប្រពន្ធណាម្ខាងបានទទួលបន្ទុក ដោយមានការយល់ព្រមតាមលិខិតលាយលក្ខណ៍អក្សរ ពីប្រពន្ធ ឬប្តីម្ខាងទៀត នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។
- សោហ៊ុយដើម្បីគ្រប់គ្រង និងថែរក្សាទ្រព្យសម្បត្តិរួម[62]។

## ២.៣ ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ

នៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន បញ្ហាដែលកើតមាននៅក្នុងទំនាក់ទំនងប្តីប្រពន្ធ អំពីការគ្រប់គ្រង ប្រើប្រាស់ ចាត់ចែង និងបែងចែកទ្រព្យសម្បត្តិ អាចនាំទៅរកវិវាទ ទាំងនៅក្នុងពេលជាប់ចំណងអាពាហ៍ពិពាហ៍ ក៏ដូចជានៅពេលលែងលះ។ ដើម្បីបង្ការ និងដោះស្រាយវិវាទទាំងនេះ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា បានចែងអំពី ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិប្តីប្រពន្ធ។ ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិប្តីប្រពន្ធជាមូលដ្ឋាន រួមមានប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា និងប្រព័ន្ធទ្រព្យសម្បត្តិតាមច្បាប់កំណត់។

### ២.៣.១ ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា

កិច្ចសន្យាទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ ត្រូវបានធ្វើឡើងដើម្បីទប់ស្កាត់វិវាទលើទំនាក់ទំនងទ្រព្យសម្បត្តិ និងដើម្បីបញ្ជាក់ឱ្យបានច្បាស់អំពីទំនាក់ទំនងសិទ្ធិ និងករណីកិច្ចរបស់ប្តីប្រពន្ធ។ ទំនាក់ទំនងជាក់ស្តែងរបស់ប្តីប្រពន្ធ មានលក្ខណៈច្រើនបែបយ៉ាង ហើយច្បាប់ផ្តល់លទ្ធភាពឱ្យប្តីប្រពន្ធនូវជម្រើសដែលមានលក្ខណៈបត់បែនសមស្របទៅតាមភាពចាំបាច់របស់ប្តីប្រពន្ធជាក់លាក់ ជាពិសេសជាកត្តាសំខាន់មួយដែលអាចជួយការពារផលប្រយោជន៍របស់សហព័ទ្ធទាំងសងខាងដែរ។

លើសពីនេះទៅទៀត បទប្បញ្ញត្តិក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ក៏បានចែងនៅក្នុងមាត្រា ៩៦៩ កថាខណ្ឌទី១ បានចែងអំពី ប្តីប្រពន្ធ អាចធ្វើកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិ នៅមុន ឬ ក្រោយ

[61] មាត្រា ៩៦៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[62] មាត្រា ៩៧៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

អាពាហ៍ពិពាហ៍បាន ប៉ុន្តែ កិច្ចសន្យានេះ មិនអាចផ្ទុយនឹងបញ្ញត្តិស្តីពីសិទ្ធិទាមទារអាហារកាតព្វកិច្ច និង ភាគបម្រុងបានឡើយ [63] ។ មួយវិញទៀត ប្រសិនបើប្តីប្រពន្ធមិនបានធ្វើកិច្ចសន្យាពិសេសចំពោះទ្រព្យសម្បត្តិនោះទេ ទំនាក់ទំនងទ្រព្យសម្បត្តិនោះ ត្រូវអនុលោមតាមបញ្ញត្តិនៃកថាខណ្ឌទី២ គឺប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់។ ជារួមមក មាត្រានេះទទួលស្គាល់សេរីភាពរបស់ប្តីប្រពន្ធ ក្នុងការធ្វើកិច្ចសន្យាប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ។ ដូចគ្នានេះដែរ កិច្ចសន្យានេះទៀតសោត ភាពចាំបាច់ក៏ត្រូវធ្វើជាលាយលក្ខណ៍អក្សរផងដែរ ដោយសារកិច្ចសន្យានេះនាំឱ្យមានឥទ្ធិពលយ៉ាងខ្លាំងទៅលើទំនាក់ទំនងនៃសិទ្ធិ និងករណីកិច្ចលើទ្រព្យសម្បត្តិរវាងប្តីប្រពន្ធ[64]។

ការបង្កើតឱ្យមានឡើង នូវប្រព័ន្ធកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ គឺក្នុងគោលបំណង ឱ្យការកំណត់នូវទ្រព្យសម្បត្តិរបស់សហព័ទ្ធទាំងសងខាងមានភាពពិតប្រាកដ ច្បាស់លាស់ មិនថាទ្រព្យនោះជាប្រភេទអចលនវត្ថុ ឬចលនវត្ថុនោះទេ។ ក្នុងការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ សហព័ទ្ធទាំងសងខាងអាចកំណត់ពីទំនាក់ទំនងសិទ្ធិ ករណីកិច្ច និងទំនាក់ទំនងទ្រព្យសម្បត្តិដែលមានលក្ខណៈជាក់ស្តែង ទៅតាមឆន្ទៈរបស់ពួកគេរៀងៗខ្លួន។ យោងទៅតាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ត្រង់មាត្រា ៩៦៩ បានអនុញ្ញាតឱ្យប្តីប្រពន្ធ អាចធ្វើកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិ នៅមុន ឬក្រោយអាពាហ៍ពិពាហ៍បាន។ ត្រង់ចំណុចនេះ យើងក៏សង្កេតឃើញមានកំណត់យ៉ាងលម្អិតនៅក្នុងប្រកាសស្តីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដែលបានអនុញ្ញាតឱ្យប្តីប្រពន្ធ ឬបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា អាចធ្វើការចុះបញ្ជីកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិនៅមុន ឬក្រោយការរៀបអាពាហ៍ពិពាហ៍បាន ដើម្បីកំណត់ឱ្យបានច្បាស់លាស់អំពីទំនាក់ទំនងទ្រព្យសម្បត្តិប្តីប្រពន្ធ[65]។

### ២.៣.១.១ នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវធ្វើរួមគ្នា និងជាលាយល័ក្ខណ៍អក្សរដោយប្តីប្រពន្ធ ឬដោយបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍។ ពាក្យសុំត្រូវសរសេរចូលនូវឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ កាលបរិច្ឆេទចុះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ខ្លឹមសារនៃកិច្ចសន្យានោះ និងចំណុចផ្សេងទៀតដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ពាក្យសុំត្រូវភ្ជាប់មកជាមួយនូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធជាលាយល័ក្ខណ៍អក្សរ និងឯកសារផ្សេងទៀតដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌[66]។

---

[63] មាត្រា៩៦៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[64] មាត្រា៩៧០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[65] ប្រការ ២ នៃប្រកាសលេខ ៦១ កយ.ស្រក/១៣ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៣ របស់ក្រសួងយុត្តិធម៌ ស្តីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

[66] មាត្រា ២៨ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ឆ្នាំ២០១១

ពាក្យសុំច្បាប់ដើម ត្រូវមានហត្ថលេខា ឬស្នាមម្រាមដៃរបស់អ្នកដាក់ពាក្យសុំ ដោយភ្ជាប់មកជាមួយនូវច្បាប់ថតចម្លងនៃច្បាប់ដើមនោះ។ ជាគោលការណ៍ ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ឬបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវធ្វើឡើងរួមគ្នា លើកលែងតែក្នុងករណីដូចខាងក្រោម អាចដាក់ពាក្យសុំតែម្នាក់ឯងបានៈ

- ការផ្លាស់ប្តូរ ឬការកែតម្រូវតែ ឈ្មោះ អាសយដ្ឋាន ថ្ងៃខែឆ្នាំកំណើត ប្តីប្រពន្ធ ឬបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា។
- ការចុះបញ្ជី ដោយផ្អែកលើសាលក្រម ឬសាលដីកា ឬដីកាសម្រេចស្ថាពរ ប្តីប្រពន្ធ ឬបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ដូចមានចែងនៅក្នុងមាត្រា ៣០ កថាខណ្ឌទី៣ ចំណុច ខ គ ឃ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី។
- រាល់ពាក្យសុំចុះបញ្ជីខាងលើ អ្នកតំណាងក៏អាចកាន់យកមកដាក់នៅចំពោះមុខមន្ត្រីចុះបញ្ជីជំនួសប្តីប្រពន្ធ ឬបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានដែរ។
- បុគ្គល ឬអ្នកតំណាងដែលដាក់ពាក្យសុំចុះបញ្ជី ត្រូវយកពាក្យសុំនោះ មកដាក់នៅនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី នៃក្រសួងយុត្តិធម៌ដោយផ្ទាល់[67]។

នៅពេលដាក់ពាក្យសុំចុះបញ្ជី អ្នកដាក់ពាក្យសុំចុះបញ្ជីទាក់ទងនឹងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដូចជា ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ជាអាទិ៍ ត្រូវផ្តល់ឯកសារចាំបាច់មួយចំនួនទៅឱ្យនាយកដ្ឋានកិច្ចការរដ្ឋប្បវេណីទៅតាមប្រភេទនៃពាក្យសុំចុះបញ្ជីនោះ។ ចំពោះពាក្យសុំចុះបញ្ជីដែលអ្នកតំណាងយកមកដាក់ ត្រូវភ្ជាប់លិខិតប្រគល់សិទ្ធិតំណាងផងដែរ[68]។

ផ្ទុយទៅវិញ ប្រសិនបើមានការផ្លាស់ប្តូរនូវចំណុចដែលបានចុះក្នុងបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ឬបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវដាក់ពាក្យសុំចុះបញ្ជីចំពោះការផ្លាស់ប្តូរនោះ។ ក្នុងករណីប្តីប្រពន្ធបានរំលាយអាពាហ៍ពិពាហ៍ ឬប្រសិនបើបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា បានរំលាយកំជាប់ពាក្យប្តីប្រពន្ធ ឬបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានោះ ត្រូវដាក់ពាក្យលុបចោលការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធជាមួយគ្នា។ ប៉ុន្តែក្នុងករណីប្តី ឬប្រពន្ធ ឬបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានរំលាយកំជាប់ពាក្យប្តីប្រពន្ធ ឬបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានោះ អាចដាក់ពាក្យសុំលុបចោលការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធតែឯកឯងបាន ប្រសិនបើមានមូលហេតុៈ

[67] ប្រការ ១៥ នៃប្រកាសលេខ ៦១ កយ.ស្រក/១៣ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៣ របស់ក្រសួងយុត្តិធម៌ ស្តីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

[68] ប្រការ ១៧ នៃប្រកាសលេខ ៦១ កយ.ស្រក/១៣ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៣ របស់ក្រសួងយុត្តិធម៌ ស្តីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

- បើសហព័ទ្ធណាម្នាក់បានស្លាប់ គឺសហព័ទ្ធដែលនៅរស់។
- បើមានសេចក្ដីសម្រេចអំពីការបែងចែកទ្រព្យសម្បត្តិក្នុងសាលក្រម ឬសាលដីការំលាយអាពាហ៍ពិពាហ៍ ដែលបានចូលជាស្ថាពរ គឺអតីតសហព័ទ្ធណាម្នាក់។
- បើតុលាការបានសម្រេចសេចក្ដីអំពីការបែងចែកទ្រព្យសម្បត្តិ ដោយការរំលាយអាពាហ៍ពិពាហ៍ ដោយផ្អែកលើបញ្ញត្តិនៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ហើយសេចក្ដីសម្រេចនោះចូលជាស្ថាពរ គឺអតីតសហព័ទ្ធណាម្នាក់។
- បើហេតុការណ៍ដែលរំលាយកំជាប់ពាក្យ ត្រូវបានបញ្ជាក់ជាក់លាក់ នៅក្នុងសាលក្រម ឬសាលដីកាស្ថាពរ ដែលសម្រេចអំពីការទាមទារដោយផ្អែកលើហេតុការណ៍រំលាយកំជាប់ពាក្យ គឺភាគីណាម្នាក់[69]។

### ២.៣.១.២ អានុភាពនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

នៅក្នុងកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវធ្វើការចុះបញ្ជី ទើបអាចតតាំងជាមួយតតិយជនបាន។ ក្នុងករណីដែលប្ដីប្រពន្ធបានធ្វើសន្យាផ្សេងពីប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ បើមិនបានចុះបញ្ជីទេ មិនអាចយកកិច្ចសន្យានោះមកតតាំងជាមួយតតិយជនបានឡើយ[70]។ ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ មានអានុភាពនៅពេលដែលចុះហត្ថលេខា និងប្រថាប់ត្រារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌[71]។

នៅពេលប្ដីប្រពន្ធបានសម្រេចចិត្តចុះបញ្ជីទ្រព្យសម្បត្តិប្ដីប្រពន្ធនេះទៅតាមគោលការណ៍ច្បាប់ដែលបានកំណត់ដោយគោរពនូវឆន្ទៈរបស់ភាគីទាំងសងខាង នោះអានុភាពត្រូវមានចំពោះទ្រព្យសម្បត្តិភាគីទាំងពីរ។ ដូចនេះ អានុភាពនៃកិច្ចសន្យា មានទៅលើទំហំទ្រព្យសម្បត្តិដែលសហព័ទ្ធបានចុះបញ្ជី នៅក្នុងកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ។ម្យ៉ាងវិញទៀត ក្រៅពីមានអានុភាពចំពោះភាគី កិច្ចសន្យានេះ ក៏មានអានុភាពចំពោះតតិយជនដែលមានផលប្រយោជន៍នៅក្នុងរង្វង់ទ្រព្យសម្បត្តិរបស់ប្ដីប្រពន្ធនោះផងដែរ តតិយជនអាចស្នើសុំឱ្យចេញលិខិតបញ្ជាក់នៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធនេះបាន ក្នុងគោលដៅរកភាពច្បាស់លាស់មុនសម្រេចចិត្តរកស៊ី ឬធ្វើទំនាក់ទំនងកិច្ចសន្យាផ្សេងៗ។

### ២.៣.២ ប្រព័ន្ធទ្រព្យសម្បត្តិតាមច្បាប់កំណត់

នៅក្នុងសង្គមបច្ចុប្បន្ន បញ្ហាចម្រូងចម្រាស់នៅក្នុងទំនាក់ទំនងប្ដីប្រពន្ធ អំពីការគ្រប់គ្រងប្រើប្រាស់ចាត់ចែង និងបែងចែកទ្រព្យសម្បត្តិអាចនាំទៅរកវិវាទ ទាំងនៅក្នុងពេលជាប់ចំណងអាពាហ៍ពិពាហ៍ ក៏ដូចជានៅ

---

[69] មាត្រា ៣០ នៃច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ឆ្នាំ២០១១

[70] មាត្រា ៩៧០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[71] ប្រការ ៣៦ នៃប្រកាសលេខ ៦១ កយ.ស្រក/១៣ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៣ របស់ក្រសួងយុត្តិធម៌ ស្ដីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

ពេលលែងលះ។ ដើម្បីបង្ការ និងដោះស្រាយវិវាទទាំងនេះ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា បានចែងអំពីប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិប្តីប្រពន្ធ។ ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិប្តីប្រពន្ធ ជាមូលដ្ឋានរួមមាន ប្រព័ន្ធទ្រព្យសម្បត្តិដោយឡែក ដែលជាប្រព័ន្ធមិនធ្វើឱ្យមានផលប៉ះពាល់ដល់ទំនាក់ទំនងទ្រព្យសម្បត្តិប្តីប្រពន្ធ នោះទេ ទោះបីជាបានរៀបអាពាហ៍ពិពាហ៍ហើយក៏ដោយ។ មួយទៀតគឺ ប្រព័ន្ធទ្រព្យសម្បត្តិរួម ដែលជាប្រព័ន្ធ នឹងមានផលប៉ះពាល់ទៅដល់ទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ នៅក្រោយពេលរៀបអាពាហ៍ពិពាហ៍ ហើយទ្រព្យទាំង នោះត្រូវក្លាយជាទ្រព្យរួម[72]។

**២.៣.២.១ ទ្រព្យសម្បត្តិដោយឡែក**

ដោយយោងតាមមាត្រា ៩៧២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ទ្រព្យដោយឡែក គឺជាទ្រព្យសម្បត្តិដែល មានកំណត់ខាងក្រោមនេះ ដែលវាស្ថិតនៅក្រោមកម្មសិទ្ធិរបស់សហព័ទ្ធណាម្នាក់៖

- ទ្រព្យសម្បត្តិដែលប្តី ឬប្រពន្ធមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍ មានន័យថាភាគីប្តី ឬប្រពន្ធមាន ទ្រព្យនោះ នៅមុនពេលរៀបអាពាហ៍ពិពាហ៍ ទោះបីក្រោយរៀបអាពាហ៍ពិពាហ៍ក៏ដោយ ក៏គេចាត់ទុកថា ទ្រព្យនោះ ជាទ្រព្យដោយឡែករបស់ប្តី ឬប្រពន្ធនោះដដែល។ ឧទាហរណ៍៖ ប្តីមានផ្ទះមួយល្វែងមុន ពេលរៀបអាពាហ៍ពិពាហ៍ ទោះក្រោយរៀបអាពាហ៍ពិពាហ៍ ក៏ផ្ទះនោះ នៅតែជាទ្រព្យរបស់ប្តីដដែល គឺ មិនអាចរាប់ជាទ្រព្យរួមនោះទេ។
- ទ្រព្យសម្បត្តិដែលប្តី ឬប្រពន្ធទទួលបានដោយប្រទានកម្ម សន្តតិកម្ម ឬអច្ច័យទាន នៅក្នុងអំឡុងពេល អាពាហ៍ពិពាហ៍។ក្នុងករណីប្រសិនបើម្ចាស់អំណោយឱ្យទ្រព្យទៅប្តីឬប្រពន្ធនោះមានន័យថា អំណោយ នោះនឹងក្លាយទៅជាទ្រព្យដោយឡែករបស់ប្តី ឬប្រពន្ធនោះ។ លើកលែងតែម្ចាស់អំណោយបានបញ្ជាក់ ថាឱ្យទាំងប្តី និងប្រពន្ធ ទើបទ្រព្យនោះក្លាយទៅជាទ្រព្យរួមរបស់ប្តី និប្រពន្ធ ។ ឧទាហរណ៍៖ ឪពុករបស់ លោក "ក" បានប្រគល់ផ្ទះមួយល្វែងឱ្យគាត់នៅក្នុងពេលចំណងអាពាហ៍ពិពាហ៍។ នោះ គេចាត់ទុកថា ផ្ទះនោះជាទ្រព្យដោយឡែករបស់លោក"ក" ទោះបីជាទ្រព្យនោះបានមកក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ក៏ដោយ។
- ទ្រព្យសម្បត្តិជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដែលសហព័ទ្ធមាន នៅមុនពេលរៀប អាពាហ៍ពិពាហ៍ ឬទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបានដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅ ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។ ឧទាហរណ៍៖ ប្តីមានផ្ទះមួយខ្នងដែលជាទ្រព្យដោយឡែករបស់ខ្លួន ក្រោយមកនៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ប្តីបានលក់ផ្ទះនោះក្នុងតម្លៃ៥ម៉ឺនដុល្លារ ដូច្នេះប្រាក់ដែល បានមកពីការលក់ផ្ទះនោះ ក៏គេចាត់ទុកថាជាទ្រព្យរបស់ប្តីដដែល ទោះបីជាប្តីលក់នៅក្នុងអំឡុងពេល

[72] គេហទំព័រ http://freshnewsasia.com/index.php/en/localnews/98271-2018-09-09-03-41-20.html

ជីវិតអាពាហ៍ពិពាហ៍ក៏ដោយ។ ម្យ៉ាងវិញទៀត ប្រសិនបើប្ដីយកលុយនោះទៅទិញដីហើយ លក់ទៅវិញបានប្រាក់ចំណេញបន្ថែមទៀតក៏ដោយ ក៏វានៅតែជាទ្រព្យដោយឡែករបស់ប្ដី ព្រោះផលចំណេញនោះកើតចេញពីតម្លៃតបនៃវត្ថុដែលជាទ្រព្យដោយឡែករបស់ប្ដី[73]។

មាត្រាខាងលើនេះបានកំណត់អំពីវិសាលភាពនៃទ្រព្យសម្បត្តិដោយឡែក ហើយទ្រព្យសម្បត្តិដែលមានមុនពេលរៀបអាពាហ៍ពិពាហ៍ ទ្រព្យសម្បត្តិដែលទទួលបានតាមរយៈប្រទានកម្ម សន្តតិកម្ម អច្ច័យទាន និងទ្រព្យដែលទទួលបានតាមរយៈការចាត់ចែងទ្រព្យសម្បត្តិដោយឡែកផ្សេងទៀត នឹងត្រូវរាប់ជាទ្រព្យដោយឡែក។ នៅពេលដែលរស់នៅក្នុងទំនាក់ទំនងអាពាហ៍ពិពាហ៍កាន់តែយូរទៅ មានករណីជាច្រើនដែលទ្រព្យសម្បត្តិមានមុនពេលរៀបអាពាហ៍ពិពាហ៍ និងទ្រព្យសម្បត្តិដែលទទួលបានក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍ ក្លាយទៅជាមិនអាចបែងចែកច្បាស់លាស់ថា ជាទ្រព្យដោយឡែក ឬជាទ្រព្យរួម កត្តាទាំងអស់នេះហើយអាចបណ្ដាលឱ្យក្លាយទៅជាវិវាទ។

ហេតុដូច្នេះ ច្បាប់ក៏បានបង្កើតប្រព័ន្ធកិច្ចសន្យាទ្រព្យសម្បត្តិរបស់ប្ដីប្រពន្ធ ត្រូវបានធ្វើឡើង ដើម្បីទប់ស្កាត់វិវាទលើទំនាក់ទំនងទ្រព្យសម្បត្តិ និងដើម្បីបញ្ជាក់ឱ្យបានច្បាស់អំពីទំនាក់ទំនងសិទ្ធិ និងករណីកិច្ចរបស់ប្ដីប្រពន្ធ ព្រមទាំងនីតិវិធីនៃការចុះបញ្ជីទ្រព្យសម្បត្តិរបស់ប្ដីប្រពន្ធ ដើម្បីបញ្ជាក់ឱ្យច្បាស់ជាមុនថា ទ្រព្យសម្បត្តិណាខ្លះ ជាទ្រព្យដោយឡែក ហើយទ្រព្យសម្បត្តិណាខ្លះ ដែលជាទ្រព្យរួម ដូចបានបកស្រាយនៅក្នុងចំណុច ២.៣.១ (ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា)និងចំណុច ២.៣.១.១(នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ)។

ម្យ៉ាងទៀត ប្ដីប្រពន្ធដែលកំពុងមានចំណងអាពាហ៍ពិពាហ៍ជាមួយគ្នា មានសិទ្ធិអាស្រ័យនៅលើទ្រព្យសម្បត្តិដោយឡែកនោះផងដែរ មានន័យថា ប្ដីប្រពន្ធម្ខាងអាចអាស្រ័យនៅអចលនវត្ថុដែលជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធម្ខាងទៀត ហើយដែលត្រូវបានប្រើប្រាស់សម្រាប់ការអាស្រ័យនៅរបស់គ្រួសារបាន បើទោះបីជា សហព័ទ្ធម្ខាងទៀតបានចាត់ចែងអចលនវត្ថុនោះក៏ដោយ ក៏អាចបន្តអាស្រ័យនៅអចលនវត្ថុនោះបានដែរ[74]។

### ២.៣.២.២ ទ្រព្យសម្បត្តិរួម

យោងតាមមាត្រា ៩៧៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិទាំងឡាយដែលប្ដីប្រពន្ធទាំងសងខាង ឬ តែម្ខាងទទួលបាននៅអំឡុងពេលអាពាហ៍ពិពាហ៍ក្នុងលក្ខណៈជាប្រាក់បៀវត្សរ៍ ឬ ប្រាក់ឈ្នួល ឬ ប្រាក់កម្រៃ ឬ ប្រយោជន៍នានា លើកលែងតែទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបាន ដោយ

[73] អត្ថបទយល់ដឹងផ្នែកច្បាប់ ទ្រព្យរួម និងទ្រព្យដោយឡែករបស់ប្ដីប្រពន្ធ រៀបរៀងដោយ លោកមេធាវី សេង ឈុនលី អនុប្រធានក្រុមមេធាវី និងកញ្ញា សាំង សុភាព សមាជិកក្រុមការងាររៀបចំ និងផ្សព្វផ្សាយអត្ថបទច្បាប់ នៃក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ។
[74] មាត្រា៩៧៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ និង ទ្រព្យសម្បត្តិជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិនោះ ដូចបានបកស្រាយក្នុងចំណុច ២.៣.២.១ (ទ្រព្យសម្បត្តិដោយឡែក)។

ឧទាហរណ៍៖ ប្ដីធ្វើការជាមន្ត្រីរាជការ និងទទួលបានប្រាក់បៀវត្សរ៍ ១លានរៀល ក្នុងមួយខែ ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។ ហេតុដូច្នេះហើយប្រាក់បៀវត្សរ៍របស់ប្ដី ត្រូវចាត់ទុកជាទ្រព្យសម្បត្តិរួមរបស់ប្ដី និងប្រពន្ធ។

ក្នុងករណីប្រាក់ចំណូលដែលប្ដីរកបានតែម្ខាង ហើយប្រពន្ធត្រឹមតែជាស្ត្រីមេផ្ទះ ធ្វើតែការងារគេហកិច្ច (ការងារក្នុងផ្ទះ) តើប្រាក់ចំណូលដែលប្ដីរកបានតែម្ខាងត្រូវចាត់ទុកថា ជាទ្រព្យរួម ឬ ទ្រព្យដោយឡែក?

ពាក់ព័ន្ធនឹងករណីខាងលើ យោងតាមមាត្រា៣៦ វាក្យខ័ណ្ឌទី៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់យ៉ាងច្បាស់ថា ការងារមេផ្ទះ មានតម្លៃស្មើគ្នានឹងកម្រៃដែលបានមកពីការងារធ្វើនៅក្រៅផ្ទះ។ មានន័យថា ប្ដីមិនអាចបដិសេធចំពោះចំណូលដែលខ្លួនរកបានពីការងារក្រៅផ្ទះ ថាមិនមែនជាទ្រព្យរួម ឬបន្ថយសិទ្ធិរបស់ប្រពន្ធលើចំណូលរបស់ខ្លួន ដោយសំអាងថាប្រពន្ធរបស់ខ្លួនធ្វើតែការងារផ្ទះ មើលថែទាំកូន ដាំស្ល បោកគក់ ដោយមិនបានប្រឡូកនឹងការងារខាងក្រៅដែលនឿយហត់ដូចការងាររបស់ខ្លួនឡើយ។

ក្នុងករណីមានបំណុលរួម ប្ដីប្រពន្ធត្រូវតែទទួលខុសត្រូវរួមគ្នា ទោះបីជាបំណុលនោះ ប្ដីប្រពន្ធទាំងពីរជាអ្នកខ្ចីរួមគ្នា ឬក៏សហព័ទ្ធណាម្នាក់ជាអ្នកខ្ចី ឱ្យតែមានការព្រមព្រៀងជាលាយល័ក្ខណ៍អក្សរពីសហព័ទ្ធម្ខាងទៀត។ ប៉ុន្តែបើទោះបីជាគ្មានការព្រមព្រៀងជាលាយល័ក្ខណ៍អក្សរពីសហព័ទ្ធម្ខាងទៀតក៏ដោយក៏អាចចាត់ទុកថាជាបំណុលរួមបានផងដែរ ប្រសិនបើបំណុលនោះ ស្ថិតក្រោមរូបភាពជាបំណុលដែលជាប់ពាក់ព័ន្ធនឹងការរក្សាជីវភាពរួមរបស់ប្ដីប្រពន្ធ ការអប់រំ ការថែទាំ និងព្យាបាលកូន បំណុលដែលជាប់ពាក់ព័ន្ធនឹងការគ្រប់គ្រង និងរក្សាទ្រព្យសម្បត្តិរួម ដូចបានបកស្រាយនៅក្នុងចំណុច ២.២.២.៣ (ការទទួលខុសត្រូវដោយសាមគ្គីភាព)។

## ២.៤ ការគ្រប់គ្រង និង ការប្រើប្រាស់ទ្រព្យសម្បត្តិ

ចំពោះការរស់នៅក្នុងចំណងអាពាហ៍ពិពាហ៍ជាមួយគ្នា ប្ដីប្រពន្ធគ្រប់រូបមានកាតព្វកិច្ចគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិរួមរបស់ខ្លួនឱ្យបានត្រឹមត្រូវ ជារួមមក នៅក្នុងច្បាប់ក៏បានបញ្ញត្តិយ៉ាងច្បាស់លាស់ចំពោះការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិរួមមានៈ ប្ដីប្រពន្ធ មានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ ទទួលផលប្រយោជន៍ និងគ្រប់គ្រងទ្រព្យសម្បត្តិរួម នៅក្នុងទំហំដែលចាំបាច់ ដោយផ្អែកលើការចាំបាច់នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ហើយសហព័ទ្ធត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរួម ដោយសហការគ្នា និងអាចទាមទារចំពោះភាគីម្ខាងទៀតឱ្យធ្វើចំណាត់ការដែលចាំបាច់ដើម្បីគ្រប់គ្រង និងរក្សាទុកនូវទ្រព្យសម្បត្តិរួមបាន ប៉ុន្តែនៅក្នុងករណីដែលការពិភាក្សាអំពីការគ្រប់គ្រង ឬ ប្រើប្រាស់ទ្រព្យសម្បត្តិរបស់ប្ដីប្រពន្ធ មិនមានប្រសិទ្ធិភាពនោះទេ ភាគីម្ខាងទៀតអាចទាមទារទៅតុលាការឱ្យធ្វើការចាត់ចែងចំពោះការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិរួមបាន[75]។

[75] មាត្រា៩៧៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

## ២.៥ ការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ

ក្រមរដ្ឋប្បវេណីបានបញ្ញត្តិអំពីការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធដូចខាងក្រោម៖

- បើគ្មានការយល់ព្រមពីប្តីប្រពន្ធទាំងសងខាងទេ ទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធមិនអាចយកទៅលក់ ឬធ្វើការចាត់ចែងផ្សេងទៀតបានឡើយ។
- ប្រសិនបើស្ថានភាពមិនអាចជៀសបាន សម្រាប់ការថែទាំជីវភាពរួមក្នុងអាពាហ៍ពិពាហ៍ និងដើម្បីរក្សាជីវភាពរស់នៅ ករណីនេះប្តីប្រពន្ធណាម្ខាងអាចលក់ ឬធ្វើការចាត់ចែងផ្សេងទៀតបាននូវទ្រព្យសម្បត្តិរួមដោយទទួលការអនុញ្ញាតពីតុលាការ។
- ក្នុងករណីដែលប្តី ឬ ប្រពន្ធណាម្ខាង បានលក់ ឬធ្វើការចាត់ចែងផ្សេងទៀតនូវទ្រព្យសម្បត្តិរួម ដោយគ្មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតផងនិងគ្មានការអនុញ្ញាតពីតុលាការផង សហព័ទ្ធដែលមិនបានផ្តល់ការយល់ព្រម អាចទាមទារឱ្យលុបចោលនូវការចាត់ចែងនោះ ទៅតុលាការបាន នៅក្នុងអំឡុងពេល ០២ឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះ ជាអចលនវត្ថុ និងនៅក្នុងអំឡុងពេល ០១ឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះ ជាទ្រព្យសម្បត្តិផ្សេង[76]។

[76] មាត្រា៩៧៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានចំណាយពេលក្នុងការសិក្សាស្រាវជ្រាវ និងចងក្រងអត្ថបទសារណានេះមក នាងខ្ញុំបានកត់សម្គាល់ឃើញថា ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស គឺមិនមានភាពខុសគ្នាពីការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរជាមួយនឹងពលរដ្ឋខ្មែរប៉ុន្មាននោះទេ ព្រោះអាពាហ៍ពិពាហ៍នោះ ត្រូវបានប្រារព្ធធ្វើឡើងនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលត្រូវបានធ្វើឡើងស្របទៅតាមគោលការណ៍ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា គ្រាន់តែមានចំណុចខុសគ្នាចំពោះនីតិវិធីនៃការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍បន្តិចបន្តួចតែប៉ុណ្ណោះ។

ដូចនេះ ចំពោះជនបរទេសដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ជាមួយនឹងពលរដ្ឋខ្មែរដោយស្របច្បាប់ គឺត្រូវដាក់ពាក្យសុំទៅតាមលំហូរនៃនីតិវិធីរបស់ប្រទេសកម្ពុជា ដែលរួមមានជាអាទិ៍ ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅក្រសួងមហាផ្ទៃ និងការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋាន ឃុំសង្កាត់ជាដើម។

អាពាហ៍ពិពាហ៍ដែលធ្វើឡើងស្របទៅតាមនីតិវិធីច្បាប់ គឺជាបញ្ហាដ៏សំខាន់ដែលប្រជាពលរដ្ឋគ្រប់រូបត្រូវតែមានការយកចិត្តទុកដាក់ ពីព្រោះថា អាពាហ៍ពិពាហ៍គឺជាអ្វីដែលមនុស្សត្រូវជួបប្រទះក្នុងឆាកជីវិត ហើយអាពាហ៍ពិពាហ៍បានបង្កើតនូវចំណងនិស្ស័យរវាងបុរស និងនារី ដែលសន្យាថារស់នៅជាមួយគ្នាអស់មួយជីវិត តែប្រសិនបើមានបញ្ហាណាមួយកើតឡើងដូចជា ការជិតក្បត់ គឺមានតែច្បាប់ទេដែលអាចជួយដោះស្រាយបញ្ហា និងការពារផលប្រយោជន៍សាមីជននោះបាន។

ជាក់ស្តែងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា បានកំណត់យ៉ាងច្បាស់អំពីការរៀបអាពាហ៍ពិពាហ៍ដែលអាចមានអានុភាពតាមផ្លូវច្បាប់ និងការហាមឃាត់ផ្សេងៗ ដើម្បីបង្ការកុំឱ្យមានបញ្ហានៅថ្ងៃក្រោយ ដូចជាការកំណត់អំពីអាយុនៃជនដែលអាចរៀបអាពាហ៍ពិពាហ៍ កំណត់អំពីឆន្ទៈដើម្បីឱ្យច្បាស់ថា អាពាហ៍ពិពាហ៍នោះមិនត្រូវបានកើតឡើង ក្រោមការបង្ខិតបង្ខំ ការហាមឃាត់មិនឱ្យមានការរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិតញាតិពន្ធ និងការហាមឃាត់មិនឱ្យមានការរៀបអាពាហ៍ពិពាហ៍ធ្វើឡើងតាមរយៈភ្នាក់ងារជ្រើសរើសគូស្រករជាដើម។ពិសេសជាងនេះទៅទៀត នៅពេលដែលជនបរទេសបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងពលរដ្ឋខ្មែរ ច្បាប់មិនត្រឹមតែទទួលស្គាល់ចំណងអាពាហ៍ពិពាហ៍ និងការពារផលប្រយោជន៍ពាក់ព័ន្ធនឹងទ្រព្យសម្បត្តិ របស់ជននោះប៉ុណ្ណោះនោះទេ ថែមទាំងទទួលបានសិទ្ធិមួយចំនួនស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដូចជា សិទ្ធិទទួលបានសញ្ជាតិជាពលរដ្ឋខ្មែរ សិទ្ធិទទួលបានសន្តតិកម្ម និងសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លីជាដើម។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានសិក្សាស្រាវជ្រាវ និងចងក្រងនូវអត្ថបទសារណា ព្រមទាំងទទួលបានការពន្យល់ណែនាំបន្ថែមពីលោកសាស្ត្រាចារ្យ **ហ៊ីង គឹមឡេង** រួចមក ធ្វើឱ្យនាងខ្ញុំបានយល់ដឹងបន្ថែមអំពីបញ្ហាដែលទាក់ទងទៅនឹងការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ព្រមទាំងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសផងដែរ ព្រោះការរៀបអាពាហ៍ពិពាហ៍ មិនត្រឹមតែផ្សារភ្ជាប់ចំណងញាតិរវាងគ្នា និងគ្នានោះទេ សូម្បីតែសិទ្ធិ និងករណីកិច្ចមួយចំនួនដែលច្បាប់បានកំណត់ក៏ត្រូវបានផ្សារភ្ជាប់ចំពោះជននោះផងដែរ។

អាពាហ៍ពិពាហ៍ គឺជាបញ្ហាដ៏ធំមួយដែលពលរដ្ឋគ្រប់រូបគ្រូវគប្បីត្រូវយកចិត្តទុកដាក់ ព្រោះថាប្រសិនបើប្រជាពលរដ្ឋមិនបានយល់ដឹងពីមូលដ្ឋានច្បាប់ពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ ការរៀបអាពាហ៍ពិពាហ៍នោះអាចនាំឱ្យមានបញ្ហានៅថ្ងៃក្រោយ និងធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគី។

ម្យ៉ាងទៀត នាងខ្ញុំសង្កេតឃើញថា ប្រជាពលរដ្ឋខ្មែរយើងមួយចំនួន នៅតែមានកង្វះខាតក្នុងការយល់ដឹងពាក់ព័ន្ធនឹងច្បាប់នៃការរៀបអាពាហ៍ពិពាហ៍នេះ ជាពិសេសប្រជាពលរដ្ឋនៅតាមជនបទ ដែលភាគច្រើនពួកគាត់គិតថា ការរៀបអាពាហ៍ពិពាហ៍ទៅតាមប្រពៃណីទំនៀមទម្លាប់ គឺជាការគ្រប់គ្រាន់ហើយ។ បន្ថែមទៅលើចំណុចនេះ នាងខ្ញុំក៏សង្កេតឃើញថា ប្រព័ន្ធនៃការផ្សព្វផ្សាយច្បាប់នៅក្នុងប្រទេសកម្ពុជាយើង នៅមានកម្រិតនៅឡើយ រួមផ្សំនឹងកត្តាជីវភាព និងទីតាំងភូមិសាស្ត្ររបស់ប្រជាជន ដែលជាបញ្ហាចម្បងធ្វើឱ្យប្រជាពលរដ្ឋខ្មែរមួយចំនួនខ្វះការយល់ដឹងអំពីផលប៉ះពាល់ផ្សេងៗនៃការមិនគោរពទៅតាមនីតិវិធីដែលច្បាប់កំណត់។

នាងខ្ញុំសង្ឃឹមថា ស្ថាប័នគ្រប់ជាន់ថ្នាក់ដែលមានសមត្ថកិច្ច ពិសេស ក្រសួងយុត្តិធម៌ ដែលជាស្ថាប័នច្បាប់មួយដ៏សំខាន់នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងអង្គការជាតិ និងអង្គការអន្តរជាតិពាក់ព័ន្ធ នឹងចូលរួមយ៉ាងសកម្មក្នុងការបណ្តុះបណ្តាលប្រជាពលរដ្ឋឱ្យមានការយល់ដឹងអំពីច្បាប់កាន់តែទូលំទូលាយ មិនត្រឹមតែចំពោះនិស្សិតច្បាប់ ឬមន្ត្រីអនុវត្តច្បាប់នោះទេ ដើម្បីឱ្យការផ្សព្វផ្សាយច្បាប់ និងការអនុវត្តច្បាប់ទទួលបានប្រសិទ្ធភាពខ្ពស់ និងប្រកបដោយនិរន្តភាព។

ជាចុងក្រោយ នាងខ្ញុំជឿជាក់ថា នៅពេលដែលប្រជាពលរដ្ឋខ្មែរយើងមានចំណេះដឹងទូលំទូលាយ អំពីការរៀបអាពាហ៍ពិពាហ៍នេះ នោះពួកគាត់នឹងយល់អំពីផលប្រយោជន៍នៃការគោរពច្បាប់ និងប្រតិបត្តិតាមជាក់ជាមិនខាន ពិសេស ពួកគាត់នឹងយល់ដឹងអំពីផលប៉ះពាល់ផ្សេងៗអំពីការដែលមិនគោរពទៅតាមនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍នេះ។

# ឯកសារយោង

# ឯកសារយោង

## ១.រដ្ឋធម្មនុញ្ញ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣

## ២.លិខិតបទដ្ឋានអន្តរជាតិ

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងពិធីសារបន្ថែម ខែតុលា ឆ្នាំ២០០៩

## ៣.ក្រម

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ តាមព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

## ៤.ច្បាប់

១.ច្បាប់ស្តីពីឯកពន្ធភាព ប្រកាសឱ្យប្រើ តាមព្រះរាជក្រមលេខ នស/រកម/១០០៦/០២៦ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៦

២.ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រកាសឱ្យប្រើ តាមព្រះរាជក្រមលេខ នស/រកម/០២០៨/០០៥ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨

៣.ច្បាប់ស្តីពីសញ្ជាតិ ប្រកាសឱ្យប្រើ តាមព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨

៤.ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ប្រកាសឱ្យប្រើ តាមព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១

៥.ច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេសប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៥១០/០០៦ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១០

## ៥.បទបញ្ញា

១.អនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន

២.អនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

៣.អនុក្រឹត្យលេខ ១១២ អនក្រ.បក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ ស្តីពី ការអនុវត្តច្បាប់ស្តីពីសញ្ជាតិ

**៦.ប្រកាស**

១.ប្រកាសលេខ ៦១ កយ.ស្រក/១៣ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៣ របស់ក្រសួងយុត្តិធម៌ ស្តីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

២.ប្រកាសរួមលេខ១០៣៩ សហវ ប្រក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៦ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

៣.ប្រកាសអន្តរក្រសួងលេខ ១៤៣៤២ ប្រក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

៤.ប្រកាសអន្តរក្រសួងលេខ ១៤៤១៤ ប្រក ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់ក្រសួងមហាផ្ទៃ

**៧.សេចក្តីណែនាំ**

សេចក្តីណែនាំលេខ ០០១ សណន ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៩ ស្តីពី ការអនុវត្តអនុក្រឹត្យស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

**៨.សន្ទានុក្រម**

សន្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី ដែលត្រូវបានរៀបចំដោយគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ និងបោះពុម្ពដោយទីស្តីការគណៈរដ្ឋមន្ត្រី នៅឆ្នាំ ២០០៧

**៩.ឯកសារស្រាវជ្រាវតាមរយៈអ៊ីនធឺណែត**

១.កម្រងឯកសារស្តីពី របៀបកត់ត្រាការងារអត្រានុកូលដ្ឋាន (http://cdslawcambodia.com/wp-content/uploads /2018/12/២០០៥ -អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន.pdf

២. www.ciclg.com, ហ្វេសបុកផេក៖ ក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ / Cambodia International Cooperation Law Group

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១

- អនុក្រឹត្យស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

## ឧបសម្ព័ន្ធទី២

- អនុក្រឹត្យស្តីពីអគ្រានុកូលដ្ឋាន

## ឧបសម្ព័ន្ធទី៣

- សេចក្តីណែនាំស្តីពី ការអនុវត្តអនុក្រឹត្យស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

# ឧបសម្ព័ន្ធទី១

# អនុក្រឹត្យស្តីពីការកំណត់បែបបទ និង នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរ និងជនបរទេស

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៨៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរ និងជនបរទេស

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញក្រឹត្យលេខ ៥៦ក្រ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានឃើញព្រះរាជក្រមលេខ ០៥ នស ៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអន្តោប្រវេសន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៥ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ

www.pheakdeylaw.com

- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៦/០២៦ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីឯកពន្ធភាព
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីបែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា រវាងពលរដ្ឋខ្មែរ និងជនបរទេស ។

**មាត្រា ២.-**

ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសត្រូវផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត និងឆន្ទៈផ្ទាល់របស់សាមីខ្លួន និងត្រូវអនុវត្តតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនានា នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣.-**

ត្រូវបានហាមឃាត់ដាច់ខាតចំពោះអាពាហ៍ពិពាហ៍ដែលធ្វើឡើងតាមរយៈភ្នាក់ងាររើសគូស្រករ ឈ្មួញកណ្តាល ឬក្រុមហ៊ុនអាជីវកម្ម ។

**មាត្រា ៤.-**

ត្រូវបានហាមឃាត់ដាច់ខាតចំពោះអាពាហ៍ពិពាហ៍ក្លែងក្លាយ បោកបញ្ឆោត ក្នុងគោលបំណងកេងប្រវ័ញ្ចពលកម្ម ជួញដូរមនុស្ស ឬធ្វើអាជីវកម្មផ្លូវភេទ ។

www.pheakdeylaw.com

# ជំពូកទី ២
# បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរនិងជនបរទេស

**មាត្រា ៥.-**

ជនបរទេសដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ ចាំបាច់ត្រូវមានវត្តមាននៅព្រះរាជាណាចក្រកម្ពុជាដើម្បីបំពេញបែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ ។

**មាត្រា ៦.-**

ដើម្បីរៀបអាពាហ៍ពិពាហ៍បានជាមួយពលរដ្ឋខ្មែរ សាមីខ្លួនជនបរទេសត្រូវបំពេញបែបបទទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា ដោយភ្ជាប់នូវសំណុំឯកសារដូចខាងក្រោម :

- ពាក្យសុំរៀបអាពាហ៍ពិពាហ៍
- ឯកសារថតចម្លងនៃ លិខិតឆ្លងដែនរបស់សាមីខ្លួនជនបរទេសមានទិដ្ឋាការចូលប្រទេសកម្ពុជា ដែលនៅមានសុពលភាព
- លិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយ ចេញដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស
- លិខិតបញ្ជាក់សុខភាពចេញដោយសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា
- លិខិតថ្កោលទោសចេញដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស
- លិខិតបញ្ជាក់អំពីមុខរបរពិតប្រាកដរបស់សាមីខ្លួនជនបរទេសដែលធានាដល់ជីវភាពរស់នៅចេញដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស ។

ឯកសារថតចម្លងនៃលិខិតឆ្លងដែន និងលិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយ ត្រូវមានបញ្ជាក់នីត្យានុកូលភាពពីស្ថានទូត ឬស្ថានតំណាងនៃប្រទេសរបស់សាមីខ្លួនជនបរទេស ប្រចាំព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៧.-**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជាមានភារកិច្ចពិនិត្យ និងផ្តល់យោបល់លើសំណុំឯកសាររបស់ជនបរទេសដែលសុំរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ និងត្រូវជូនដំណឹងទៅសាមីខ្លួនជនបរទេសវិញ ក្នុងរយៈពេលយ៉ាងយូរ០៥ថ្ងៃការងារ ។ ក្រោយពីបានពិនិត្យ និងផ្តល់យោបល់លើសំណុំឯកសាររបស់ជនបរទេសហើយ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវបញ្ជូនសំណុំឯកសារទាំងនោះទៅក្រសួងមហាផ្ទៃ និងជូនពត៌មានទៅស្ថាប័នពាក់ព័ន្ធ ។

www.pheakdeylaw.com

**មាត្រា ៨.-**

បន្ទាប់ពីទទួលសំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍របស់ជនបរទេសពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងមហាផ្ទៃមានភារកិច្ច ៖

- ចុះបញ្ជីសំណុំឯកសាររបស់ជនបរទេសនោះ និងត្រូវជូនដំណឹងទៅសាមីខ្លួនជនបរទេសវិញ ក្នុងរយៈពេលយ៉ាងយូរ ០៥ថ្ងៃការងារ ។
- ជូនដំណឹងអំពីការសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ ។
- ពិនិត្យនីត្យានុកូលភាពលើសំណុំឯកសារដែលចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ ។

**មាត្រា ៩.-**

សាមីខ្លួនជនបរទេស បន្ទាប់ពីបានទទួលការពិនិត្យ និងផ្តល់យោបល់លើសំណុំឯកសារ និងបានចុះបញ្ជីសំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍រួចហើយ ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ ។

ចំពោះសាមីខ្លួនពលរដ្ឋខ្មែរ ដែលត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេសនោះ ក៏ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍ដែលខ្លួនរស់នៅដោយមានភ្ជាប់នូវសំណុំឯកសារដូចខាងក្រោម ៖

- ពាក្យសុំរៀបអាពាហ៍ពិពាហ៍
- សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់សាមីខ្លួនពលរដ្ឋខ្មែរ
- លិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយ ចេញដោយមេឃុំ ឬចៅសង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ
- លិខិតបញ្ជាក់សុខភាពចេញដោយមន្ទីរពេទ្យ ដែលទទួលស្គាល់ជាផ្លូវការពីក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

ពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងសំណុំឯកសារសាមីខ្លួនជាពលរដ្ឋខ្មែរ និងជនបរទេសត្រូវដាក់ស្របពេលជាមួយគ្នា ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ ដោយអនុវត្តតាមទម្រង់បែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន ។

**មាត្រា ១០.-**

មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់មានភារកិច្ច ពិនិត្យ និងសំរេចលើពាក្យស្នើសុំរៀបអាពាហ៍ពិពាហ៍របស់

www.pheakdeylaw.com

សាមីខ្លួនបុរស និងនារី ក្នុងរយៈពេលយ៉ាងយូរ ០៣ថ្ងៃការងារ បន្ទាប់ពីបានទទួលពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងសំណុំឯកសារភ្ជាប់ ។

បន្ទាប់ពីពិនិត្យពាក្យសុំ និងសំណុំឯកសារភ្ជាប់របស់សាមីខ្លួនបុរស និងនារី បានត្រឹមត្រូវតាមគោលការណ៍ច្បាប់រួចហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវរៀបចំប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ដោយមានវត្តមានផ្ទាល់របស់សាមីខ្លួនបុរស និងនារី ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ ។

ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍នេះត្រូវបិទផ្សាយរយៈពេល១០ថ្ងៃ នៅស្ថានទូត ឬស្ថានតំណាងនៃប្រទេសសាមីខ្លួនជនបរទេសប្រចាំនៅព្រះរាជាណាចក្រកម្ពុជា នៅលំនៅដ្ឋានអចិន្ត្រៃយ៍ និងនៅសាលាឃុំ សង្កាត់ នៃសាមីខ្លួនពលរដ្ឋខ្មែរ ស្របតាមការកំណត់ក្នុងបែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន ។ ផុតរយៈពេល១០ថ្ងៃ ប្រសិនគ្មានការប្តឹងតវ៉ាឬប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះ ទើបសាមីខ្លួនបុរស និងនារីអាចរៀបអាពាហ៍ពិពាហ៍បាន ។

**មាត្រា ១១.-**

អាពាហ៍ពិពាហ៍នឹងមានអនុភាពពេញលក្ខណៈច្បាប់បានលុះត្រាតែសាមីខ្លួនបុរស និងនារី ចុះកិច្ចសន្យាអាពាហ៍ពិពាហ៍តាមរយៈការចុះបញ្ជីអាពាហ៍ពិពាហ៍ដោយសាមីខ្លួនផ្ទាល់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន នៃឃុំ សង្កាត់ ដែលសាមីខ្លួនទាំងពីរបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ដោយនាំមកជាមួយនូវសាក្សីគ្រប់អាយុការចំនួន ០២រូបផង ស្របទៅតាមទម្រង់បែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន ។

**មាត្រា ១២.-**

ក្រសួងមហាផ្ទៃត្រូវធ្វើសេចក្តីណែនាំដល់មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងអង្គភាពក្រោមឱវាទដែលពាក់ព័ន្ធ អំពីគំរូលិខិតស្នាម បែបបទ និងនីតិវិធីជាក់ស្តែងបន្ថែមទៀតទាក់ទងការសុំរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ។

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិត្រូវធ្វើសេចក្តីណែនាំអំពីគំរូលិខិតស្នាម បែបបទ និងនីតិវិធីជាក់ស្តែងបន្ថែមទៀតទាក់ទងការសុំរៀបអាពាហ៍ពិពាហ៍របស់ជនបរទេសជាមួយពលរដ្ឋខ្មែរ ។

## ជំពូកទី ៣

## អវសានប្បញ្ញត្តិ

**មាត្រា ១៣.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

www.pheakdeylaw.com

**មាត្រា ១៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ**

**ហោ ណាំហុង**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៤
- គ្រប់សាលាខេត្ត ក្រុង
- ឯកសារ កាលប្បវត្តិ

www.pheakdeylaw.com

# ឧបសម្ព័ន្ធទី២
# អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាល**

**លេខ :** ១០៣ អនក្រ បក

# អនុក្រឹត្យ
# ស្តីពី
# អគ្គានុកូលដ្ឋាន
# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១/៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ៥៦ ក្រ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៨៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម ០១/៩៦ /០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌

តាមការឯកភាពរបស់គណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០០

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់បែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២.-**

អត្រានុកូលដ្ឋាន គឺជាចំណងរួមភ្ជាប់សញ្ជាតិទៅនឹងរដ្ឋ និងស្ថានភាពជាក់ស្តែង ដែលជននោះមាននៅក្នុងត្រកូល-គ្រួសារខ្លួន និងសង្គមជាតិ និងដែលបង្កើតឱ្យជននោះមានសិទ្ធិ និងករណីយកិច្ច ។

សំបុត្រអត្រានុកូលដ្ឋាន គឺជាសំបុត្រសម្រាប់កត់ត្រាភាពជាស៊ីវិលនៃពលរដ្ឋខ្មែរ និងជនបរទេសដែលរស់នៅស្របច្បាប់ ក្នុងដែនសមត្ថកិច្ចកំណត់ នៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

សំបុត្រអត្រានុកូលដ្ឋានមាន សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្រមរណភាព ។

**មាត្រា ៣.-**

ការសុំចុះអត្រានុកូលដ្ឋានក្នុងសៀវភៅអនុត្រានុកូលដ្ឋាន ជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ។

**មាត្រា ៤.-**

រាល់ការសុំចុះសៀវភៅអនុត្រានុកូលដ្ឋាន កំណើត និងមរណភាព អ្នករាយការណ៍ និង/ឬ សាក្សី និង ឬសាមីខ្លួន ត្រូវទៅផ្ទាល់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

ចំពោះការសុំចុះសៀវភៅអត្រានុកូលដ្ឋាន អាពាហ៍ពិពាហ៍ សាមីខ្លួន និងសាក្សី ត្រូវទៅផ្ទាល់ចំពោះមុខមន្ត្រីអត្រា-នុកូលដ្ឋាន ។

**មាត្រា ៥.-**

ទម្រង់បែបបទ និងសំបុត្រអត្រានុកូលដ្ឋាន នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយឯកភាពគ្នាទូទាំងប្រ-ទេស ។

គំរូសំបុត្រអត្រានុកូលដ្ឋាន ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ៦.-**

ការចុះសៀវភៅអត្រានុកូលដ្ឋាន សម្រាប់ព្រះរាជវង្សានុវង្ស ត្រូវអនុវត្តដោយឡែក ដោយប្រគល់ភារកិច្ចនេះជូនរដ្ឋមន្ត្រីព្រះបរមរាជវាំង ។

**មាត្រា ៧.-**

រាល់សំបុត្រអត្រានុកូលដ្ឋានថតចម្លង មិនមានតម្លៃជាផ្លូវការឡើយ ។

មន្ត្រីអត្រានុកូលដ្ឋាន មិនត្រូវបញ្ជាក់លើសំបុត្រអត្រានុកូលដ្ឋានថតចម្លងទេ ។

រាល់ការចម្លង ឬសម្រង់សំបុត្រអត្រានុកូលដ្ឋាន មានចែងក្នុងជំពូកទី ១០ នៃអនុក្រឹត្យនេះ ។

## ជំពូកទី ២

## អំពីមន្ត្រីអត្រានុកូលដ្ឋាន

### មាត្រា ៨.-

មេឃុំ ឬចៅសង្កាត់ ជាមន្ត្រីអត្រានុកូលដ្ឋានក្នុងដែនដីឃុំ ឬសង្កាត់ ដែលខ្លួនគ្រប់គ្រង ។

នៅពេលដែលមេឃុំ ឬចៅសង្កាត់អវត្តមាន ត្រូវផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរឱ្យជំទប់ ឬចៅសង្កាត់រង តាមឋានានុក្រម និងរាយការណ៍ជូនអភិបាលស្រុក ឬខណ្ឌតាមផ្លូវការ ។

ក្នុងករណីមេឃុំ ឬចៅសង្កាត់អវត្តមានដោយស្លាប់ ឬដោយបញ្ឈប់ពីមុខតំណែង ក្នុងចន្លោះពេលដែលមិនទាន់មានការរៀបចំមេឃុំ ឬចៅសង្កាត់ថ្មី សិទ្ធិជាមន្ត្រីអត្រានុកូលដ្ឋាន ត្រូវប្រគល់ជូនទៅជំទប់ ឬចៅសង្កាត់រង តាមឋានានុក្រម ។

### មាត្រា ៩.-

មន្ត្រីអត្រានុកូលដ្ឋានមានភារកិច្ច :

- ទទួលពិនិត្យ កត់ត្រា រឿងហេតុសំខាន់ៗទាក់ទងនឹង កំណើត អាពាហ៍ពិពាហ៍ មរណភាពនៃជនទាំងឡាយចុះក្នុងសៀវភៅអត្រានុកូលដ្ឋាន
- ចេញសេចក្តីចម្លង ឬសម្រង់នៃអត្រានុកូលដ្ឋាន ដែលមានក្នុងឆ្នាំមិនទាន់ដាច់
- កែតម្រូវអក្ខរាវិរុទ្ធ លើអត្រានុកូលដ្ឋានក្នុងឆ្នាំមិនទាន់ដាច់ តាមលក្ខខណ្ឌមាត្រា ១៣ នៃអនុក្រឹត្យនេះ
- អនុញ្ញាតអោយរៀបចំអាពាហ៍ពិពាហ៍ និងធ្វើបុណ្យបូជា ឬបញ្ចុះសព
- ទទួលខុសត្រូវចំពោះសំបុត្រអត្រានុកូលដ្ឋាន ដែលខ្លួនបានអនុវត្ត
- ចុះហត្ថលេខា និងបោះត្រា លើសំបុត្រអត្រានុកូលដ្ឋាន
- កែតម្រូវ ឬបដិសេធអត្រានុកូលដ្ឋាន តាមអំណាចសាលក្រមស្ថាពររបស់តុលាការ ឬតាមបទប្បញ្ញត្តិនៃច្បាប់
- ថែរក្សាទុកដាក់សៀវភៅអត្រានុកូលដ្ឋាន តាមប្រភេទឱ្យបានគត់មត់ល្អ ងាយស្រួលក្នុងការតាមដាន និងការគ្រប់គ្រង
- បញ្ជូនសៀវភៅអត្រានុកូលដ្ឋានឆ្នាំដែលដាច់ទៅ យកទៅតម្កល់ទុកនៅសាលាស្រុក ឬខណ្ឌផ្ទាល់ ០១ ច្បាប់ និងនៅតុលាការខេត្ត ឬក្រុងសាមី ០១ច្បាប់
- ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងឃុំ ឬសង្កាត់ ឱ្យបានយល់ដឹងអំពីកាតព្វកិច្ចរបស់ខ្លួន ចំពោះអត្រានុកូលដ្ឋាន និងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋ ដែលមកទំនាក់ទំនងអំពីអត្រានុកូលដ្ឋាន
- ធ្វើរបាយការណ៍អំពី កំណើត អាពាហ៍ពិពាហ៍ មរណភាព ចំនួនគ្រួសារ ចំនួនប្រជាពលរដ្ឋក្នុងឃុំ ឬសង្កាត់ជារៀងរាល់ខែ និង រាល់ដំណាច់ឆ្នាំនីមួយៗ ផ្ញើទៅសាលាស្រុក ឬសាលាខណ្ឌ សាមី
- សហការជាមួយសមត្ថកិច្ចនៅមូលដ្ឋាន អំពីការងារអត្រានុកូលដ្ឋានក្នុងករណីចាំបាច់ ។

**មាត្រា ១០.-**

រាល់ការអនុវត្តការងារអត្រានុកូលដ្ឋាននៅ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅឯបរទេស ត្រូវមានទម្រង់បែបបទ និងសំបុត្រអត្រានុកូលដ្ឋានដូចការងារអត្រានុកូលដ្ឋាន ដែលអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិអន្តរជាតិ ត្រូវធ្វើសេចក្តីណែនាំបន្ថែម ដោយប្រកាសរួម ។

**មាត្រា ១១.-**

ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅឯបរទេស ត្រូវមានមន្ត្រី ០១រូប នៃស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល ឱ្យទទួលមុខងារជាមន្ត្រីអត្រានុកូលដ្ឋាន តាមសេចក្តីសម្រេចចាត់តាំងពីរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដោយជូនព័ត៌មានទៅ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

បែបបទនៃការបំពេញមុខងារជាមន្ត្រីអត្រានុកូលដ្ឋាននេះ ត្រូវពិគ្រោះរវាងក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

## ជំពូកទី ៣

## អំពីសៀវភៅអត្រានុកូលដ្ឋាន

**មាត្រា ១២.-**

ក្នុងឃុំ ឬសង្កាត់នីមួយៗ ត្រូវមានសៀវភៅអត្រានុកូលដ្ឋាន សម្រាប់កត់ត្រាអំពីកំណើត អាពាហ៍ពិពាហ៍ មរណភាព បញ្ជាក់កំណើត បញ្ជាក់អាពាហ៍ពិពាហ៍ និងបញ្ជាក់មរណភាព ។

សៀវភៅនេះត្រូវធ្វើជា០២ច្បាប់ដូចគ្នា តាមប្រភេទនីមួយៗ តាមគំរូដែលកំណត់ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

សៀវភៅនេះត្រូវចុះចំនួនសន្លឹក និងចុះលេខរៀងសន្លឹក ពីសន្លឹកទី១ ដល់សន្លឹកចុងក្រោយ ។ សន្លឹកទី១ និង សន្លឹកចុងក្រោយត្រូវសរសេរជាអក្សរ និងត្រូវចុះហត្ថលេខាពេញដោយអភិបាលស្រុក ឬអភិបាលខណ្ឌ ។ សន្លឹកទី២ និងសន្លឹកដទៃទៀតដែលអាចចុះហត្ថលេខាសង្ខេប និងបោះត្រារបស់អភិបាលស្រុក ឬអភិបាលខណ្ឌគ្រប់សន្លឹក ។

**មាត្រា ១៣.-**

សៀវភៅអត្រានុកូលដ្ឋានទាំងអស់ មិនត្រូវឱ្យមាន កោស ឆូត លុប សរសេរជ្រៀតថែមឡើយ ។ បើមានកោស ឆូត លុបត្រូវទុកពាក្យទាំងនោះឱ្យនៅមើលបាន ហើយសរសេរទឹកខ្មៅពណ៌ក្រហមនៅលើរឹមទំព័រខាងឆ្វេងថា យល់ព្រមលុបប៉ុន្មានពាក្យ និងយល់ព្រមថែមប៉ុន្មានពាក្យ ទើបមន្ត្រីអត្រានុកូលដ្ឋាន អ្នករាយការណ៍ និង ឬសាក្សី និង ឬសាមីខ្លួនចុះហត្ថលេខា ឬផ្ដិតមេដៃស្ដាំទាំងអស់គ្នា ។

ចំពោះសន្លឹកណា ដែលសរសេរខុស ត្រូវរក្សាទុកជាឯកសារមិនឱ្យហែកចោលឡើយ ។

**មាត្រា ១៤.-**

សៀវភៅអត្រានុកូលដ្ឋានតាមឆ្នាំនីមួយៗ ត្រូវបើកឱ្យប្រើប្រាស់ចាប់ពីថ្ងៃទី ០១ ខែ មករា ហើយត្រូវបញ្ឈប់នៅថ្ងៃទី ៣១ ខែ ធ្នូ រៀងរាល់ឆ្នាំ ។

នៅខែមករាឆ្នាំបន្ទាប់ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវបញ្ជូនសៀវភៅតាមប្រភេទនីមួយៗ ០១ច្បាប់ ទៅសាលាស្រុក ឬខ័ណ្ឌសាមី ដើម្បីត្រួតពិនិត្យ និងតម្កល់ទុកនៅទីនោះ និងបញ្ជូន ០១ច្បាប់ទៀតដែលដូចគ្នាទៅតម្កល់ទុកនៅតុលាការខេត្ត ឬក្រុងសាមី ដើម្បីមុខការតាមផ្លូវច្បាប់ ។

សៀវភៅអត្រានុកូលដ្ឋាន ដែលបានប្រើប្រាស់នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅឯបរទេស ត្រូវបញ្ជូនតាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៅខែ មករា ឆ្នាំបន្ទាប់ មកតម្កល់ទុក ០១ច្បាប់ នៅក្រសួងមហាផ្ទៃ និង ០១ច្បាប់ទៀតមកតម្កល់ទុកនៅក្រសួងយុត្តិធម៌ ។

**មាត្រា ១៥.-**

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវរៀបចំទុកដាក់ ថែរក្សាសៀវភៅអត្រានុកូលដ្ឋាន និងសំណុំឯកសារដែលពាក់ព័ន្ធការងារអត្រានុកូលដ្ឋានឱ្យបានល្អ និងរក្សាការសម្ងាត់ របស់បុគ្គលម្នាក់ៗ ។

ចំពោះសាលាឃុំ សង្កាត់ណា ដែលមិនធានាសុវត្ថិភាព មន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់នោះ ត្រូវធ្វើសៀវភៅអត្រានុកូលដ្ឋានទៅរក្សាទុកនៅសាលាស្រុក ឬខណ្ឌសាមី ។ ពេលធ្វើអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋាននោះត្រូវទៅធ្វើនៅសាលាស្រុក ឬខណ្ឌ ទៅតាមបែបបទដូចបានអនុវត្តនៅសាលាឃុំ ឬសង្កាត់ ។

**មាត្រា ១៦.-**

ក្រសួងមហាផ្ទៃមានភារកិច្ចរៀបចំសៀវភៅអត្រានុកូលដ្ឋានឱ្យបានឯកភាពទូទាំងប្រទេស និងបណ្តុះបណ្តាលដល់មន្ត្រីអត្រានុកូលដ្ឋាន អំពីរបៀបកត់ត្រាចូលក្នុងសៀវភៅអត្រានុកូលដ្ឋានតាមប្រភេទនីមួយៗ និងធានាផ្គត់ផ្គង់សៀវភៅ និងសំបុត្រអត្រានុកូលដ្ឋានឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលាដល់មន្ត្រីអត្រានុកូលដ្ឋាន ។

## ជំពូកទី ៤

## អំពីសំបុត្រកំណើត

**មាត្រា ១៧.-**

បើមានទារកកើត ឪពុក ឬម្តាយ មានកាតព្វកិច្ចត្រូវទៅរាយការណ៍ ចុះសៀវភៅកំណើតនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន នៅសាលាឃុំ ឬសង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ឪពុក ម្តាយទារកនោះ មិនឱ្យហួស ៣០ថ្ងៃដោយបញ្ជាក់ឱ្យបានច្បាស់ថា ឪពុក និងម្តាយនៃទារកនោះ មានខាន់ស្លា ឬឥតខាន់ស្លា ។ បើមានខាន់ស្លាត្រូវបង្ហាញសំបុត្រអាពាហ៍ពិពាហ៍ របស់ឪពុក និងម្តាយទារកនោះ ។

បើឪពុក ម្តាយមានធុរៈទៅមិនបាន ត្រូវពឹងពាក់អ្នកជាសាច់ញាតិសន្តាន ឬអ្នកនៅជិតខាងដែលបានឃើញ និងដឹងឮផ្ទាល់ពីទារកនោះកើតឱ្យទៅចុះសៀវភៅកំណើត ឱ្យបានទាន់ពេលកំណត់ ដោយយកសំបុត្រអាពាហ៍ពិពាហ៍ ឪពុក និងម្តាយទារកនោះជាប់ទៅជាមួយផង ។

**មាត្រា ១៨.-**

នាមត្រកូលរបស់ទារក អាចយកត្រកូល ដែលក្រុមគ្រួសារកំណត់យកតាំងពីដូនតាយូរលង់មកហើយ ឬអាចយក ឈ្មោះជីតាខាងឪពុក ឬអាចយកឈ្មោះឪពុករបស់ទារកនោះក៏បាន ។

ឪពុក ម្តាយ ឬអាណាព្យាបាល ជាអ្នកដាក់នាមខ្លួនឱ្យទារក ។

**មាត្រា ១៩.-**

បើមានជនណារើសបានទារកដែលគេបោះបង់ចោល ត្រូវយកទៅប្រគល់ឱ្យមន្ត្រីអត្រានុកូលដ្ឋានក្នុងឃុំ ឬសង្កាត់នៃ ទីកន្លែងដែលរើសទារកនោះ ។ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវធ្វើកំណត់ហេតុ និងចុះក្នុងសៀវភៅកំណើត ដោយរកឈ្មោះ ដាក់ឱ្យ ហើយបើក្នុងករណីចាំបាច់ មន្ត្រីអត្រានុកូលដ្ឋានត្រូវពិគ្រោះយោបល់ជាមួយមន្ត្រីសុខាភិបាល ដើម្បីដាក់ថ្ងៃ ខែ ឆ្នាំ កំណើតទារកដែលរើសបាននោះ ដោយស្មាន និងឈ្មោះឪពុក ម្តាយដាក់ថាមិនស្គាល់ ។

បើមានជនណា សុំទារកដែលរើសបាននោះធ្វើជាកូនចិញ្ចឹម ត្រូវយកនាមត្រកូលនៃអ្នកសុំ ។

ក្នុងករណីគ្មានជនណាសុំទារកដែលរើសបាននោះ ធ្វើជាកូនចិញ្ចឹម មន្ត្រីអត្រានុកូលដ្ឋានត្រូវបញ្ជូនទារកដែលរើស បាននោះ ទៅមជ្ឈមណ្ឌលសង្គ្រោះទារក ឬមជ្ឈមណ្ឌលកុមារកំព្រាដែលនៅជិតបំផុត ដោយភ្ជាប់ជាមួយនូវសំបុត្រកំណើត របស់ទារកនោះ និងកំណត់ហេតុស្តីអំពីការប្រគល់ទារកនោះ ជូនមជ្ឈមណ្ឌលសង្គ្រោះទារក ឬមជ្ឈមណ្ឌលកុមារកំព្រា ។

**មាត្រា ២០.-**

ចំពោះទារក ឬកុមារ ដែលកំពុងចិញ្ចឹមបីបាច់ថែរក្សា ក្នុងមជ្ឈមណ្ឌលសង្គ្រោះទារក ឬមជ្ឈមណ្ឌលកុមារកំព្រា ហើយដែលពុំទាន់មានសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត អ្នកទទួលខុសត្រូវនៃមជ្ឈមណ្ឌលទាំងនោះត្រូវធ្វើសេចក្តី រាយការណ៍ និងនាំទារក ឬកុមារនោះ ទៅជូនមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ដែលមជ្ឈមណ្ឌលនោះតាំងនៅ ដើម្បីមន្ត្រី អត្រានុកូលដ្ឋានផ្តល់សំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតឱ្យ ។

**មាត្រា ២១.-**

ការសុំទារក ឬកុមារ ពីមជ្ឈមណ្ឌលសង្គ្រោះទារក ឬមជ្ឈមណ្ឌលកុមារកំព្រា ការសុំទារកដែលរើសបាន និងការសុំ ទារក ឬកូនពីឪពុក ម្តាយធ្វើជាកូនចិញ្ចឹម ត្រូវអនុវត្តទៅតាមនីតិវិធី ដូចមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានជាធរមាន ។

កិច្ចសន្យាសុំកូនខាងលើនេះ ត្រូវចុះក្នុងសៀវភៅអត្រានុកូលដ្ឋាន ។

**មាត្រា ២២.-**

បើមានទណ្ឌិតណាម្នាក់សម្រាលកូន ទីកន្លែងកំណើតនៃទារកនោះ ត្រូវយកតាមលំនៅដ្ឋានរបស់ម្តាយ ឬឪពុក ។

**មាត្រា ២៣.-**

ទារកកើតពីឪពុក ម្តាយគ្មានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ក៏ត្រូវចុះក្នុងសៀវភៅកំណើតដែរ ។ នៅពេល ធ្វើសំបុត្រកំណើត បើឪពុក ម្តាយដែលគ្មានចំណងអាពាហ៍ពិពាហ៍នោះ បានឆ្លើយទទួលស្គាល់ដោយជាក់លាក់ ចំពោះមុខ មន្ត្រីអត្រានុកូលដ្ឋានថា ទារកដែលកើតមកនោះជាកូនរបស់ខ្លួន មន្ត្រីអត្រានុកូលដ្ឋានត្រូវចាត់ទុកឪពុក ម្តាយនោះថា ជា ឪពុក ម្តាយរបស់កូននោះ ។

ករណីមានតែឪពុក ឬមានតែម្តាយឆ្លើយទទួលស្គាល់តែម្នាក់ឯង ទារកនោះត្រូវចាត់ទុកថាជាកូនរបស់អ្នកដែលបានទទួលស្គាល់តែម្នាក់ឯងតែប៉ុណ្ណោះ ។

ក្រោយពេលឪពុក ឬម្តាយបានប្តឹងចុះក្នុងសៀវភៅកំណើត ឪពុក ឬម្តាយណា ដែលមិនទាន់ទទួលស្គាល់ទារកនោះ ឪពុក ឬម្តាយនោះ អាចប្តឹងសុំទទួលស្គាល់កូនជាក្រោយបាន ។

កូនឥតខាន់ស្លាដែលឪពុក ម្តាយបានទទួលស្គាល់នឹងទៅជាកូនមានខាន់ស្លាបាន ប្រសិនបើក្រោយពីកំណើតកូននោះ ឪពុក ម្តាយរបស់កូននោះ បានចុះអាពាហ៍ពិពាហ៍ជាមួយគ្នា ។

ការទទួលស្គាល់កូនអាចធ្វើនៅមុនពេលចុះអាពាហ៍ពិពាហ៍ ធ្វើដំណាលគ្នា និងពេលចុះអាពាហ៍ពិពាហ៍ ឬក្រោយពេលចុះអាពាហ៍ពិពាហ៍ក៏បាន ។

**មាត្រា ២៤.-**

ក្រោយពេលចុះសៀវភៅកំណើតរួចហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់ឱ្យអ្នករាយការណ៍ នូវសំបុត្រកំណើតច្បាប់ដើម ០១ សន្លឹកទុកជាសម្គាល់ និងចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ។

**មាត្រា ២៥.-**

បើមានទារកកើតហើយ ទុកឱ្យហួសរយៈពេល ៣០ថ្ងៃ ពុំបានទៅរាយការណ៍ ចុះសៀវភៅកំណើត ឪពុក ឬ ម្តាយ ឬអាណាព្យាបាល ត្រូវទៅសុំសាលក្រមពីតុលាការខេត្ត ក្រុងសាមី ។

ឪពុក ឬម្តាយ ឬអាណាព្យាបាលទារកនោះ ត្រូវយកសាលក្រមតុលាការនោះ មកសុំមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ដែលខ្លួនរស់នៅ ដើម្បីចុះសៀវភៅកំណើត ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវធ្វើសេចក្តីណែនាំបន្ថែម ។

**មាត្រា ២៦.-**

ទារកកើតពីម្តាយ ឪពុកជាពលរដ្ឋខ្មែរ រស់នៅស្របច្បាប់ឯបរទេស ឬពីឪពុកជាពលរដ្ឋខ្មែរ ម្តាយជាជនបរទេស ឬពីឪពុកជាជនបរទេស ម្តាយជាពលរដ្ឋខ្មែរ ឪពុក ម្តាយ នៃទារកនោះ អាចសុំចុះសៀវភៅកំណើតនៅឯប្រទេសនោះតាមបញ្ញត្តិច្បាប់របស់ប្រទេសនោះ ។ ពេលវិលត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញ ត្រូវទៅចុះសៀវភៅកំណើតនៅឃុំ ឬសង្កាត់ដែលខ្លួនរស់នៅតាមសំបុត្រកំណើតដែលប្រទេសនោះចេញឱ្យ ដោយយកសញ្ជាតិតាមច្បាប់សញ្ជាតិនៃព្រះរាជាណាចក្រកម្ពុជា ។ មន្ត្រីអត្រានុកូលដ្ឋានត្រូវយកសំបុត្រកំណើតថតចម្លងផ្លូវការនោះទុក ហើយចម្លងចេញពីសៀវភៅ នូវសំបុត្រកំណើតថ្មី ឱ្យយកទៅប្រើប្រាស់ ។

បើឪពុក ម្តាយនៃទារកនោះ បានទៅរាយការណ៍ចុះសៀវភៅកំណើតនៅឯស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ ពេលវិលត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញ អាចយកសំបុត្រកំណើតដែលប្រគល់ឱ្យនោះមកប្រើប្រាស់ជាផ្លូវការបាន ។

**មាត្រា ២៧.-**

ជនអន្តោប្រវេសន៍ និងជនបរទេស ដែលបានរស់នៅស្របច្បាប់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា បានកើតទារកនៅលើទឹកដីព្រះរាជាណាចក្រកម្ពុជា ឪពុក ម្តាយទារកនោះ អាចទៅចុះសៀវភៅកំណើតនៅសាលាឃុំ ឬសង្កាត់ ដែលខ្លួនរស់នៅជាប់លាប់ ឬអាចទៅចុះសៀវភៅកំណើតនៅ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល នៃប្រទេសរបស់ខ្លួន ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ។ បើចុះសៀវភៅកំណើតនៅសាលាឃុំ សាលាសង្កាត់ នាមត្រកូល និងនាមផ្ទាល់ខ្លួន និង នាមនៃឪពុក ម្តាយរបស់ទារកនោះ ត្រូវសរសេរជាអក្សរឡាតាំង អមជាមួយអក្សរខ្មែរផង ។

ចំពោះសញ្ជាតិនៃកូននោះ ត្រូវអនុវត្តតាមច្បាប់សញ្ជាតិនៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៥

## អំពីសំបុត្រអាពាហ៍ពិពាហ៍

**មាត្រា ២៨.-**

បុរស នារីដែលមានបំណងរៀបអាពាហ៍ពិពាហ៍ត្រូវដាក់ពាក្យសុំច្បាប់រៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋាន នៃឃុំ សង្កាត់ នៃលំនៅដ្ឋានសាមីខ្លួនខាងនារី ។ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវពិនិត្យឱ្យបានហ្មត់ចត់នូវពាក្យសុំនោះដោយផ្អែកទៅលើលក្ខខណ្ឌនៃច្បាប់ ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ជាធរមាននៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៩.-**

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវបិទប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ដែលគ្រោងនឹងធ្វើនោះ ផ្សាយជាសាធារណៈ នៅលំនៅដ្ឋាន និងនៅសាលាឃុំ ឬសាលាសង្កាត់ នៃសាមីខ្លួននារី ០១ច្បាប់ ។ ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ០២ច្បាប់ទៀត ត្រូវផ្ញើទៅជូនមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ខាងបុរស ដើម្បីយកទៅបិទផ្សាយនៅលំនៅដ្ឋាន និងបិទនៅសាលាឃុំ ឬសង្កាត់ នៃសាមីខ្លួនបុរស ០១ច្បាប់ ។

ប័ណ្ណប្រកាសត្រូវចុះ :

១- នាមត្រកូល នាមខ្លួន អាយុ មុខរបរ និងលំនៅនៃអនាគត ប្តី ប្រពន្ធ ។

២- នាមត្រកូល នាមខ្លួន អាយុ មុខរបរ និងលំនៅរបស់ឪពុក ម្តាយ នៃអនាគតប្តី ប្រពន្ធ បើឪពុក ឬម្តាយស្លាប់ ត្រូវដាក់ថាស្លាប់

៣- រយៈពេលប្តឹងជំទាស់ ។

ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ត្រូវបិទផ្សាយក្នុងរយៈពេល ១០ថ្ងៃ មុនថ្ងៃរៀបអាពាហ៍ពិពាហ៍ ដើម្បីឱ្យជនដែលមានផលប្រយោជន៍ក្នុងរឿងនេះ អាចប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះបាន ប្រសិនបើមានការមិនយល់ស្របនឹងអាពាហ៍ពិ-ពាហ៍នោះ ។ ផុតរយៈពេល ១០ថ្ងៃ អាពាហ៍ពិពាហ៍អាចធ្វើទៅបាន បើគ្មានការប្តឹងជំទាស់ ។ បើមានបណ្តឹងជំទាស់នឹងអាចរៀបអាពាហ៍ពិពាហ៍បាន លុះត្រាតែបណ្តឹងជំទាស់ត្រូវបានសមត្ថកិច្ចដោះស្រាយចប់ ។

**មាត្រា ៣០.-**

អាពាហ៍ពិពាហ៍ នឹងចាត់ទុកជាត្រឹមត្រូវតាមលក្ខណៈច្បាប់បាន លុះត្រាតែបុរស និងនារី ដែលស្ម័គ្រចិត្តទទួលគ្នាជាប្តី ប្រពន្ធ ចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអាត្រានុកូលដ្ឋាន ខាងលំនៅដ្ឋានរបស់នារី ។

កិច្ចសន្យានេះ ត្រូវចុះក្នុងសៀវភៅអាពាហ៍ពិពាហ៍ ហើយត្រូវចុះហត្ថលេខា ដោយមន្ត្រីអាត្រានុកូលដ្ឋាន និងផ្តិតមេដៃ ប្តី ប្រពន្ធ និងសាក្សីគ្រប់អាយុការចំនួន ០២នាក់ផង ។

**មាត្រា ៣១.-**

ពេលសាមីខ្លួនជាអនាគត ប្តី និងប្រពន្ធមករាយការណ៍សុំចុះសៀវភៅអាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅអាពាហ៍ពិពាហ៍ រួចហើយត្រូវប្រគល់ឱ្យសាមីខ្លួនប្តី ប្រពន្ធនូវសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើម ០១សន្លឹក និងចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ។

**មាត្រា ៣២.-**

ការសុំរៀបអាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ ឬរវាងពលរដ្ឋខ្មែរ និងជនបរទេស ដែលរស់នៅស្របច្បាប់ឯបរទេស ត្រូវប្រព្រឹត្តទៅនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៃ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅប្រទេស ដែលគូភាគីមានទីលំនៅ ។ ក្នុងករណីដែលអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ និងអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស បានប្រព្រឹត្តទៅត្រឹមត្រូវតាមទម្រង់នៃអាពាហ៍ពិពាហ៍ ដែលមានចែងក្នុងច្បាប់នៃកន្លែងរៀបអាពាហ៍ពិពាហ៍នោះ ត្រូវទទួលស្គាល់យកជាការបាននៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើអាពាហ៍ពិពាហ៍នោះ មិនផ្ទុយនឹងបទបញ្ញត្តិច្បាប់នៃព្រះ រាជាណាចក្រកម្ពុជា ។ សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ឬសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍នោះ ត្រូវយកមកចុះក្នុងសៀវភៅអាពាហ៍ពិពាហ៍នៃស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសនៃកន្លែងរៀបអាពាហ៍ពិពាហ៍ នោះ ឬបើប្តី ប្រពន្ធមកតាំងលំនៅនៅព្រះរាជាណាចក្រកម្ពុជាត្រូវយកមកចុះសៀវភៅអាពាហ៍ពិពាហ៍នៅសាលាឃុំ ឬសង្កាត់ដែលខ្លួនបានរស់នៅ ។ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល ឬមន្ត្រី អត្រានុកូលដ្ឋាននៅព្រះរាជាណាចក្រកម្ពុជា ត្រូវយកសំបុត្រអាពាហ៍ពិពាហ៍ ថតចម្លងផ្លូវការនោះទុក ហើយចម្លងចេញពី សៀវភៅនូវសំបុត្រពាហ៍ពិពាហ៍ថ្មី ឱ្យទៅជននោះយកទៅប្រើប្រាស់ ។

**មាត្រា ៣៣.-**

អាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរ និងជនបរទេស ឬជនអន្តោប្រវេសន៍ ដែលរស់នៅស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ត្រូវប្រព្រឹត្តទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣៤.-**

ជនអន្តោប្រវេសន៍ និងជនបរទេស ដែលរស់នៅស្របច្បាប់នៅលើទឹកដី នៃព្រះរាជាណាចក្រកម្ពុជា អាចរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស ឬជនអន្តោប្រវេសន៍នោះបាន ដោយអនុវត្តតាមច្បាប់ ស្តីពីអាពាហ៍ពិពាហ៍ ដែលមានចែងនៅក្នុងប្រទេសរបស់ខ្លួន តែត្រូវសុំអនុញ្ញាតច្បាប់ពីមន្ត្រីអត្រានុកូលដ្ឋានដោយប្រាប់ពី ទីកន្លែង និងពេលវេលាដែលខ្លួនរៀបអាពាហ៍ពិពាហ៍នេះឱ្យបានច្បាស់ ។

ពេលរៀបអាពាហ៍ពិពាហ៍ ប្តី ប្រពន្ធ អាចទៅសុំចុះសៀវភៅអាពាហ៍ពិពាហ៍នៅ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃប្រទេសរបស់ខ្លួនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើមាន ឬសុំចុះសៀវភៅអាពាហ៍ពិពាហ៍នៅមន្ត្រីអត្រានុកូលដ្ឋានតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជាក៏បាន ។

ការចុះឈ្មោះនៃជនជាតិបរទេស ត្រូវសរសេរជាអក្សរឡាតាំង អមជាមួយអក្សរខ្មែរផង ។

## ជំពូកទី ៦
## អំពីសំបុត្រមរណភាព

### មាត្រា ៣៥.-

ពេលមានអ្នកស្លាប់ភ្លាម ក្រុមគ្រួសារ ឬសាច់ញាតិសន្តាន ឬអ្នកជិតខាង ឬអ្នកមានភារកិច្ចនៅក្រសួង ស្ថាប័ន អង្គភាពរបស់អ្នកស្លាប់ ត្រូវរាយការណ៍ជូនដល់មន្ត្រីអត្រានុកូលដ្ឋានសាលាឃុំ ឬសង្កាត់ នៃទីកន្លែងរស់នៅជាប់លាប់ របស់អ្នកស្លាប់ ។

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវធ្វើលិខិតអនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬបញ្ចុះសព បើស្លាប់ដោយជម្ងឺធម្មតា ដោយចាស់ជរា ដោយគ្រោះថ្នាក់ធម្មជាតិ ឬដោយគ្រោះថ្នាក់ផ្សេងៗ ដែលមិនមានមន្ទិលសង្ស័យទាក់ទង ដល់អំពើឃាតកម្មនៃបទល្មើសឧក្រិដ្ឋណាមួយ ។

ការចុះសៀវភៅមរណភាព និងចេញសំបុត្រមរណភាព ត្រូវធ្វើក្នុងរយៈពេលយ៉ាងយូរបំផុត ១៥ថ្ងៃ ក្រោយពីថ្ងៃទទួលមរណភាព ។

បើអ្នកស្លាប់ដោយជម្ងឺឆ្លងរាតត្បាត អាចបណ្តាលឱ្យគ្រោះថ្នាក់ដល់សង្គម ត្រូវរាយការណ៍ទៅមន្ទីរពេទ្យ ឬផ្នែកអនាម័យភ្លាម ។ បើពេទ្យ ឬផ្នែកអនាម័យសម្រេចយ៉ាងណា មន្ត្រីអត្រានុកូលដ្ឋានត្រូវធ្វើលិខិតអនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬបញ្ចុះ សពតាមការសម្រេចនោះ ។

### មាត្រា ៣៦.-

បើមានអ្នកស្លាប់ដោយមូលហេតុណាមួយ ដែលពាក់ព័ន្ធដល់ការមន្ទិលសង្ស័យ ដល់អំពើឃាតកម្មនៃបទល្មើសឧក្រិដ្ឋ មន្ត្រីអត្រានុកូលដ្ឋាន ឬជនទាំងឡាយណា ដែលមានការពាក់ព័ន្ធត្រូវរាយការណ៍ភ្លាមដល់អាជ្ញាធរមានសមត្ថកិច្ចនៅកន្លែងអ្នកនោះស្លាប់ ដើម្បីឱ្យសមត្ថកិច្ចជំនាញនានា ពិនិត្យស្រាវជ្រាវ និងដោះស្រាយរួសរាន់ ។ ក្រោយពីមានការសម្រេចយ៉ាង ណាពីភ្នាក់ងារមានមសមត្ថកិច្ច ទើបមន្ត្រីអត្រានុកូលដ្ឋានអនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬបញ្ចុះសពបាន ។

### មាត្រា ៣៧.-

បើមានពលរដ្ឋខ្មែររស់នៅក្នុងឃុំ ឬសង្កាត់ណាមួយ បានទៅស្លាប់នៅឃុំ ឬសង្កាត់ផ្សេង មន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់ដែលមានអ្នកស្លាប់ ត្រូវជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់របស់អ្នកស្លាប់រស់នៅដើម្បីជូនដំណឹងដល់ក្រុមគ្រួសារនៃអ្នកស្លាប់ ឱ្យទៅយកសពធ្វើបុណ្យ និងចុះសៀវភៅមរណភាពនៅឃុំ ឬសង្កាត់នៃអ្នកស្លាប់នោះស្នាក់នៅជាប់លាប់ ។

បើអ្នកស្លាប់គ្មានក្រុមគ្រួសារ ឬគ្មានអ្នកស្គាល់ទេ មន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់ដែលមានអ្នកស្លាប់ត្រូវចាត់

ថែងបូជា ឬបញ្ចុះសពនោះ និងចុះសៀវភៅមរណភាពក្នុងឃុំ ឬសង្កាត់នោះ ។

**មាត្រា ៣៨.-**

បើមានអ្នកទោសណាម្នាក់ស្លាប់ក្នុងពន្ធនាគារ អ្នកទទួលខុសត្រូវនៃពន្ធនាគារនោះ ត្រូវធ្វើសេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ និងទៅមន្ត្រីអត្រានុកូលដ្ឋាននៃលំនៅអចិន្ត្រៃយ៍របស់អ្នកទោសនោះដើម្បីមន្ត្រីអត្រានុកូលដ្ឋានចុះក្នុងសៀវភៅមរណភាព ។

**មាត្រា ៣៩.-**

ពេលមានអ្នករាយការណ៍អំពីមរណភាព មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅមរណភាព រួចប្រគល់ឱ្យអ្នកសុំនូវសំបុត្រមរណភាពច្បាប់ដើម ០១សន្លឹក និងចេញសេចក្ដីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ។

**មាត្រា ៤០.-**

បើមានអ្នកស្លាប់ទុកហួសរយៈពេល ១៥ថ្ងៃ ពុំបានទៅរាយការណ៍ចុះសៀវភៅមរណភាពទេ ក្រុមគ្រួសារ នៃអ្នកស្លាប់ ត្រូវទៅសុំសាលក្រមពីតុលាការខេត្ត-ក្រុងសាមី រួចយកសាលក្រមតុលាការនោះ មកសុំមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ នៃអ្នកស្លាប់ ដើម្បីចុះសៀវភៅមរណភាព ។

**មាត្រា ៤១.-**

បើមានពលរដ្ឋខ្មែររស់នៅស្របច្បាប់ឯបរទេសបានស្លាប់ ក្រុមគ្រួសារ ឬសាច់ញាតិសន្តាន ឬអ្នកជិតខាង ឬអ្នកដែលបានឃើញអ្នកស្លាប់នោះផ្ទាល់ អាចទៅចុះសៀវភៅមរណភាពនៅប្រទេសនោះ តាមច្បាប់របស់ប្រទេសនោះ ។ ពេលត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញ ត្រូវយកសំបុត្រមរណភាពដែលធ្វើនៅបរទេសនោះទៅចុះសៀវភៅនៅ ឃុំ ឬសង្កាត់ដែលសាមីខ្លួនអ្នកស្លាប់ ធ្លាប់ស្នាក់នៅជាប់លាប់មុនពេលចេញទៅបរទេស ។

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវដកយកសំបុត្រមរណភាពថតចម្លងជាផ្លូវការទុកជាឯកសារ ហើយចម្លងចេញពីសៀវភៅមរណភាពនូវសំបុត្រមរណភាពថ្មី ប្រគល់ឱ្យសាមីខ្លួនអ្នកសុំយកទៅប្រើប្រាស់ ។

បើបានទៅរាយការណ៍ចុះសៀវភៅមរណភាពនៅ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ រួចហើយពេលត្រឡប់មកប្រទេសកម្ពុជាវិញអាចយកសំបុត្រមរណភាពនោះមកប្រើប្រាស់ជាផ្លូវការបាន ។

**មាត្រា ៤២.-**

ជនអន្តោប្រវេសន៍ និងជនបរទេសរស់នៅស្របច្បាប់លើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានស្លាប់នៅ លើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ក្រុមគ្រួសារសាច់ញាតិ ឬអ្នកទទួលខុសត្រូវ អាចទៅចុះសៀវភៅមរណភាពនៅសាលាឃុំ ឬសង្កាត់ ដែលអ្នកស្លាប់ធ្លាប់រស់នៅជាប់លាប់ មុនពេលខ្លួនស្លាប់ ឬអាចទៅចុះសៀវភៅមរណភាព នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃប្រទេសរបស់អ្នកស្លាប់ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើមាន ។

បើចុះសៀវភៅមរណភាពនៅឃុំ ឬសង្កាត់ ការចុះឈ្មោះជនជាតិបរទេស ត្រូវសរសេរជាអក្សរឡាតាំង អមជាមួយអក្សរខ្មែរផង ។

## ជំពូកទី ៧
## អំពីសំបុត្របញ្ជាក់កំណើត

### មាត្រា ៤៣.-

ពលរដ្ឋខ្មែរដែលបានកើតមុនពេលមានអនុក្រឹត្យ ស្តីពីអត្រានុកូលដ្ឋានថ្មីនេះ ចូលជាធរមាន ហើយគ្មានសំបុត្រកំនើតប្រើប្រាស់ អាចសុំចុះសៀវភៅបញ្ជាក់សំបុត្រកំណើតបាន តាមគំរូណែនាំថ្មី នៅសាលាឃុំ ឬសង្កាត់ ដែលខ្លួនរស់នៅជាប់លាប់បច្ចុប្បន្ន ដោយមានសាក្សីចំនួន ០២រូប ជាទីតិជន និងជាមនុស្សគួរឱ្យជឿទុកចិត្តបាន ដែលបានស្គាល់ច្បាស់ពីប្រវត្តិអ្នកត្រូវសុំធ្វើសំបុត្របញ្ជាក់កំណើត និងធ្លាប់រស់នៅក្នុងភូមិ ឃុំ ឬសង្កាត់ជាមួយ ពីពេលដែលសាមីខ្លួនកើតនាំមកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

ចំពោះមន្ត្រីរាជការដែលបានទទួលបៀវត្ស ឬទទួលសោធននិវត្តន៍ ត្រូវយកឯកសារបៀវត្ស ឬសោធននិវត្តន៍ ឬសេចក្តីបញ្ជាក់ពីស្ថាប័នសាមី ដើម្បីសុំសំបុត្របញ្ជាក់កំណើត ហើយថ្ងៃ ខែ ឆ្នាំកំណើត ដែលចុះនៅក្នុងសៀវភៅបញ្ជាក់កំណើតមិនត្រូវឱ្យខុសពីថ្ងៃ ខែ ឆ្នាំកំណើត ដែលមាននៅក្នុងឯកសារបៀវត្ស ឬសោធននិវត្តន៍ជាផ្លូវការឡើយ ។

### មាត្រា ៤៤.-

ពេលមានអ្នកមកសុំចុះសៀវភៅកំនើត មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅបញ្ជាក់កំណើត រួចត្រូវប្រគល់អោយសាមីខ្លួន ឬក្រុមគ្រួសារនូវសំបុត្របញ្ជាក់កំណើតច្បាប់ដើម ០១សន្លឹក និងចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ដោយមានហត្ថលេខារបស់មន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ ។

## ជំពូកទី ៨
## អំពីសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍

### មាត្រា ៤៥.-

ពលរដ្ឋខ្មែរដែលបានគ្នាជាប្តី ឬប្រពន្ធ ពិតប្រាកដ នៅមុនពេលមានអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានថ្មីនេះចូលជាធរមាន ហើយគ្មានសំបុត្រអាពាហ៍ពិពាហ៍ប្រើប្រាស់ សាមីខ្លួនប្តី ប្រពន្ធអាចមកសុំចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍បានតាមគំរូណែនាំថ្មីនៅសាលាឃុំ ឬសង្កាត់ដែលខ្លួនរស់នៅជាប់លាប់បច្ចុប្បន្ន ដោយមានសាក្សីចំនួន ០២រូប ជាទីតិជន និងជាមនុស្សគួរឱ្យជឿទុកចិត្តបាន ដែលបានដឹងឮផ្ទាល់ពីសាមីខ្លួនប្តី ប្រពន្ធនោះ និងធ្លាប់រស់នៅក្នុងភូមិ ឃុំ ឬសង្កាត់ជាមួយគ្នានាំមកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

### មាត្រា ៤៦.-

ពេលមានសាមីខ្លួនប្តី និងប្រពន្ធមកសុំចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ រួចហើយត្រូវប្រគល់ឱ្យសាមីខ្លួនប្តី ប្រពន្ធនូវសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ច្បាប់ដើម ០១សន្លឹក និង ចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ដោយមានហត្ថលេខារបស់មន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ ។

## ជំពូកទី ៩
## អំពីសំបុត្របញ្ជាក់មរណភាព

**មាត្រា ៤៧.-**

ពលរដ្ឋខ្មែរ ដែលស្លាប់មុនពេលអនុក្រឹត្យស្តីពី អត្រានុកូលដ្ឋានថ្មីនេះ ចូលជាធរមាន ហើយគ្មានសំបុត្រមរណភាព សាច់ញាតិសន្តានដែលនៅរស់ អាចមកសុំចុះសៀវភៅបញ្ជាក់មរណភាពតាមគំរូណែនាំថ្មីនៅសាលាឃុំ ឬសង្កាត់ដែលញាតិសន្តានរស់នៅជាប់លាប់បច្ចុប្បន្នបាន ដោយនាំសាក្សីចំនួន ០២រូប ជានីតិជន និងជាមនុស្សគួរឱ្យជឿទុកចិត្តបាន ដែលបានដឹងឮផ្ទាល់អំពីការស្លាប់ និងធ្លាប់រស់នៅក្នុងភូមិ ឃុំ ឬ សង្កាត់ជាមួយអ្នកស្លាប់ មកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។

**មាត្រា ៤៨.-**

ពេលមានអ្នកមកសុំចុះសៀវភៅបញ្ជាក់មរណភាព មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅបញ្ជាក់មរណភាព រួចត្រូវប្រគល់ឱ្យអ្នកសុំនូវសំបុត្របញ្ជាក់មរណភាពច្បាប់ដើម ០១សន្លឹក និងចេញសេចក្តីចម្លងតាមការស្នើសុំ ដោយមានហត្ថលេខារបស់មន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ ។

## ជំពូកទី ១០
## អំពីសេចក្តីចម្លង ឬសម្រង់អត្រានុកូលដ្ឋាន

**មាត្រា ៤៩.-**

សេចក្តីចម្លង ឬសម្រង់អត្រានុកូលដ្ឋានមាន សេចក្តីចម្លង ឬសម្រង់សំបុត្រកំណើត សេចក្តីចម្លង ឬសម្រង់សំបុត្រអាពាហ៍ពិពាហ៍ សេចក្តីចម្លង ឬសម្រង់សំបុត្រមរណភាព សេចក្តីចម្លង ឬសម្រង់សំបុត្របញ្ជាក់កំណើត សេចក្តីចម្លង ឬសម្រង់សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ និងសេចក្តីចម្លង ឬសម្រង់សំបុត្របញ្ជាក់មរណភាព ។

រាល់ខ្លឹមសារនៃសេចក្តីចម្លង ត្រូវអនុវត្តដូចគ្នា នឹងខ្លឹមសារក្នុងសំបុត្រអត្រានុកូលដ្ឋានដើម ។ សម្រង់អត្រានុកូលដ្ឋាន ត្រូវធ្វើតាមសំណើរបស់អ្នកសុំដោយដកស្រង់នូវខ្លឹមសារសំខាន់ៗ ចេញពីសៀវភៅអត្រានុកូលដ្ឋាន ។

**មាត្រា ៥០.-**

បើមានអ្នកមកសុំចម្លង ឬសុំស្រង់សំបុត្រអត្រានុកូលដ្ឋានពីមន្ត្រីអត្រានុកូលដ្ឋាន អ្នកសុំត្រូវមានសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើមយកមកជាមួយ តែការចម្លង ឬសម្រង់ត្រូវស្រង់ចេញពីសៀវភៅដែលតម្កល់ទុក ។ ក្នុងករណីបាត់សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម មន្ត្រីអត្រានុកូលដ្ឋានត្រូវចម្លងតាមសៀវភៅអត្រានុកូលដ្ឋាន ដែលបានចុះពីមុនមក និងកំពុងថែរក្សា ក្នុងឆ្នាំដែលមិនទាន់ដាច់ នៅសាលាឃុំ ឬសង្កាត់ ។ ក្នុងករណីសៀវភៅអត្រានុកូលដ្ឋានបានវិនាសដោយមានកំណត់ហេតុត្រឹមត្រូវ ហើយមានសេចក្តីណែនាំពីអន្តរក្រសួង ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ទើបធ្វើការចម្លង ឬសម្រង់ចេញពី សន្លឹកអត្រានុកូលដ្ឋាន ដែលសាមីខ្លួនអ្នកសុំមាន ហើយយកទៅប្រើការបាន ។

**មាត្រា ៥១.-**

ការសុំចម្លង ឬសម្រង់សំបុត្រអត្រានុកូលដ្ឋានក្នុងឆ្នាំមិនទាន់ដាច់ ត្រូវសុំចម្លង ឬសុំស្រង់នៅសាលាឃុំ ឬសាលាសង្កាត់ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាន ឃុំ ឬសង្កាត់ ហើយត្រូវបញ្ជាក់ហត្ថលេខានោះ ដោយអភិបាលស្រុក ឬខណ្ឌ និងបោះត្រាផង ។

**មាត្រា ៥២.-**

ការសុំចម្លង ឬសម្រង់សំបុត្រអត្រានុកូលដ្ឋានឆ្នាំដែលកន្លងផុតទៅ ត្រូវទៅសុំចម្លង ឬសុំស្រង់នៅសាលាស្រុក ឬខណ្ឌ ឬនៅតុលាការខេត្ត ក្រុងសាមី ។

ការសុំចម្លង ឬសម្រង់នៅសាលាស្រុក ឬសាលាខណ្ឌ ត្រូវចុះហត្ថលេខាដោយមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន និងត្រូវបញ្ជាក់ហត្ថលេខានោះ ដោយអភិបាលស្រុក ឬខណ្ឌ និងបោះត្រាផង ។

ការសុំចម្លង ឬសម្រង់នៅតុលាការខេត្ត ក្រុង ត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និងត្រូវបញ្ជាក់ហត្ថលេខានោះ ដោយប្រធានតុលាការ ឬចៅក្រមជំនួស និងបោះត្រាផង ។

**មាត្រា ៥៣.-**

ពលរដ្ឋខ្មែររស់នៅស្របច្បាប់ឯបរទេស ដែលបានចុះសៀវភៅអត្រានុកូលដ្ឋាននៅ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ ការសុំចម្លង ឬសម្រង់អត្រានុកូលដ្ឋានក្នុងឆ្នាំមិនទាន់ដាច់ ត្រូវសុំចម្លង ឬសុំស្រង់នៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនោះ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាននៅទីនោះ ហើយត្រូវបញ្ជាក់ហត្ថលេខានោះ ដោយឯកអគ្គរាជទូត អគ្គកុងស៊ុល ឬកុងស៊ុល និងបោះត្រាផង ។

ការសុំចម្លង ឬសម្រង់អត្រានុកូលដ្ឋានឆ្នាំដែលកន្លងផុតទៅ ត្រូវសុំចម្លង ឬសុំស្រង់នៅក្រសួងមហាផ្ទៃ ឬនៅក្រសួងយុត្តិធម៌ ដែលមានសៀវភៅអត្រានុកូលដ្ឋានឆ្នាំចាស់ តម្កល់ទុកនៅទីនោះ ។

## ជំពូកទី ១១
## អំពីការទទួលខុសត្រូវចំពោះមុខច្បាប់
## ស្តីពីការងារអត្រានុកូលដ្ឋាន

**មាត្រា ៥៤.-**

សាមីខ្លួន និង ឬអ្នករាយការណ៍ និង ឬសាក្សី ត្រូវសំដែងនូវការស្មោះត្រង់ ចំពោះការបញ្ជាក់អះអាងរបស់ខ្លួនអំពីហេតុការណ៍ដែលកើតមានឡើង ហើយដែលខ្លួនបានដឹងឮ ឬឃើញផ្ទាល់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ស្តីពីអត្រានុកូលដ្ឋានតាមប្រភេទ ។

**មាត្រា ៥៥.-**

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវស្មោះត្រង់ក្នុងការធ្វើអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋ ។ បើមានមន្ត្រីអត្រានុកូលដ្ឋានណាម្នាក់មានការឃុបឃិត ឬក្លែងបន្លំដោយចេតនា ក្នុងការធ្វើសំបុត្រអត្រានុកូលដ្ឋាន ត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

សំបុត្រអត្រានុកូលដ្ឋានក្លែងបន្លំដែលបានចេញរួចហើយ ត្រូវប្រមូលយកមកវិញ និងប្តឹងទៅតុលាការ ដើម្បីបដិសេធ និងសុំផ្តន្ទាទោសតាមច្បាប់ ។

## ជំពូកទី១២

## អំពីថវិកាអត្រានុកូលដ្ឋាន

**មាត្រា ៥៦.-**

ការបោះពុម្ពសៀវភៅ សំបុត្រអត្រានុកូលដ្ឋាន និងការបណ្តុះបណ្តាល អំពីការងារអត្រានុកូលដ្ឋានដល់មន្ត្រីអត្រានុកូលដ្ឋានទូទាំងប្រទេសត្រូវស្ថិតនៅក្នុងបន្ទុកថវិការដ្ឋ ។

**មាត្រា ៥៧.-**

ក្រសួងមហាផ្ទៃត្រូវលើកគម្រោងថវិកាប្រចាំឆ្នាំ សម្រាប់ការសុំបោះពុម្ពសៀវភៅ សំបុត្រអត្រានុកូលដ្ឋាន និងការបណ្តុះបណ្តាលការងារអត្រានុកូលដ្ឋាន ។

**មាត្រា ៥៨.-**

ការសុំចុះសំបុត្រអត្រានុកូលដ្ឋាន កំណើត និងមរណភាព អ្នកមកសុំមិនតម្រូវឱ្យបង់ថ្លៃអ្វីឡើយ ។

ការសុំច្បាប់រៀបអាពាហ៍ពិពាហ៍ និងការចុះសំបុត្រអត្រានុកូលដ្ឋាន អាពាហ៍ពិពាហ៍ ការសុំបញ្ជាក់កំណើត បញ្ជាក់អាពាហ៍ពិពាហ៍ និងបញ្ជាក់មរណភាព អ្នកសុំត្រូវបង់ថ្លៃក្រដាសតាមការកំណត់ ។

រាល់ការសុំចម្លង ឬសម្រង់សំបុត្រអត្រានុកូលដ្ឋានអ្នកមកសុំត្រូវបង់ថ្លៃក្រដាស និងថ្លៃបិទតែមប្រិ៍ ដើម្បីជាប្រយោជន៍សម្រាប់ ឃុំ ឬសង្កាត់ និងចំណូលថវិការដ្ឋ ។

ថ្លៃក្រដាសអត្រានុកូលដ្ឋាន និងថ្លៃតែមប្រិ៍ត្រូវកំណត់ដោយអនុក្រឹត្យ តាមសេចក្តីស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី ១៣

## អន្តរប្បញ្ញត្តិ

**មាត្រា ៥៩.-**

ការសុំបញ្ជាក់អត្រានុកូលដ្ឋានមានចុះសៀវភៅបញ្ជាក់កំណើត សៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ សៀវភៅបញ្ជាក់មរណភាព ត្រូវបានអនុវត្តចំពោះតែលើពលរដ្ឋខ្មែរ ហើយអនុវត្តតែក្នុងរយៈពេល ៣ឆ្នាំ ចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន ។ ផុតរយៈពេលនេះ ពលរដ្ឋខ្មែរដែលគ្មានសំបុត្រអត្រានុកូលដ្ឋាន កំណើត និងមរណភាព ត្រូវទៅសុំសាលក្រមពីតុលាការខេត្ត ក្រុងសាមី រួចយកសាលក្រមតុលាការនោះ មកសុំមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ដើម្បីចុះសៀវភៅអត្រានុកូលដ្ឋាន ។ ឯការបញ្ជាក់អត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍អនុញ្ញាតឱ្យប្តឹងសុំចុះតាមការស្ម័គ្រចិត្តនៃសហព័ទ្ធ ។

**មាត្រា ៦០.-**

ហាមយកសំបុត្រអត្រានុកូលដ្ឋានរបស់ជនណាម្នាក់ ទៅប្រើប្រាស់ធ្វើជាសំបុត្រអត្រានុកូលដ្ឋានផ្ទាល់ខ្លួនរបស់ជន

ណាម្នាក់ផ្សេងទៀត ។

**មាត្រា ៦១.-**

រាល់សំបុត្រអត្រានុកូលដ្ឋានច្បាប់ចាស់ ដែលមានស្រាប់ពីសង្គមមុនៗ និងអត្រានុកូលដ្ឋានក្រោយឆ្នាំ ១៩៧៨ហើយ រក្សាទុករហូតដល់បច្ចុប្បន្ន សាមីខ្លួនត្រូវយកមកបង្ហាញមន្ត្រីអត្រានុកូលដ្ឋានបច្ចុប្បន្ន ដើម្បីចុះក្នុងសៀវភៅអត្រានុកូលដ្ឋានតាមគំរូថ្មី សម្រាប់ប្រើប្រាស់ទៅថ្ងៃក្រោយ ។

**មាត្រា ៦២.-**

ក្នុងករណីដែលពិនិត្យឃើញសំបុត្រអត្រានុកូលដ្ឋានចាស់ពីមុនណាមួយ ដែលមានលក្ខណៈពុំត្រឹមត្រូវ មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រមូលសំបុត្រអត្រានុកូលដ្ឋាននោះមកវិញ រួចណែនាំឱ្យសាមីជនបំពេញបែបបទសុំអត្រានុកូលដ្ឋានថ្មី ។

**មាត្រា ៦៣.-**

ហាមមនុស្សម្នាក់ចុះសៀវភៅអត្រានុកូលដ្ឋានក្នុងប្រភេទនីមួយៗ លើសពី ០១ដង និងនៅច្រើនកន្លែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ១៤
## អំពីទោសប្បញ្ញត្តិ

**មាត្រា ៦៤.-**

ជនណារាយការណ៍មិនពិត អំពីអត្រានុកូលដ្ឋានចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ឬយកអត្រានុកូលដ្ឋានរបស់អ្នកដទៃទៅប្រើប្រាស់ជារបស់ខ្លួន ឬរាយការណ៍សុំចុះអត្រានុកូលដ្ឋានលើសពី ០១ដង នៅទីកន្លែងដដែល ឬទីកន្លែងផ្សេងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬប្រើប្រាស់អត្រានុកូលដ្ឋានក្លែង ត្រូវពិន័យ និងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

**មាត្រា ៦៥.-**

មន្ត្រីអត្រានុកូលដ្ឋានណា សមគំនិត ឃុបឃិត ក្លែងបន្លំ ចុះសៀវភៅអត្រានុកូលដ្ឋានឱ្យប្រជាពលរដ្ឋ ដែលមកសុំ ឬបានទារប្រាក់លើសច្បាប់កំណត់ពីប្រជាពលរដ្ឋសម្រាប់ការងារអត្រានុកូលដ្ឋាន ត្រូវពិន័យជាប្រាក់ និងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

## ជំពូកទី ១៥
## អវសានប្បញ្ញត្តិ

**មាត្រា ៦៦.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ. ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ដើម្បីចុះហត្ថលេខា

| | សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| **ស ខេង** | **យូ ហុកគ្រី** | **អ៊ុក វិធុន** |

**ចម្លងជូន**

-ខុទ្ទកាល័យព្រះមហាក្សត្រ

-អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋាន រដ្ឋសភា

-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី

-ដូចមាត្រា ៦៧

-កាលប្បវត្តិ-ឯកសារ

# ឧបសម្ព័ន្ធទី៣

# សេចក្ដីណែនាំស្ដីពីការអនុវត្ត
# អនុក្រឹត្យស្ដីពីការកំណត់បែបបទ និង
# នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍
# រវាងពលរដ្ឋខ្មែរ និងជនបរទេស

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

ក្រសួងមហាផ្ទៃ

លេខ : ០០១.ឥណាន

រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែមករា ឆ្នាំ ២០០៩

# សេចក្ដីណែនាំ

## ស្ដីពី

## ការអនុវត្តអនុក្រឹត្យស្ដីពីការកំណត់បែបបទ និងនីតិវិធី នៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរនិងជនបរទេស

យោងអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្ដីពីអត្រានុកូលដ្ឋាន

យោងអនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្ដីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស។

ក្រសួងមហាផ្ទៃ សូមធ្វើការណែនាំដល់អង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ និង អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ក្នុងការអនុវត្តបែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ដូចខាងក្រោម :

**១- អំពីភារកិច្ច**

**ក- ថ្នាក់ក្រសួង**

នាយកដ្ឋានរដ្ឋបាលទូទៅនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ជាសេនាធិការឱ្យក្រសួងលើការងារស្ថិតិ និងអត្រានុកូលដ្ឋាន និងមានភារកិច្ច :

- ចុះបញ្ជីសំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍របស់សាមីខ្លួនជនបរទេសដែលបានផ្ញើមកពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

- ជូនឯកសារសាមីខ្លួនជនបរទេសទៅអង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ ដើម្បីសហការផ្ដល់ព័ត៌មានពីអត្តសញ្ញាណជនបរទេសនោះ

- ជូនដំណឹងអំពីការសុំរៀបអាពាហ៍ពិពាហ៍របស់សាមីខ្លួនជនបរទេស ទៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សាមី និងមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ និងជូនដំណឹង ព្រមទាំងប្រគល់សំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍ទៅសាមីខ្លួនជនបរទេស ក្នុងរយៈពេលយ៉ាងយូរ ០៥ ថ្ងៃការងារ ដើម្បីសាមីខ្លួនដាក់សំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ

- ពិនិត្យនីត្យានុកូលភាពលើសំណុំឯកសារដែលចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ ។

**ខ. ថ្នាក់រាជធានី ខេត្ត**

អភិបាលរាជធានី ខេត្ត ទទួលខុសត្រូវក្នុងការត្រួតពិនិត្យការអនុវត្តការងារស្ថិតិនិងអត្រានុកូលដ្ឋាននៅរាជធានី ខេត្តរបស់ខ្លួន ដោយមានការិយាល័យស្ថិតិនិងអត្រានុកូលដ្ឋាន នៃរាជធានី ខេត្ត ជាសេនាធិការ និងមានភារកិច្ចដូចខាងក្រោម :

- គាំទ្រ និងត្រួតពិនិត្យតាមដានការអនុវត្តការងារអត្រានុកូលដ្ឋាននៅក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់

- ផ្សព្វផ្សាយ និង ចលនាឱ្យមន្ទីរពាក់ព័ន្ធនានាជុំវិញរាជធានី ខេត្ត សហការផ្តល់ព័ត៌មានពីការអនុវត្តការងារអត្រានុកូលដ្ឋាននៅក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់

- បូកសរុបរបាយការណ៍ស្តីពីការអនុវត្តការងារអត្រានុកូលដ្ឋាននៅក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ផ្ញើមកក្រសួងមហាផ្ទៃ (នាយកដ្ឋានរដ្ឋបាលទូទៅ នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន) នៅរៀងរាល់ថ្ងៃទី ១៥ នៃខែបន្ទាប់ ។

**គ. ថ្នាក់ក្រុង ស្រុក ខណ្ឌ**

អភិបាលក្រុង ស្រុក ខណ្ឌ ទទួលខុសត្រូវក្នុងការត្រួតពិនិត្យការអនុវត្តការងារស្ថិតិ និងអត្រានុកូលដ្ឋាននៅក្រុង ស្រុក ខណ្ឌរបស់ខ្លួន និងមានភារកិច្ចដូចខាងក្រោម :

- គាំទ្រ និងត្រួតពិនិត្យតាមដានការអនុវត្តការងារអត្រានុកូលដ្ឋាននៅឃុំ សង្កាត់

- ផ្សព្វផ្សាយ និងចលនាឱ្យការិយាល័យពាក់ព័ន្ធនានាជុំវិញក្រុង ស្រុក ខណ្ឌ សហការផ្តល់ព័ត៌មានពីការអនុវត្តការងារអត្រានុកូលដ្ឋាននៅឃុំ សង្កាត់

- បូកសរុបរបាយការណ៍ស្តីពីការអនុវត្តការងារអត្រានុកូលដ្ឋាននៅឃុំ សង្កាត់ ផ្ញើមករាជធានី ខេត្ត នៅរៀងរាល់ថ្ងៃទី ១០ នៃខែបន្ទាប់ ។

**ឃ. ថ្នាក់ឃុំ សង្កាត់**

ក្រុមប្រឹក្សាឃុំ សង្កាត់ ទទួលខុសត្រូវអំពីការងារអត្រានុកូលដ្ឋាននៅក្នុងដែនដីឃុំ សង្កាត់ ដែលខ្លួនគ្រប់គ្រង ។ មេឃុំ ចៅសង្កាត់ជាមន្ត្រីអត្រានុកូលដ្ឋាន ។

មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ក្រោយពីទទួលបាននូវសេចក្តីជូនដំណឹងពីក្រសួងមហាផ្ទៃ ស្តីពីការសុំរៀបអាពាហ៍ពិពាហ៍របស់ជនបរទេសជាមួយពលរដ្ឋខ្មែរ និង បន្ទាប់ពីបានទទួលសំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍ពីសាមីខ្លួនជនបរទេស និង ពីសាមីខ្លួនពលរដ្ឋខ្មែររួចហើយ មានភារកិច្ចដូចខាងក្រោម :

- ពិនិត្យ និង សម្រេចលើសំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍របស់ជនបរទេស និង របស់ពលរដ្ឋខ្មែរយ៉ាងយូរក្នុងរយៈពេល០៣ថ្ងៃការងារ ។ ពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងសំណុំឯកសារសាមីខ្លួនជាជនបរទេស

និងរបស់ពលរដ្ឋខ្មែរ ត្រូវដាក់ស្របពេលជាមួយគ្នាទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ពលរដ្ឋខ្មែរ ។

+ សំណុំឯកសារជនបរទេសមាន :

. ពាក្យសុំរៀបអាពាហ៍ពិពាហ៍ មានបិទរូបថតរបស់សាមីខ្លួនបុរស និងសាមីខ្លួននារី ទំហំ ៤ x ៦ ថតចំពីមុខ ក្នុងរយៈពេល ៣ខែចុងក្រោយ

. ឯកសារថតចម្លង នៃលិខិតឆ្លងដែនរបស់សាមីខ្លួនជនបរទេសមានទិដ្ឋាការចូលប្រទេសកម្ពុជា ដែលនៅមានសុពលភាព

. លិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយ ចេញដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស

. លិខិតបញ្ជាក់សុខភាពចេញដោយសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា

. លិខិតថ្កោលទោសចេញដោយសមត្ថកិច្ចនៃប្រទេសសាមីខ្លួនជនបរទេស

. លិខិតបញ្ជាក់អំពីមុខរបរពិតប្រាកដរបស់សាមីខ្លួនជនបរទេស ដែលធានាដល់ជីវភាពរស់នៅចេញដោយសមត្ថកិច្ចនៃប្រទេសសាមីខ្លួនជនបរទេស

+ សំណុំឯកសារពលរដ្ឋខ្មែរមាន :

. ពាក្យសុំរៀបអាពាហ៍ពិពាហ៍ មានបិទរូបថតរបស់សាមីខ្លួនបុរស និងសាមីខ្លួននារី ទំហំ ៤x ៦ ថតចំពីមុខ ក្នុងរយៈពេល ៣ខែចុងក្រោយ

. សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត

. លិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយ ចេញដោយមេឃុំ ចៅសង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ (ករណីពោះម៉ាយ ឬមេម៉ាយដោយប្រពន្ធ ឬប្តីស្លាប់ត្រូវមានសំបុត្រមរណភាពរបស់សហព័ទ្ធ បើពោះម៉ាយឬមេម៉ាយដោយលែងលះត្រូវមានសាលក្រមពីសាលាដំបូង) ។

. លិខិតបញ្ជាក់សុខភាពចេញដោយមន្ទីរពេទ្យ ដែលទទួលស្គាល់ជាផ្លូវការពីក្រសួងសុខាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។

បើពិនិត្យឃើញឯកសារខាងលើមានលក្ខណៈត្រឹមត្រូវ ស្របតាមការកំណត់ក្នុងបែបបទ និងនីតិវិធីអត្រានុកូលដ្ឋានហើយ មន្ត្រីអត្រានុកូលដ្ឋានដោយមានវត្តមានផ្ទាល់របស់សាមីខ្លួនបុរស និងនារី ត្រូវចេញប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ចំនួន ០៥ច្បាប់ ដោយមានបិទរូបថតសាមីខ្លួនបុរស និងនារី ទំហំ ៤ x ៦ ថតចំពីមុខ ក្នុងរយៈពេល ៣ខែចុងក្រោយ នៅខាងលើផ្នែកខាងស្តាំ សំរាប់ប្រើប្រាស់ដូចខាងក្រោម :

. ០១ច្បាប់ បិទផ្សាយជាសាធារណៈនៅលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ

. ០១ច្បាប់ បិទផ្សាយជាសាធារណៈនៅសាលាឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍សាមីខ្លួនពលរដ្ឋខ្មែរ

. ០១ច្បាប់ បិទផ្សាយជាសាធារណៈនៅស្ថានទូត ឬស្ថានតំណាង នៃប្រទេសសាមីខ្លួនជនបរទេសប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

. ០១ច្បាប់ រក្សាទុកនៅសាលាឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍សាមីខ្លួនពលរដ្ឋខ្មែរ

. ០១ច្បាប់ បិទផ្សាយជាសាធារណៈនៅលំនៅដ្ឋាន ឬទីកន្លែងស្នាក់នៅនៃសាមីខ្លួនជនបរទេស (ករណីជនបរទេសនោះ មានលំនៅដ្ឋាន ឬទីកន្លែងស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា) ។

ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍នេះត្រូវបិទផ្សាយរយៈពេល ១០ថ្ងៃ នៅទីកន្លែងដូចបានកំណត់ខាងលើ ។ ផុតរយៈពេល ១០ថ្ងៃ ប្រសិនបើគ្មានការប្តឹងតវ៉ា ឬប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះ ទើបសាមីខ្លួនបុរស និងនារីអាចរៀបអាពាហ៍ពិពាហ៍បាន ។

អាពាហ៍ពិពាហ៍នឹងមានអនុភាពពេញលក្ខណៈច្បាប់បានលុះត្រាតែសាមីខ្លួនបុរស និងនារីចុះកិច្ចសន្យាអាពាហ៍ពិពាហ៍តាមរយៈការចុះបញ្ជីអាពាហ៍ពិពាហ៍ ដោយសាមីខ្លួនផ្ទាល់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ ដែលសាមីខ្លួនទាំងពីរបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ដោយនាំមកជាមួយនូវសាក្សីគ្រប់អាយុការចំនួន ០២រូបផង ស្របទៅតាមទម្រង់បែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន ។

- មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ក្រោយពីចុះបញ្ជីអាពាហ៍ពិពាហ៍តាមទម្រង់បែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋានហើយ ត្រូវចេញសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើមចំនួន ០១សន្លឹក និងចេញសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍តាមការស្នើសុំរបស់សាមីខ្លួន ដើម្បីយកទៅប្រើប្រាស់ ។

- ធ្វើរបាយការណ៍ជាបន្ទាន់ ផ្ញើមកក្រសួងមហាផ្ទៃ តាមរយៈក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត បន្ទាប់ពីបានចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស នីមួយៗរួចហើយ ដោយបញ្ជាក់អំពីលេខបញ្ជី លេខសៀវភៅ ថ្ងៃ ខែ ឆ្នាំចុះបញ្ជី ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងសញ្ជាតិរបស់សាមីខ្លួនបុរសនិងសាមីខ្លួននារី ។

- បូកសរុបរបាយការណ៍ស្តីពីការអនុវត្តការងារអត្រានុកូលដ្ឋាននៅឃុំ សង្កាត់ ផ្ញើមកសាលាក្រុង ស្រុក ខណ្ឌ នៅរៀងរាល់ថ្ងៃទី ០៥ នៃខែបន្ទាប់ ។

**២. <u>បំរាម និងការទទួលខុសត្រូវចំពោះមុខច្បាប់ ស្តីពីអត្រានុកូលដ្ឋាន</u>**

មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ មិនត្រូវអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរជាមួយជនបរទេសក្នុងករណីដូចខាងក្រោម :

ក- សំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍របស់សាមីខ្លួនជនបរទេស ពុំបានចុះបញ្ជី និងពុំបានជូនដំណឹងពីការសុំរៀបអាពាហ៍ពិពាហ៍ពីក្រសួងមហាផ្ទៃ

ខ- សំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍របស់សាមីខ្លួនជនបរទេស ឬរបស់សាមីខ្លួនពលរដ្ឋខ្មែរពុំបានបំពេញត្រឹមត្រូវតាមបែបបទ និងនីតិវិធីដែលបានកំណត់

គ- សាមីខ្លួនពលរដ្ឋខ្មែរពុំមានលំនៅដ្ឋានអចិន្ត្រៃយ៍នៅក្នុងឃុំ សង្កាត់ ក្នុងដែនដីដែលខ្លួនគ្រប់គ្រង

ឃ- សាមីខ្លួនពលរដ្ឋខ្មែរ និងជនបរទេសពុំទាន់គ្រប់អាយុដែលច្បាប់អនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍

ង- មានការប្តឹងតវ៉ា ឬប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះ ហើយមិនបានដោះស្រាយឱ្យបានចប់សព្វគ្រប់

មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវដូចខាងក្រោម :

ក- ត្រូវប្រើប្រាស់សៀវភៅ និងក្រដាសអត្រានុកូលដ្ឋាន ដែលបោះពុម្ពតាមគំរូឯកភាពចេញដោយក្រសួងមហាផ្ទៃ និងអនុវត្តឱ្យបានត្រឹមត្រូវតាមបែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន អំពីការចេញប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ការចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ ការចេញសំបុត្រអាពាហ៍ពិពាហ៍ និងការចេញសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍។

ខ- រាល់សំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទ ក្រៅពីខ្ទង់សរសេរឈ្មោះជាអក្សរឡាតាំង គឺមិនអនុញ្ញាតឱ្យសរសេរភាសាបរទេសបញ្ចូលឡើយ

គ- រាល់សំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម និងសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទមិនអនុញ្ញាតឱ្យកោស ឆូត លុប ឬសរសេរជ្រៀតឡើយ។

**៣. <u>អំពីការបង់ថ្លៃក្រដាស និងថ្លៃតែមប្រើលើសំបុត្រអត្រានុកូលដ្ឋាន</u>**

ថ្លៃក្រដាសអត្រានុកូលដ្ឋាន និងតែមប្រើត្រូវអនុវត្តតាមអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការកំណត់ថ្លៃជាវក្រដាសអត្រានុកូលដ្ឋាន និងថ្លៃតែមប្រើសារពើពន្ធ ។

ទទួលបានសេចក្តីណែនាំនេះ ស្នើអង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ និងអាជ្ញាធររាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ ចាត់ចែងផ្សព្វផ្សាយ និងមានវិធានការអនុវត្តឱ្យទទួលបានលទ្ធផលល្អ និងមានប្រសិទ្ធភាពខ្ពស់។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**<u>ចម្លងជូន</u> :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
  "ដើម្បីជូនជ្រាប"
- គ្រប់អង្គភាពចំណុះទីស្តីការក្រសួងមហាផ្ទៃ
- រាជធានីភ្នំពេញ គ្រប់ខេត្ត
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

មផ/សអ.២/......

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យសុំរៀបអាពាហ៍ពិពាហ៍

APPLICATION FORM OF MARRIAGE

| រូបថត<br>៤ x ៦<br>សាមីខ្លួនប្រុស | រូបថត<br>៤ x ៦<br>សាមីខ្លួនស្រី |
| --- | --- |

ខ្ញុំបាទ នាងខ្ញុំឈ្មោះ ..............................

(Surname&Name) ..............................

ភេទ ......... សញ្ជាតិ ....................... ថ្ងៃខែឆ្នាំកំណើត ........................ ស្ថានភាពផ្ទាល់ខ្លួន (នៅលីវឬពោះម៉ាយឬមេម៉ាយ) ...............

(Sex) ......... (Nationality) ....................... (Date of Birth) ........................ (Marital Status) ...............

ទីកន្លែងកំណើត ..............................

(Place of Birth) ..............................

លិខិតឆ្លងដែនលេខ ............................ មុខរបរបច្ចុប្បន្ន ............................

(Passport N°) ............................ (Occupation) ............................

ទីលំនៅបច្ចុប្បន្ន ..............................។

(Current Address) ..............................

ឪពុកឈ្មោះ ............................ ថ្ងៃខែឆ្នាំកំណើត ........................ មុខរបរបច្ចុប្បន្ន ........................

(Father's Name) ............................ (Date of Birth) ........................ (Occupation) ........................

ទីលំនៅបច្ចុប្បន្ន ..............................។

(Current Address)..............................

ម្តាយឈ្មោះ ............................ ថ្ងៃខែឆ្នាំកំណើត ........................ មុខរបរបច្ចុប្បន្ន ........................

(Mother's Name) ............................ (Date of Birth) ........................ (Occupation) ........................

ទីលំនៅបច្ចុប្បន្ន ..............................។

(Current Address) ..............................

### គោរពជូន (To)

### មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ......................

(The registrar of the ...................... Commune/Sangkat)

**កម្មវត្ថុ :** សំណើសុំរៀបអាពាហ៍ពិពាហ៍

ខ្ញុំបាទ នាងខ្ញុំបានស្ម័គ្រចិត្តរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ............................ ភេទ ....... ថ្ងៃខែឆ្នាំកំណើត ...................

(To request to marry with ............................ (Sex) ......... (Date of Birth) ...................

មុខរបរបច្ចុប្បន្ន ............................ ទីកន្លែងកំណើត ............................

(Occupation) ............................ (Place of Birth) ............................

ទីលំនៅបច្ចុប្បន្នផ្ទះលេខ ............. ផ្លូវលេខ .............. ភូមិ ............................ ឃុំ សង្កាត់ ............................

(Current Address) No .................... (Street) ................. (Village) ............................ (Commune/Sangkat) ............................

ក្រុង ស្រុក ខណ្ឌ ............................ រាជធានី ខេត្ត............................។

(Municipality/District/Khan) ............................ (Capital/ Province) ............................

ខ្ញុំសូមសន្យាថា នឹងអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និង លិខិតបទដ្ឋានពាក់ព័ន្ធនានា នៃព្រះរាជាណាចក្រកម្ពុជា។

(I pledge that I will abide by all the existing laws and regulations of the Kingdom of Cambodia).

អាស្រ័យហេតុនេះសូមមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ...................... មេត្តាអនុញ្ញាតឱ្យយើងខ្ញុំបានរៀបអាពាហ៍ពិពាហ៍ដោយអនុគ្រោះ។

(Accordingly, please allow us to get married legally).

ធ្វើនៅ......................ថ្ងៃទី ........ ខែ ............ ឆ្នាំ២០០..

(Done on ............................................................)

**ស្នាមមេដៃស្តាំ និងឈ្មោះសាមីខ្លួនជនបរទេស**

(Right thumbprint and name of the foreign applicant)

**សូមជូនភ្ជាប់មកជាមួយ** (Attached Document):

- ឯកសារថតចម្លងនៃលិខិតឆ្លងដែនមានទិដ្ឋាការចូលប្រទេសកម្ពុជា
  ( Copy of Passport and entry visa into Cambodia)
- លិខិតបញ្ជាក់ភាពនៅលីវឬមេម៉ាយឬពោះម៉ាយចំនួន ០១ច្បាប់
  (Certificate of Marital status)
- លិខិតបញ្ជាក់សុខភាពចំនួន ០១ច្បាប់ (Medical Certificate)
- លិខិតថ្កោលទោសចំនួន ០១ច្បាប់ (Criminal Record)
- លិខិតបញ្ជាក់ពីមុខរបរចំនួន ០១ច្បាប់ (Certificate of Profession)

មជ៌/សអ.១/......

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

| រូបថត<br>៤ x ៦<br>សាមីខ្លួនបុរស | រូបថត<br>៤ x ៦<br>សាមីខ្លួននារី |
|---|---|

## ពាក្យសុំរៀបអាពាហ៍ពិពាហ៍

ខ្ញុំបាទ នាងខ្ញុំឈ្មោះ .................................................... ជាអក្សរឡាតាំង ....................................................

ភេទ ........ សញ្ជាតិ ......... ថ្ងៃខែឆ្នាំកំណើត ......................... ស្ថានភាពផ្ទាល់ខ្លួន (នៅលីវ ឬពោះម៉ាយ ឬមេម៉ាយ) ......................

ទីកន្លែងកំណើត ....................................................................................................................

លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ .......................................... មុខរបរបច្ចុប្បន្ន ..........................................

ទីលំនៅបច្ចុប្បន្នផ្ទះលេខ ............... ផ្លូវលេខ ............. ភូមិ ................................ ឃុំ សង្កាត់ ................................

ក្រុង ស្រុក ខណ្ឌ ................................................ រាជធានី ខេត្ត ..........................................។

ឪពុកឈ្មោះ .................................................... ជាអក្សរឡាតាំង ....................................................

ថ្ងៃខែឆ្នាំកំណើត ................................................ មុខរបរបច្ចុប្បន្ន ................................................

ទីលំនៅបច្ចុប្បន្ន ..................................................................................................................។

ម្ដាយឈ្មោះ .................................................... ជាអក្សរឡាតាំង ....................................................

ថ្ងៃខែឆ្នាំកំណើត ................................................ មុខរបរបច្ចុប្បន្ន ................................................

ទីលំនៅបច្ចុប្បន្ន ..................................................................................................................។

### គោរពជូន
### មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ....................

**<u>កម្មវត្ថុ</u>** : សំណើសុំរៀបអាពាហ៍ពិពាហ៍

ដោយខ្ញុំបាទ នាងខ្ញុំបានស្ម័គ្រចិត្តរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ ................................................

ជាអក្សរឡាតាំង ...................................... ភេទ .......... សញ្ជាតិ .................. ថ្ងៃខែឆ្នាំកំណើត ..........................

លិខិតឆ្លងដែនលេខ .................................. មុខរបរបច្ចុប្បន្ន ........................................................

ទីកន្លែងកំណើត ....................................................................................................................

ទីលំនៅបច្ចុប្បន្ន ..................................................................................................................។

ខ្ញុំសូមសន្យាថា នឹងអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនានា នៃព្រះរាជាណាចក្រកម្ពុជា។

អាស្រ័យហេតុនេះ សូមមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ .................................. មេត្តាអនុញ្ញាតឱ្យយើងខ្ញុំទាំងពីរបាន រៀបអាពាហ៍ពិពាហ៍តាមសំណូមពរដោយអនុគ្រោះ។

ធ្វើនៅ.......................ថ្ងៃទី ....... ខែ ............ ឆ្នាំ២០០..

**ស្នាមមេដៃស្ដាំ និងឈ្មោះសាមីខ្លួនពលរដ្ឋខ្មែរ**

**<u>សូមជូនភ្ជាប់មកជាមួយ</u> :**

- សេចក្ដីចម្លងសំបុត្រកំណើត ឬបញ្ជាក់កំណើត ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយ ចំនួន ០១ ច្បាប់
  (ករណីពោះម៉ាយឬមេម៉ាយដោយប្រពន្ធឬប្ដីស្លាប់ ត្រូវមានសំបុត្រមរណភាពរបស់សហព័ទ្ធ បើពោះម៉ាយ ឬមេម៉ាយ ដោយការលែងលះ ត្រូវមានសាលក្រមពីសាលាដំបូង)
- លិខិតបញ្ជាក់សុខភាព ចំនួន ០១ ច្បាប់

(គំរូ)

រាជធានីភ្នំពេញ.ថ្ងៃទី ខែ ឆ្នាំ ២០០..

ជម្រាបមក

ឯកឧត្តមអភិបាលរាជធានី ខេត្ត .......................

**កម្មវត្ថុ** : ករណីស្នើសុំរៀបអាពាហ៍ពិពាហ៍របស់ជនបរទេសឈ្មោះ.............................................................

**យោង** :
- អនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស
- សេចក្តីណែនាំលេខ...........សជណ ចុះថ្ងៃទី....... ខែ........ ឆ្នាំ២០០..... របស់ក្រសួងមហាផ្ទៃ ស្តីពីការអនុវត្តបែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស
- លិខិតស្នើសុំរៀបអាពាហ៍ពិពាហ៍របស់ជនបរទេសឈ្មោះ ....................................................... ចុះថ្ងៃទី ......... ខែ ........... ឆ្នាំ ២០០...

តបតាមកម្មវត្ថុ និងយោងខាងលើ ក្រសួងមហាផ្ទៃ ជំរាបមកឯកឧត្តមអភិបាល................ ជ្រាបថា ជនបរទេសឈ្មោះ...................................... ភេទ ....... សញ្ជាតិ ........... ថ្ងៃខែឆ្នាំកំណើត .................. លិខិតឆ្លងដែនលេខ ........................... បានស្នើសុំរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ .................................. ភេទ ........ ថ្ងៃខែឆ្នាំកំណើត ............................... ទីលំនៅបច្ចុប្បន្នផ្ទះលេខ .......... ផ្លូវលេខ ...... ក្រុម ...... ភូមិ .............. ឃុំ សង្កាត់ .......................ក្រុង ស្រុក ខណ្ឌ ......................... រាជធានី ខេត្ត .................. ។

ក្រសួងមហាផ្ទៃ បានពិនិត្យ និងចុះបញ្ជី លើសំណុំឯកសារស្នើសុំរៀបអាពាហ៍ពិពាហ៍របស់សាមីខ្លួនជនបរទេសរួចរាល់ហើយ ។ ដូច្នេះ សាមីខ្លួនជនបរទេសត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ............................. ។

សេចក្តីដូចបានជំរាបខាងលើ សូមឯកឧត្តមអភិបាល ជ្រាបតាមការគួរ ។/.

ជ. រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

**ចម្លងជូន** :
- ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- សាលាក្រុង ស្រុក ខណ្ឌ.........
  "ដើម្បីជ្រាប"
- សាលាឃុំ សង្កាត់.........
- សាមីខ្លួន
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ